# ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨

## អាជ្ញាធរថៃចាប់បញ្ជូនពលរដ្ឋខ្មែរ១៣នាក់មកស្រុកវិញ បន្ទាប់ពីពួកគេលួចឆ្លងដែនខុសច្បាប់

http://ppd-news.net/ *Posted By: admin November 30, 2018*

ខេត្តឧត្តរមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរចំនួន១៣នាក់ក្នុងនោះមានស្រីចំនួន៤នាក់ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកឲ្យភាគីកម្ពុជាវិញ កាលពីម្សិលមិញតាមច្រកអន្តរជាតិជាំស្រងាំ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បន្ទាប់ពីពួកគេឆ្លងដែនខុសចច្បាប់ទៅរកការងារធ្វើនៅក្នុងទឹកដីថៃ។ ពលរដ្ឋខ្មែរចំនួន១៣នាក់ មានទី១.ឈ្មោះ ដាក ច្រឹក ភេទស្រី អាយុ៣៥ឆ្នាំ,ទី២.ឈ្មោះ ម៉ាន នាត ភេទប្រុស អាយុ៤៨ឆ្នាំ, ទី៣.ឈ្មោះ ពៃក ហេន ភេទប្រុស អាយុ៣២ឆ្នាំ, ទី៤.ឈ្មោះ ហ៊ន វី ភេទស្រី អាយុ៣៩ឆ្នាំ, ទី៥.ឈ្មោះ ធឿន ជារិទ្ធិ ភេទប្រុស អាយុ២០ឆ្នាំ, ទី៦.ឈ្មោះ ធាត ផល ភេទប្រុស អាយុ៣៣ឆ្នាំ, ទី៧.ឈ្មោះ ក្រិត សុផាត ភេទប្រុស អាយុ១៩ឆ្នាំ, ទី៨.ឈ្មោះ ក្រឹក សុភារ័ក្ស ភេទប្រុស អាយុ២១ឆ្នាំ, ទី៩.ឈ្មោះ ហិន ហេង ភេទប្រុស អាយុ១៩ឆ្នាំ, ទី១០.ឈ្មោះ យួន តូ ភេទប្រុស អាយុ៣៦ឆ្នាំ, ទី១១.ឈ្មោះ មាន ធូ ភេទប្រុស អាយុ៣៨ឆ្នាំ, ទី១២.ឈ្មោះ ពុំ រុង ភេទស្រី អាយុ៣៥ឆ្នាំ, និងទី១៣.ឈ្មោះ រ៉េត ទន់ ភេទស្រី អាយុ២៨ឆ្នាំ។ អ្នកទាំង១៣ មានទីលំនៅ ភូមិប៉ោយសំពោង ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង ៕

## ការសែតបរទេសនិងអ្នកវិភាគៈ ពលករខ្មែរធ្វើការនៅក្រៅប្រទេសនៅតែងាយរងគ្រោះ

http://wmc.org.kh/ ថ្ងៃសុក្រ ទី៣០ ខែកញ្ញា ឆ្នាំ២០១៨ ជុំ ដោគជាតា

ភ្នំពេញ៖ នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន ថ្មីៗនេះមានប្រសាសន៍ថា ការដែលប្រជាជនកម្ពុជាទៅធ្វើការនៅប្រទេសក្រៅមិនមែនជារឿងអាក្រក់នោះទេ។ តែយ៉ាងណា អ្នកវិភាគថា ពលករខ្មែរជាពលករដែលទទួលហានិភ័យខ្ពស់ជាងគេ ប្រើប្រៀបធៀបជាមួយពលកររបស់ប្រទេសដទៃក្នុងតំបន់អាស៊ី។ ស្របពេលនេះដែរ ការសែតបរទេសបានចុះផ្សាយថា ពលករតាមផ្ទះរបស់កម្ពុជានៅគុយវ៉ែត ឬមជ្ឈឹមបូព៌ាទទួលភាពអយុត្តិធម៌ និងលក្ខខ័ណ្ឌការងារអាក្រក់បំផុត។

គេហទំព័រព័ត៌មានបរទេសមួយ មានឈ្មោះថា UCANEWS បានចុះផ្សាយព័ត៌មានកាលពីថ្ងៃទី ២៨ ខែ វិច្ឆិកា ថា ពលករតាមផ្ទះនៃប្រទេសកម្ពុជានៅគុយវ៉ែត ឬមជ្ឈឹមបូព៌ា ជាក្រុមងាយទទួលភាពអយុត្តិធម៌ និងលក្ខខ័ណ្ឌការងារអាក្រក់បំផុត។ គេហទំព័រនេះ បានស្រង់សម្តីនឹងរឿងរ៉ាវរបស់ស្ត្រីកម្ពុជាមួយចំនួនដែលធ្វើការងារផ្ទះនៅតំបន់ទាំងនោះ។ ក្នុងនោះ ស្ត្រីខ្មែរម្នាក់ឈ្មោះ Ary Ramsan ក្នុងចំណោមស្ត្រីជាច្រើនដែលធ្លាប់បានធ្វើការក្នុងបរិយាកាសដ៏រន្ធត់។

កាលពីពីរឆ្នាំមុន យ៉ាងតិចណាស់មានស្ត្រីចំនួន ៦នាក់ ដែលបានត្រឡប់មកផ្ទះវិញជាមួយនឹងរឿងរ៉ាវរំលោភ និងកេងប្រវ័ញ្ចគ្រប់រូបភាពយ៉ាងខ្លាំង។ បញ្ហានេះ អង្គការសិទ្ធិមនុស្សក៏ធ្លាប់បានព្រមានអំពីគ្រោះថ្នាក់នៃការបញ្ជូនពលករទៅធ្វើការនៅប្រទេស អារ៉ាប៊ីសាវអ៊ូឌីត ឡេបាណន់ និងគុយវ៉ែត។

UCANEWS ចុះផ្សាយបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា ហាក់ដូចជាមានការជឿជាក់ថា ការបញ្ជូនពលករចំនួន ៥ ពាន់នាក់ទៅប្រទេសគុយវ៉ែត ក្នុងឆ្នាំ២០១៩ ប្រហែលជាគ្មានបញ្ហានោះទេ។ ពលករដែលធ្វើការនៅក្រៅប្រទេសខ្លះដែលជាស្ត្រីបម្រើការនៅក្នុងផ្ទះ កម្មកររោងចក្រ កម្មករសំណង់ និងកសិករជាដើម។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិយាយថា រាជរដ្ឋាភិបាលកម្ពុជានឹងជួយការពារពលករ តាមរយៈអនុស្សារ ណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខាតាំងពីជាង ១០ឆ្នាំមុន។តែអនុប្រធានអង្គការឃ្លាំមើលសិទ្ធិមនុស្ស Hunman Rights Watch លោក Phil Robertson បានបង្ហាញការព្រួយបារម្ភ

ចំពោះគម្រោងរបស់កម្ពុជានេះ។ លោកមានប្រសាសន៍ប្រាប់សារព័ត៌មាននេះថា ពលករជាច្រើននឹងប្រឈមមុខទៅនឹងការរំលោភសិទ្ធិមនុស្សនៅប្រទេសគុយវ៉ែត។ ជាងនេះ ពួកគេងាយរងគ្រោះក្នុងករណីរំលោភបំពានលើរូបរាងកាយ និងពាក្យសម្ដី ការបង្ខំដោយឱ្យធ្វើការបន្ថែមម៉ោងមិនបើប្រាក់ឈ្នួល និងបិទសិទ្ធិសេរីភាពជាដើម។ លោកបន្ថែមថា ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាមានការហ្មត់ចត់ចំពោះការការពារពលករនោះត្រូវតែមានបង្កើតនូវលេខទំនាក់ទំនងហ៉េសពេលមានអាសន្នព្រមទាំងបង្កើន និងពង្រឹងក្រុមមន្ត្រីស្ថានទូតកម្ពុជានៅប្រទេសទាំងនោះ ដែលអាចធ្វើអន្តរាគមន៍ និងផ្ដល់ជម្រកដល់ពលករដែលបានរងការរំលោភបំពានទាំងនោះ។

ទោះបីជាមានភាពចម្រូងចម្រាស់បែបនេះក្ដី ក៏រាជរដ្ឋាភិបាលកម្ពុជាមិនបញ្ឈប់ការបញ្ជូនពលករទៅបរទេសដែរ។ បើតាមការប៉ាន់ប្រមាណប្រជា ជនកម្ពុជាប្រហែលជា ១លាន ទៅ ២លាននាក់ គឺកំពុងតែធ្វើការនៅក្រៅប្រទេសរបស់ខ្លួនដែលភាគច្រើន គឺប្រទេសថៃ។ ការសែត UCANEWS នេះ ក៏បានចុះផ្សាយបន្ថែមអំពីបរិយាកាសការងាររបស់ស្ត្រីកម្ពុជាម្នាក់ទៀតឈ្មោះថា El Maiyan ។ យ៉ាងណា ពលករកម្ពុជានោះរៀបរាប់ថា នាងបានទៅប្រទេសអារ៉ាប់ប៊ីសាអូឌីតតាមរយៈភ្នាក់ងារការងារវៀតណាមដោយទៅធ្វើជាស្ត្រីមេផ្ទះ។ El Maiyan ធ្វើការ១៦ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្ដាហ៍ ព្រមទាំងធ្វើការហួសកម្លាំងទៀតផង។ ជាងនេះទៀត នាងត្រូវបានម្ចាស់ផ្ទះវាយទាត់ធ្វើបាបជារៀងរាល់ថ្ងៃដែលធ្វើឱ្យរាងការចុះខ្សោយរួមទាំងក្អកធ្លាក់ឈាម។ បើទោះបីជានាងត្រូវបានត្រឡប់មកកម្ពុជាក្ដី ក៏នាងនៅតែមានអារម្មណ៍ថា ខ្លាចឈឺ និងចងចាំរឿងទាំងនេះរហូតមកដល់សព្វថ្ងៃ។

កាលពីថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានសរសេរលើទំព័រហ្វេសបុករបស់ខ្លួន ដោយអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់ កុំគិតថា ការដែលមានពលរដ្ឋធ្វើការនៅក្រៅប្រទេសថា នេះជារឿងខុស។ សម្ដេចបញ្ជាក់ថា ប្រទេសមួយចំនួនក៏បញ្ជូនពលរដ្ឋទៅធ្វើការនៅបរទេសដូចកម្ពុជាដែរ។

ដោយឡែក លោកបណ្ឌិត មាស នី អ្នកវិភាគបញ្ហាសង្គម និងនយោបាយបានសរសេរលើទំព័រហ្វេសបុករបស់លោកថា ការបញ្ជូនពលករទៅបរទេសជាដំណឹងល្អសម្រាប់រាជរដ្ឋាភិបាល។ យ៉ាងណា អ្នកវិភាគរូបនេះ បានប្រាប់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា នៅព្រឹកថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨នេះថា កម្ពុជាជាប្រទេសដែលមានកម្លាំងពលកម្មច្រើនជាងគេនៅតំបន់អាស៊ី។លោកបណ្ឌិត មាស នី បន្ថែមថា រដ្ឋាភិបាលកម្ពុជាមិនទាន់មានការយកចិត្តទុកដាក់ដល់ពលករដែលបានបញ្ជូនទៅបរទេសឱ្យបានច្រើននៅឡើយទេ។ លោក បណ្ឌិត មាស នី៖ «ក៏ប៉ុន្តែបញ្ហាដែលវាពិបាកនោះ ត្រង់ថា រដ្ឋាភិបាលកម្ពុជាយើងមិនទាន់បានផ្ដល់ការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការថែទាំពលកររបស់ខ្លួនដែលបានបញ្ជូនទៅបរទេសនឹងនៅឡើយទេនេះជាករណីដែលខ្ញុំបានឃើញនៅក្នុងប្រទេសដទៃ ហើយតាមស្ថានទូតបរទេសមួយៗ របស់កម្ពុជា ដែលមានពលករខ្មែរធ្វើការហ្នឹងក៏មិនទាន់បានបម្រើពលរដ្ឋនឹងឱ្យបានពេញដៃពេញជើង »។ ជាងនេះទៅទៀត លោកបានបញ្ជាក់ថា ប្រទេសណាក៏មានពលរដ្ឋទៅធ្វើការនៅបរទេសដែរ ប៉ុន្តែខុសគ្នាត្រង់ថាពលករកម្ពុជាដែលទៅធ្វើការនៅបរទេស ជាការធ្វើការដោយកម្លាំង និងគ្មានជំនាញ ព្រមទាំងទទួលបានប្រាក់ឈ្នួលតិចជាដើម។ លោក បន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា ត្រូវតាមដានលើសុវត្ថិភាព សិទ្ធិការងារ ដែលនេះ គឺជាកត្តាសំខាន់បំផុត។

តាមរបាយការណ៍លទ្ធផលនៃសន្និបាតបូកសរុបការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ បង្ហាញថា រដ្ឋាភិបាលកម្ពុបានផ្ដល់សេវាស្វែងរកការងារធ្វើនៅក្រៅប្រទេសដល់ពលរដ្ឋចំនួនជាង ១លាន២សែននាក់។ ក្នុងចំណោមពលករទាំងនោះ គឺពលករទៅប្រទេសថៃមានជាង ១លាននាក់ កូរ៉េខាងត្បូងចំនួន ៤ម៉ឺននាក់ ជប៉ុនចំនួន ៦ពាន់នាក់ ម៉ាឡេស៊ីចំនួន ៣ម៉ឺននាក់ សិង្ហបុរីចំនួនជិត ៥០០នាក់ និងតំបន់រដ្ឋបាលពិសេសហុងកុង បានចាប់ផ្ដើមបញ្ជូនពលការិនីចំនួន ១៥នាក់។ របាយការណ៍ដដែលនោះ ក៏បានអះអាងថា ប្រជាពលរដ្ឋកម្ពុជាមានការងារធ្វើសរុបមានចំនួន ៩៩,៣%។

របាយការណ៍រវាងអង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ចេញផ្សាយថា ពលករខ្មែរធ្វើការនៅបរទេស មួយចំនួន ៨នាក់ ក្នុងចំណោម ១០នាក់ ត្រូវបានរំលោភបំពានសិទ្ធិការងារ ដែលស្មើនឹង ៨០ភាគរយ។ ជាងនេះ ពលករខ្មែរ ៧នាក់ ក្នុងចំណោម១០នាក់ មានបញ្ហាជំងឺផ្លូវចិត្ត ដែលស្មើនឹង ៦៦ភាគរយ៕

## អូស្ត្រាលីផ្លាស់ប្តូរច្បាប់ថ្មីដើម្បីទប់ស្កាត់ការជួញដូរកុមារកំព្រា

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 01/12/2018

អូស្ត្រាលី ៖ យោងតាមទីភ្នាក់ងារសារព័ត៌មាន AFP បានឲ្យដឹងថា ប្រទេសអូស្ត្រាលីបានដាក់កំហិតទៅលើទង្វើនៃការបញ្ឆោតកុមារក្នុងមណ្ឌលកុមារកំព្រាដែលជាទម្រង់នៃទាសភាពនៅក្នុងអ្វីដែលត្រូវបានគេជឿថាជាការផ្លាស់ប្តូរលើកដំបូងរបស់ខ្លួននៅក្នុងពិភពលោក ។ ចំពេលមានការព្រមានថាកុមារនៅតាមបណ្តាប្រទេសក្រីក្រត្រូវបានដឹកជញ្ជូនចូលទៅក្នុងស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងតំរូវការប្រាក់ខែសំរាប់ការងារស្ម័គ្រចិត្តនៅភាគខាងលិច ដោយច្បាប់ថ្មីត្រូវបានណែនាំដើម្បីដោះស្រាយបញ្ហានេះ ។ ច្បាប់ស្តីពីទាសភាពសម័យទំនើបត្រូវបានអនុម័តដោយសភាទាំងពីរកាលពីថ្ងៃព្រហស្បតិ៍ ហើយរួមបញ្ចូលទាំងការបញ្ជាក់ពីការជួញដូរ ឬការកេងប្រវ័ញ្ចលើកុមារនៅក្នុងមណ្ឌលកុមារកំព្រា ។ក្រោមច្បាប់ថ្មីនេះដែលគេហៅថា"ការជួញដូរកុមារកំព្រា" នឹងត្រូវបានចាត់ទុកថាជាទាសភាព និងការជួញដូរ ។

លោក Paul Ronalds នៃអង្គការជួយសង្គ្រោះកុមារអូស្ត្រាលីដែលជាក្រុមបញ្ចុះបញ្ចូលក្រៅរដ្ឋាភិបាលបាននិយាយថា "ប្រទេសអូស្ត្រាលីគឺជាប្រទេសដំបូងគេបង្អស់នៅលើពិភពលោកដែលទទួលស្គាល់ការជួញដូរកុមារកំព្រាជាទម្រង់ទាសភាពសម័យទំនើប" ។គេប៉ាន់ប្រមាណថា ប្រហែល ៨០ ភាគរយនៃកុមារ ៨ លាននាក់នៅតាមមណ្ឌលកុមារកំព្រានៅទូទាំងពិភពលោកមានឪពុកម្តាយ ឬគ្រួសារដែលអាចថែរក្សាពួកគេ ។ ពេលខ្លះកុមារត្រូវបានបញ្ជូនទៅឆ្ងាយដោយឪពុកម្តាយរបស់ពួកគេជឿថាពួកគេនឹងទទួលបានការអប់រំល្អ ។យោងទៅតាមអង្គការសង្គ្រោះកុមារជាងបានឲ្យដឹងថា ៥០ ភាគរយនៃសាកលវិទ្យាល័យប្រទេសអូស្ត្រាលីបានផ្សព្វផ្សាយការស្វែងរកការងារធ្វើឲ្យកុមារកំព្រាជាឱកាសស្ម័គ្រចិត្តនៅបរទេស ។ ក្រុមសកម្មជនសង្ឃឹមថាការផ្លាស់ប្តូរច្បាប់នេះនឹងធ្វើឲ្យពលរដ្ឋអូស្ត្រាលីកាន់តែប្រុងប្រយ័ត្នក្នុងការធ្វើសកម្មភាពស្ម័គ្រចិត្តនៅក្រៅប្រទេស ៕

## ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨

## រោងជ័យខ្មែរ-ចិនមិនទាន់ចប់ស្រួលផង ត្រូវបញ្ឈប់ឆ្អើលពេញរោង

https://www.khmerload.com/news/ ២១ ម៉ោងមុន 14:28 December 03, 2018

ខេត្តកណ្តាល ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា អាពាហ៍ពិពាហ៍រវាងជនជាតិចិន និងខ្មែរ ដែលបានលួចរៀបការដោយពុំមានច្បាប់ទម្លាប់ត្រឹមត្រូវនោះទេ ហើយត្រូវកម្លាំងសមត្ថកិច្ចនគរបាលស្រុកកៀនស្វាយ បានចុះទៅធ្វើការបញ្ឈប់អាពាហ៍ពិពាហ៍នោះ បង្កឱ្យមានការភ្ញាក់ផ្អើលកាលពីម៉ោង១១និង៣០នាទីព្រឹក ថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០១៨ ស្ថិតនៅក្នុងភូមិសំរោងក្អែ៣ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ សេចក្តីរាយការណ៍បន្តថា កូនកំលោះឈ្មោះ YANG XIMING អាយុ៣០ឆ្នាំ ជាជនជាតិចិន មានទីលំនៅបច្ចុប្បន្នស្នាក់នៅសិប្បកម្មបោះពុម្ពលី.ផេង (រាជធានីភ្នំពេញ) កាន់លិខិតឆ្លងដែនលេខ E82486140 ផុតកំណត់ថ្ងៃទី07.07.2026 និងទិដ្ឋាការលេខ EI01027234 ផុតកំណត់ថ្ងៃទី27.09.2019។ ចំណែកកូនក្រមុំឈ្មោះតូ ស្រីជាតិ អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ-ឃុំខាងលើ។

បើយោងតាមរបាយការណ៍របស់សមត្ថកិច្ចនគរបាលស្រុកកៀនស្វាយ បានបញ្ជាក់ឲ្យដឹងថា នៅម៉ោង១០និង៣០នាទីព្រឹកថ្ងៃទី២ ធ្នូនោះ មានសេចក្តីរាយការណ៍ថា មានពិធីរៀបមង្គលការមួយនៅចំណុចភូមិ-ឃុំខាងលើ ដែលមានកូនកំលោះជាជនជាតិចិន និងកូនក្រមុំជាជនជាតិខ្មែរ ខណៈដែលអាជ្ញាធរស្រុក ពុំបានចេញច្បាប់ទម្លាប់ឲ្យនោះ

ឡើយ។ ប្រភពខាងលើបន្តថា ហើយបន្ទាប់ពីទទួលបានព័ត៌មាននេះភ្លាម កម្លាំងសមត្ថកិច្ចនគរបាលជំនាញស្រុកសហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍មូលដ្ឋានចុះទៅធ្វើការបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍នេះភ្លាមៗតែម្តង។ ។ ក្រោយពីធ្វើការបញ្ឈប់ការរៀបអាពាហ៍អាពាហ៍នេះហើយ សមត្ថកិច្ចក៏បានកសាងសំណុំរឿង តាមនីតិវិធីច្បាប់៕

## ចុះបង្ក្រាបទីតាំងរកស៊ីផ្លូវភេទ ឃាត់ខ្លួនច្រើននាក់

https://kohsantepheapdaily.com.kh/ *ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨ម៉ោង ១៥:៤៥ប្រាក់ សារិទ្ធ*

ខេត្តកំពត ៖ កំលាំងសមត្ថិកច្ចនគរបាលក្រុងកំពតដឹកនាំដោយលោកវរសេនីយ៍ទោហោ វណ្ណា អធិការនគរបាលក្រុងកំពតបានចុះបង្ក្រាបទីតាំងរកស៊ីផ្លូវភេទមួយកន្លែងនៅចំណុចដើមក្រខុប ស្ថិតក្នុងភូមិទ្វីខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត កាលពីវេលាម៉ោង៩និង៥០នាទីយប់ថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៨ ។ ក្នុងកិច្ចចុះប្រតិបត្តិការខាងលើ កំលាំងសមត្ថកិច្ចបានឃាត់ខ្លួននារីដែលបំរើការងារក្នុងទីតាំងខាងលើបានចំនួន៤នាក់ ក្នុងនោះមានម្ចាស់ទីតាំងម្នាក់និងបុរសដែលជាភ្ញៀវចំនួន៤នាក់ផងដែរនាំមកកាន់អធិការនគរបាលក្រុងកំពត ដើម្បីចាត់ការតាមនីតិវិធី។ លោកវរសេនីយ៍ទោ ហោ វណ្ណា អធិការនគរបាលក្រុងកំពតបានប្រាប់ឱ្យដឹងថា ដោយទទួលបញ្ជា និងការចង្អុលបង្ហាញពីលោកឧត្តមសេនីយទោ ម៉ៅ ចន្ទ័មធុរិទ្ធ ស្នងការនគរបាលខេត្តដើម្បីចុះបង្ក្រាបផ្ទះបើករកស៊ីផ្លូវភេទមួយកន្លែងខាងលើតាមសេចក្តីរាយការណ៍ពីប្រជាពលរដ្ឋដែលនៅក្នុងភូមិនោះ លោកក៏បានសុំកំលាំងការិយាល័យជួញដូរនិងការពារអនិតីជននៃស្នងការខេត្តដើម្បីចុះបង្ក្រាប និងឃាត់ខ្លួនប្រុសស្រីចំនួន៨នាក់ខាងលើនាំមកកាន់អធិការនគរបាលក្រុងកំពត ដើម្បីធ្វើការសាកសួរនិងកសាងសំណុំរឿងតាមនីតិវិធី។ ព័ត៌មានលម្អិតនឹងមានផ្សាយនៅលើទំព័រកាសែតកោះសន្តិភាព ៕

## នាយឧត្តមសេនីយ៍ ហ៊ូ សាគុណ ដឹកនាំប្រតិភូរបស់អគ្គស្នងការនគរបាលជាតិប្រជុំពិភាក្សាជាមួយលោកBretl Dicksonប្រធានគំរោងអង្គការIOMរបស់ប្រទេសកាណាដា

http://cambodiapolice.com/policekh/ 5:49 pm 3 ធ្នូ 2018

បាត់ដំបង៖ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្នាក់ការប៉ុស្តិ៍នគរបាលច្រកទ្វារតំបន់អូរអន្លក់ ព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨ ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ូ សាគុណ អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែនបានដឹកនាំប្រតិភូរបស់អគ្គស្នងការនគរបាលជាតិ រួមជាមួយលោកមេបញ្ជាការរងប្រចាំភូមិភាគទី៥ លោក ស្នងការរងខេត្ត លោកមេបញ្ជាការវរៈ ៨១៩ លោកនាយប៉ុស្តិ៍ច្រកទ្វារតំបន់អូរអន្លក់ និងអូរជ្រៃល ជួបប្រជុំពិភាក្សាជាមួយលោក Bretl Dickson ប្រធានគំរោងអង្គការ IOM របស់ប្រទេសកាណាដាប្រចាំនៅប្រទេសកម្ពុជាក្នុងគោលបំណងស្វែងយល់អំពីលំហូរចំណាកស្រុកប្រជាពលរដ្ឋខ្មែរតាមតំបន់ព្រំដែនកម្ពុជា-ថៃក្នុងភូមិសាស្រ្តខេត្តបាត់ដំបងក្នុងគោលបំណង ដើម្បីហ្វឹកហ្វឺនមុខជំនាញបច្ចេកទេសផ្នែកប្រពន្ធ័ទិន្នយ័ដល់កងកម្លាំងនគរបាល ដើម្បីងាយស្រួលក្នុងការក្តាបតាមដាន និងត្រួតពិនិត្យការលំហូរចំណាកស្រុករបស់ប្រជាពលរដ្ឋអោយបានច្បាស់លាស់។

ជាកិច្ចឆ្លើយតបនាយឧត្តមសេនីយ៍អគ្គស្នង ការរងនគរបាលជាតិបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់តំណាងអង្គការ IOM ដែលមានគំរោងជួយបណ្តុះបណ្តាលធនធានមនុស្សផ្នែកប្រពន្ធ័ទិន្នយ័ផ្នែកបច្ចេកទេសដល់នគរបាលកម្ពុជានាពេលនេះអោយទទួលបាននូវប្រសិទ្ធភាព៕

## ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨

## សមាគមកម្ពុជា-ម៉ាឡេស៊ី ចុះMOU លើកកម្ពស់សិទ្ធិ សុខុមាលភាព និងកិច្ចគាំពារដល់ពលករកម្ពុជាទៅធ្វើការនៅប្រទេសម៉ាឡេស៊ី

http://www.mlvt.gov.kh/ ថ្ងៃទី ០៥ ធ្នូ ២០១៨

(ភ្នំពេញ)៖ សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC) សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីការសហការការពារពលករកម្ពុជាធ្វើការនៅម៉ាឡេស៊ី ជាមួយ សមាគមម៉ាឡេស៊ីនៃទីភ្នាក់ងារស្ត្រីជំនួយការមេផ្ទះ(PAPA) សមាគមជាតិធនធនមនុស្សម៉ាឡេស៊ី (PUSMA) និង សមាគមជាតិម៉ាឡេស៊ីទីភ្នាក់ងារការងារ(PIKAP)ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការ ក្រសួងការងារ នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨។

គោលបំណងនៃអនុស្សរណៈយោគយល់គ្នានេះ សំដៅបង្កើតកិច្ចសហប្រតិបត្តិការ រវាងសមាគមទាំងប្រាំ ដើម្បីចូលរួមលើកកម្ពស់សិទ្ធិ សុខុមាលភាព និងការការពារពលករទេសន្តប្រទេសន៍កម្ពុជាដែលធ្វើការនៅប្រទេសម៉ាឡេស៊ី។ បន្ថែមពីនេះទៀត អនុស្សរណៈយោគយល់គ្នានេះក៍ជាយន្តការថ្មីមួយ នៅក្នុងការធ្វើសកម្មភាពបង្កើនអត្ថប្រយោជន៍ជូនពលករទេសន្តប្រវេសន៍កម្ពុជាដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

ការបើកដំណើរការឡើងវិញនៃការជ្រើសរើស និងបញ្ជូនពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានផ្អាកការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសរួចមក រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការ និងបទដ្ឋានគតិយុត្តិជាច្រើនសម្រាប់ការពារ គ្រប់គ្រង និងលើកកម្ពស់សិទ្ធិដល់ពលករខ្មែរទាំងអស់ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសម៉ាឡេស៊ី។

សូមបញ្ជាក់ថា បច្ចុប្បន្នទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាដែលទទួលបានកាអនុញ្ញាតពីក្រសួងមានចំនួន ១០៣ ឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស។ ក្នុងនោះប្រទេសម៉ាឡេស៊ី មានចំនួន ៦៩ ក្រុមហ៊ុន (គិតត្រឹម ខែតុលា ឆ្នាំ២០១៨)។

## នារីចិន ១៤៤នាក់ ត្រូវគេបោកតាមបណ្តាញសង្គម ទៅធ្វើពេស្យាចារនៅសិង្ហបុរី

http://kleykley.sabay.com.kh/ ថ្ងៃទី ០៤ ធ្នូ ២០១៨ ម៉ោង 15:39

ជនសង្ស័យជាង ៣០នាក់ត្រូវបានចាប់ខ្លួន ខណៈប៉ូលិសរកឃើញស្ត្រីចិន ១៤៤នាក់ ត្រូវបានគេបោកទៅធ្វើពេស្យាចារនៅក្នុងតំបន់ភ្លើងក្រហម ក្នុងប្រទេសសិង្ហបុរី។ នេះបើតាមការប្រកាសរបស់ក្រសួងសន្តិសុខសាធារណៈចិន កាលពីថ្ងៃទី៣ ខែវិច្ឆិកា ២០១៨ ម្សិលមិញ។

ក្រសួងសន្តិសុខជាតិចិនបញ្ជាក់ថា ប៉ូលិសក្នុងប្រទេសចិន និងសិង្ហបុរីបានរកឃើញក្រុមបងធំ កាលពីខែមីនា ដោយក្រុមបងធំនោះបានប្រើបណ្តាញសង្គម WeChat និងកម្មវិធីផ្ញើសារផ្សេងទៀត បោកនារីចិនដីគោកជាង ១០០ នាក់ ទៅធ្វើពេស្យាចារនៅក្នុងប្រទេសសិង្ហបុរី។ ពេស្យាចារ គឺស្របច្បាប់នៅក្នុងប្រទេសសិង្ហបុរី នៅក្នុងតំបន់ភ្លើងក្រហមដែលអនុញ្ញាតដោយរដ្ឋាភិបាល ប៉ុន្តែត្រូវបានបញ្ញត្តិ និងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង។ សិង្ហបុរីហាមមិនឲ្យមានផ្ទះបន ការផ្តល់សេវាពេស្យាចារនៅតាមទីសាធារណៈ ការផ្សព្វផ្សាយសេវាពេស្យាចារតាមអនឡាញ និងការជ្រើសរើសនារីពេស្យាចារ។

បច្ចុប្បន្ន មានផ្ទះបនដែលទទួលអាជ្ញាបណ្ណ ប្រមាណ ៩០ទីតាំង ដែលកំពុងប្រតិបត្តិការនៅក្នុងតបន់ភ្លើងក្រហម របស់សិង្ហបុរី ប៉ុន្តែមាននារីកស៊ីផ្លូវភេទជាច្រើនកំពុងធ្វើការដោយខុសច្បាប់ក្នុងផ្ទះបនដែលពុំមានអាជ្ញាប

ណ្ណ។ នេះបើតាមការបញ្ជាក់របស់លោកស្រី Vanessa Ho ប្រធានក្រុមតស៊ូមតិសម្រាប់នារីរកស៊ីផ្លូវភេទក្នុងប្រទេសសិង្ហបុរី។ អំឡុងការស៊ើបអង្កេត ប៉ូលិសចិនបានកំណត់មុខសញ្ញាមេជួញដូរមនុស្សចំនួន ២នាក់ ដែលមានឈ្មោះ Zhou និង Zhu វ័យ ២៧ដូចគ្នា នៅក្រុង Lianyungang ខេត្ត Jiangsu ភាគខាងកើតប្រទេសចិន។ ប៉ូលិសចិនបញ្ជាក់ថា ប៉ូលិសចិន និងសិង្ហបុរីបានចាប់ខ្លួនជនសង្ស័យទាំងនោះ នៅថ្ងៃទី២២ ខែវិច្ឆិកា ក្នុងប្រតិបត្តិការរួម នៅក្នុងប្រទេសទាំងពីរ៕ ប្រភព៖ South China Morning Post ប្រែសម្រួល៖ វាសនា

## ថ្ងៃទី06 ខែធ្នូ ឆ្នាំ២០១៨

## រដ្ឋគួរបង្កើនខ្ទង់ចំណាយលើការស្តារនីតិសម្បទា ជនដែលត្រូវគេជួញដូរ

https://www.postkhmer.com/ តុង សុប្រាជ្ញ | Publication date 05 December 2018 | 10:06 ICT

នៅថ្ងៃទី ១២ ខែធ្នូ សប្តាហ៍ក្រោយនេះគឺជាទិវាជាតិប្រឆាំងនឹងអំពើជួញដូរមនុស្សលើកទី ១២ នៅឆ្នាំនេះ។ តាមរយៈការសិក្សារបស់អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការអន្តោប្រវេសន៍អន្តរជាតិ (IOM) ឆ្នាំ ២០១៧ ក្នុងចំណោមពលករចំណាកស្រុកពីប្រទេសកម្ពុជា ឡាវ និងវៀតណាមចំនួន ១៨០០ នាក់ដែលទើបត្រឡប់មកពីធ្វើការនៅប្រទេសថៃ និងម៉ាឡេស៊ីបានបង្ហាញថា ៩៣ ភាគរយនៃពួកគេបានសម្រេចចិត្តទៅធ្វើការនៅក្រៅស្រុក គឺចង់ផ្ញើលុយមកផ្ទះវិញ ដោយសារតម្រូវការជីវភាពប្រចាំគ្រួសារខ្លាំងជំពាក់បំណុលគេ កូនរៀន សន្សំលុយ និងទុកជួយសមាជិកគ្រួសារ។ អ៊ីចឹងហើយបានជាទៅមើលតាមភូមិនៅស្រុកខ្មែរ ឡើងស្ងាត់ភូមិសល់តែយាយតានៅមើលចៅគឺមនុស្សពេញវ័យធ្វើចំណាកស្រុកទៅធ្វើការនៅបរទេសទាំងមានឯកសារផ្លូវច្បាប់ និងមិនមានឯកសារអ្វីសោះក៏ទៅដែរ។ គ្រាន់តែទិន្នន័យពលករខ្មែរនៅប្រទេសថៃប្រមាណជាង ១ លាន ៧ ម៉ឺននាក់កំពុងធ្វើការស្របច្បាប់នៅទីនោះដែលអន្តរក្រសួងរវាងប្រទេសកម្ពុជា និងថៃបានចុះទៅផ្តល់ឯកសារស្របច្បាប់ដល់ពលរដ្ឋទាំងនោះថ្មីៗផងដែរ។ តែទោះបីជាយ៉ាងណាក៏នៅមានពលរដ្ឋខុសច្បាប់ដែលចាញ់បោកមេខ្យល់ធ្វើការអត់មានឯកសារត្រូវអាជ្ញាធរថៃចាប់បញ្ជូនមកវិញជារៀងរាល់ខែប្រមាណ ៥ ពាន់នាក់។ នេះបើតាមរបាយការណ៍របស់ក្រសួងការងារ។

តាមរយៈចំណាកស្រុកនេះក៏មានពលករខ្មែរមួយចំនួនត្រូវបានគេជួញដូរលក់ពីកន្លែងមួយទៅកន្លែងមួយពីប្រទេសមួយទៅប្រទេសមួយទៀត។ បើតាមការសិក្សាស្រាវជ្រាវបែបលឿន (Rapid Survey, 2010) នៃគម្រោងការអន្តរភ្នាក់ងាររបស់ អ.ស.ប ស្តីពីបញ្ហាជួញដូរមនុស្ស (UNIAP) ធ្វើការសម្ភាសពលករខ្មែរធ្វើការមិនមានក្រដាសស្នាមដែលត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកស្រុកខ្មែរវិញនៅច្រកប៉ោយប៉ែតព្រំដែនខ្មែរ-ថៃបានបង្ហាញថា ១ ភាគ ៤ នៃចំនួនសរុប ៤០០ នាក់គឺជាជនរងគ្រោះដោយសារការជួញដូរ និង ១ ភាគ ៣ នៃពួកគេដែលផ្តល់សម្ភាសឲ្យដឹងថា ពួកគេធ្លាក់ខ្លួនក្លាយជាជនរងគ្រោះ ដោយបានត្អូញត្អែរពីបញ្ហាធ្ងន់ធ្ងរនៅក្រៅប្រទេស។

តែបើមើលទៅលើរបាយការណ៍ប្រឆាំងនឹងការទប់ស្កាត់ការជួញដូរមនុស្សនៅស្រុកខ្មែរមានភាពផ្សេងៗគ្នាទៅតាមស្ថាប័ន បើលទ្ធផលបូកសរុបរបស់រដ្ឋាភិបាលគឺក្រសួងមហាផ្ទៃនិយាយអំពីការចាប់ជនល្មើស រំដោះជនរងគ្រោះ និងការអនុវត្តទៅតាមនីតិវិធីច្បាប់។ អគ្គស្នងការដ្ឋាននគរបាលជាតិបានបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទបានចំនួន ១៥៩ ករណីនៅក្នុងឆ្នាំ ២០១៧ កន្លងទៅបើធៀបនឹងឆ្នាំ ២០១៦ គឺមានការកើនឡើង ៦៧ ករណី រំដោះជនរងគ្រោះដែលសង្គ្រោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន ៣៤៥ នាក់។

បើតាមរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០១៧ និងទិសដៅអនុវត្តឆ្នាំ ២០១៨ របស់គណៈកម្មការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សគឺបានបង្ហាញលម្អិតអំពីសកម្មភាពរបស់ការងារអន្តរក្រសួងពាក់ព័ន្ធទាំងបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ អង្គការដៃគូ និងបណ្តាក្រុមហ៊ុនឯកជនស្រប

ច្បាប់ក្នុងការចូលរួមទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស។ តែទោះយ៉ាងណាក៏របាយការណ៍នេះបានបង្ហាញពីការប្រឈម និងខ្វះខាតផងដែរ ជាពិសេសរឿងថវិកាតាមស្ថាប័នសម្រាប់ការគាំពារជនរងគ្រោះដោយសារជួញដូរផងដែរ។

តែបើមើលតាមរបាយការណ៍របស់បណ្តាអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការតាមដានករណីជួញដូរមនុស្សវិញ គឺបានបង្ហាញជាករណីៗដែលលម្អិតទៅជនរងគ្រោះដោយសារចាញ់បោកគេយកទៅលក់តាមរយៈរៀបការទៅស្រុកចិនរងគ្រោះវេទនារងការរំលោភបំពាន និងបាត់បង់នីតិសម្បទា និងករណីជនរងគ្រោះដែលត្រូវគេលក់បន្តមកពីម៉ាឡេស៊ីទៅដល់ហុងកុងចិនកោះតៃវ៉ាន់ ឬក៏ពីធ្វើការពីសមុទ្រថៃត្រូវបានគេលក់ទៅធ្លាក់ដល់ប្រទេសឥណ្ឌាក៏មានដែរ។

បើតាមគម្រោងចំណាយថវិកាជាតិប្រចាំឆ្នាំ ២០១៨ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះថវិកាក្រសួងសង្គមកិច្ចដែលពាក់ព័ន្ធទៅនឹងការធ្វើឲ្យប្រសើរឡើងនូវមជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះដោយសារការជួញដូរដែលមានចែងក្នុងខ្ទង់ចំណាយនៅក្នុងអនុកម្មវិធីទី ១៖ ដែលលើកឡើងសម្រាប់ចំណាយការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងសម្រាប់ជនងាយរងគ្រោះ និងកិច្ចការគ្រួសារ និងអនុកម្មវិធីទី ២៖ អភិវឌ្ឍន៍សុខុមាលភាពកុមារ និងយុវនីតិសម្បទាសរុបបានតែ ១៥៧៨៣ លានរៀល (ប្រមាណជា ៤ លានដុល្លារតែប៉ុណ្ណោះ) ក្នុង ១ ឆ្នាំ។ ដូច្នេះថវិកានេះមានតិចតួចណាស់សម្រាប់បម្រើការនៅមន្ទីរសង្គមកិច្ចតាមខេត្ត និងរាជធានីនៅកន្លែងផ្តល់សេវាដែលជា (មណ្ឌលស្តារនីតិសម្បទា) និងការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ដូចដែលមានចែងនៅក្នុងប្រព័ន្ធបញ្ជូននៃគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របឆ្នាំ ២០១៥ និងគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារជនរងគ្រោះដោយសារអំពើជួញដូរមនុស្សឆ្នាំ ២០០៩។

ដោយសារមានការខ្វះខាតថវិកាជាតិនេះហើយបានជានៅក្នុងគោលការណ៍ណែនាំនេះត្រូវការជំនួយពីអង្គការដៃគូដើម្បីឲ្យដំណើរការបានដូចជាមណ្ឌលស្តារនីតិសម្បទាដែលរួមមានសេវាផ្តល់ប្រឹក្សា សេវាសុខាភិបាល សេវាគាំទ្រផ្លូវច្បាប់ សេវាស្តារនីតិសម្បទា សេវាអប់រំ សេវាជំនាញវិជ្ជាជីវៈជាដើម។ តែបើអស់ជំនួយសេវាទាំងនេះក៏បាត់ទៅវិញដែរពោលគឺមិនមាននិរន្តរភាពនោះទេ។ ហេតុដូច្នេះហើយទាំងគោលនយោបាយចាស់ និងគោលការណ៍ថ្មីនេះគួរតែកែសម្រួលឲ្យបានប្រសើរឡើងដោយមានភាពជាម្ចាស់ការក្នុងការដោះស្រាយចំពោះការស្តារនីតិសម្បទាចំពោះជនរងគ្រោះដោយសារអំពើជួញដូរនេះគឺមានន័យថារដ្ឋគួរតែដំឡើងថវិកាជាតិ និងកាត់បន្ថយថវិកាជំនួយពីអង្គការដៃគូដើម្បីឲ្យមាននិរន្តរភាព និងភាពជាម្ចាស់ប្រទេសរបស់ខ្លួនព្រោះពឹងលើថវិកាអង្គការគឺមិនស្ថិតស្ថេរនោះទេ។ លើសពីនេះរាជរដ្ឋាភិបាលគួរតែបង្កើនខ្ទង់ចំណាយ និងបង្កើតបន្ថែមមជ្ឈមណ្ឌលស្តារនីតិសម្បទាពេញលេញទាំងនៅភ្នំពេញ និងបណ្តាខេត្តនានាសម្រាប់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងផ្លូវភេទឲ្យដូចការយកចិត្តទុកដាក់ការគិតគូរពីគុកតូចចង្អៀតសម្រាប់អ្នកទោសដែលប្រព្រឹត្តបទល្មើស។ មិនតែប៉ុណ្ណោះរដ្ឋក៏កំពុងតែសាងសង់ពន្ធនាគារបំពាក់ឧបករណ៍ទំនើបៗសម្រាប់អ្នកទោសអ្នកមានៗ ដែលយកគំរូពីប្រទេសជឿនលឿនដូចនៅសហរដ្ឋអាមេរិក អូស្ត្រាលី និងនូវែលសេឡង់ទៀតផង៕

## ស្ត្រីពពោះជំនួស ១៥ នាក់ត្រូវបានដោះលែង តែត្រូវចិញ្ចឹមកូន

https://www.postkhmer.com/ គង់ មេត្តា | Publication date 06 December 2018 | 10:07 ICT

ភ្នំពេញៈ ស្ត្រី ១៥ នាក់ដែលពាក់ព័ន្ធនឹងរឿងស៊ីឈ្នួលពពោះជំនួសត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយភ្ជាប់នឹងការសន្យាចិញ្ចឹមកូន ក្រោយពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សស្នើទៅ

តុលាការឲ្យពិចារណាដោះលែង ខណៈពួកគេបានសម្រាលកូនរួចជាអ្វីដែលមន្ត្រីសិទ្ធិមនុស្សស្វាគមន៍ តែចង់ឱ្យមានច្បាប់។

យោងតាមបុរសអ្នកយាមនៅមន្ទីរពេទ្យ ១៦ ឧសភាម្នាក់សុំមិនបញ្ចេញឈ្មោះ បានប្រាប់ថាគិតមកត្រឹមថ្ងៃ ៤ ធ្នូ មានស្ត្រីមានផ្ទៃពោះប្រមាណ ១៧ នាក់កំពុងនៅមន្ទីរពេទ្យក្នុងនោះមាន ១៥ នាក់បានសម្រាលកូនរួចហើយត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យដែល ៤ នាក់ត្រូវបានបញ្ជូនចេញកាលពីសប្តាហ៍មុន រីឯ១១នាក់ត្រូវបានដោះលែងកាលពីថ្ងៃចន្ទដើមសប្តាហ៍នេះ។ លោកថា៖ «ខ្ញុំគិតថាអាទិត្យក្រោយគេនឹងដោះលែងទាំងអស់ហើយ ខ្ញុំជិតបានទៅធ្វើការនៅកន្លែងដើមវិញហើយ»។

លោក សួស វិទ្យារ៉ាន់ឌី អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញមិនអាចទាក់ទងដើម្បីសុំការបកស្រាយពីករណីនេះបានទេ កាលពីម្សិលមិញ។

ស្ត្រីពពោះម្នាក់ក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះបានថ្លែងកាលពីម្សិលមិញថា ខ្លួនត្រូវបានគេឱ្យចុះកិច្ចសន្យាថានឹងត្រូវចិញ្ចឹមកូនជាមួយនឹងការអនុញ្ញាតឲ្យមានសេរីភាពបណ្តោះអាសន្ន និងត្រូវចិញ្ចឹមកូនរហូតដល់អាយុ ១៨ ឆ្នាំ ខណៈកូនប្រុសគាត់ទើបមានអាយុត្រឹមតែជាង ៣ ខែ។ អ្នកស្រីបានបញ្ជាក់ថា៖ «គេឱ្យយើងធ្វើកិច្ចសន្យាចុះហត្ថលេខាថា ទាល់តែចិញ្ចឹមកូនហ្នឹងទើបបានចេញ។ ប្រសិនបើបាត់កូនហ្នឹង ខ្ញុំនឹងត្រូវបញ្ជូនទៅគុកព្រៃសហើយ ។...ជីវិតពួកខ្ញុំគឺនៅនឹងកូន ហើយពួកខ្ញុំត្រូវចិញ្ចឹមកូនជាការដោះដូរ ទាល់តែគាត់អាយុ ១៨ ឆ្នាំ ហើយគេនឹងតាមត្រួតពិនិត្យយើង។ ប៉ុន្តែក្នុងចិត្តខ្ញុំ ខ្ញុំពិតជាស្រឡាញ់គាត់មែន ហើយអាណិតថែមទៀត ខ្ញុំទុកចិញ្ចឹមខ្លួនឯង»។ អ្នកស្រីបានបន្តថា ៖ «ពេលគេប្រាប់ខ្ញុំកាលពីល្ងាចថ្ងៃចន្ទ ខណៈខ្ញុំកំពុងអង្គុយមើលកូន ខ្ញុំអរសឹងងាប់ទៅហើយ គេយកពួកយើងទៅសម្រាកនៅអង្គការបាន ១ យប់»។ ខ្ញុំបានមកដល់ផ្ទះហើយ ខ្ញុំមានអារម្មណ៍សប្បាយចិត្ត កូនខ្ញុំឥឡូវមានអាយុជាង ៣ ខែហើយ។ ខ្ញុំបានមកដល់ផ្ទះខ្ញុំតាំងពីថ្ងៃរសៀល»។

បុរសជាប្តីស្ត្រីពពោះជំនួសម្នាក់សុំមិនបញ្ចេញឈ្មោះបានថ្លែងដែរថា ប្រពន្ធលោកទើបមានទម្ងន់ ៧ ខែដែលជាកូនពពោះជំនួស ប៉ុន្តែលោករីករាយ ខណៈដឹងថាភរិយានឹងត្រូវគេដោះលែងវិញ បន្ទាប់ពីឃាត់ខ្លួន។ បុរសវ័យ ២៧ ឆ្នាំរូបនេះបញ្ជាក់ថា៖ «ខ្ញុំឮគេថា អាទិត្យក្រោយគេនឹងដោះលែងគាត់ហើយ។ ខ្ញុំនឹកគាត់ខ្លាំងណាស់។ ខ្ញុំសប្បាយចិត្តណាស់។ កូនសស្អាតគួរឱ្យស្រឡាញ់។ មេធាវីឱ្យចុះហត្ថលេខាប្រហែលជាមួយខែមុន គាត់ប្រាប់ថាកុំឱ្យធ្វើអំពើអ៊ីចឹងទៀត។ ខ្ញុំអត់បានអានក្រដាសហ្នឹងទេ។ ខ្ញុំនឹងទុកកូនហ្នឹងយកមកផ្ទះទាក់ទងនឹងឪពុកម្តាយបង្កើតវាជារឿងរបស់គេទេ។ គេបានហៅយើងឱ្យទៅផ្តិតមេដៃជានា។ ការឱ្យយើងនៅក្រៅឃុំហ្នឹង ខ្ញុំគិតថា ប្រហែលអ៊ីចឹងហើយ ដែលយើងត្រូវចិញ្ចឹមកូន»។

កាលពីថ្ងៃទី ២២ ខែមិថុនាឆ្នាំនេះសមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីពពោះជំនួស ៣២ នាក់ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ហើយសមត្ថកិច្ចបានបញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាលក្នុងនាមជាជនរងគ្រោះ ប៉ុន្តែនៅទីបំផុតពួកគេត្រូវបានចោទប្រកាន់ និងឃុំខ្លួនមុនការជំនុំជម្រះដោយចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញកាលពីខែកក្កដា ក្រោមការចោទប្រកាន់ពីបទប៉ុនប៉ងលក់ ទិញ ឬដោះដូរមនុស្សសម្រាប់ការផ្ទេរឆ្លងព្រំដែន និងប្រព្រឹត្តជាលក្ខណៈអន្តរការីរវាងឪពុក ម្តាយសុំកូន និងស្ត្រីពពោះជំនួសតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។

កាលពីចុងខែតុលាឆ្នាំនេះលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សធ្លាប់បានឲ្យដឹងថា មេធាវីការពារឲ្យស្ត្រីពពោះទាំង ៣២ នាក់បានរៀបចំឯកសារដាក់ទៅតុលាការដើម្បីស្នើសុំឲ្យតុលាការពិចារណាដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដើម្បីឲ្យពួក

គេបានចិញ្ចឹមកូនៗដែលពួកគេស៊ីឈ្នួលបង្កើតឲ្យអ្នកផ្សេងនោះ ដោយពួកគេមិនបញ្ជូនកូនទាំងនោះទៅឲ្យអ្នកជួលពួកគេឡើយ។ លោកស្រី ជូ ប៊ុនអេង កាលពីម្សិលមិញមិនអាចទាក់ទង ដើម្បីសុំធ្វើអត្ថាធិប្បាយបន្ថែមបានទេ។

លោកស្រី ធីតា ឃឹះ ជានាយិកាប្រតិបត្តិអង្គការសីលកាបានស្វាគមន៍ចំពោះការដោះលែងស្ត្រីក៏ដូចជា កុមារឱ្យបាននៅក្រៅឃុំនេះ។ ប៉ុន្តែលោកស្រីបានស្នើឱ្យមានការស្រាវជ្រាវច្បាស់លាស់ពាក់ព័ន្ធករណីនេះ និងបានគាំទ្រឱ្យបង្កើតច្បាប់ឱ្យបានតឹងរ៉ឹងដើម្បីចៀសវាងកើតករណីនេះនៅថ្ងៃអនាគតទៀត។ លោកស្រីបានបញ្ជាក់ថា៖ «នេះគឺជារឿងមួយចម្រូងចម្រាសណាស់ដែលថា បច្ចេកទេស និងសេចក្តីត្រូវការរបស់អ្នកនៅខាងក្រៅ និងអ្នករកស៊ីវាលឿនជាងច្បាប់របស់អ្នកនៅក្នុងស្រុកយើង។ អ៊ីចឹងទៅប្រសិនបើមិនស្រាវជ្រាវឱ្យច្បាស់ យើងអាចសម្រេចចិត្តខុសច្រើន»។ ទោះបីជាយ៉ាងណាក្តីលោកស្រីយល់ថាជាការលំបាកចំពោះអ្នកមានតម្រូវការ និងអ្នកត្រូវការចំណូលបានពីសកម្មភាពនេះ។ លោកស្រី ធីតា ឃឹះ បន្ថែមថា៖ «ខ្ញុំគិតថា វាជារឿងលំបាកនៅក្នុងករណីអស់ហ្នឹង វាជាករណីដែលអ្នករកស៊ីមានសេចក្តីត្រូវការអ្នកមានលុយ និងពលរដ្ឋយើងដែលត្រូវការលុយ វាជាការលំបាកក្នុងការសម្រេចចិត្តពីរឿងនេះ...អ៊ីចឹងក្នុងករណីហ្នឹងកូនគួរតែឱ្យទៅឪម៉ែគេវិញ ហើយចាំដាក់ច្បាប់កុំឲ្យធ្វើក្នុងករណីនេះគឺស្ត្រី និងទារកជាអ្នកទទួលរងគ្រោះ។ យើងត្រូវធ្វើច្បាប់»៕

## របាយការណ៍: ករណីកម្មករក្រោមអាយុក្នុងវិស័យកាត់ដេរធ្លាក់ចុះ

https://www.postkhmer.com/ គង់ មេត្តា | Publication date 06 December 2018 | 08:57 ICT

ភ្នំពេញៈ តាមសេចក្តីថ្លែងការណ៍ប្រចាំឆ្នាំរបស់គម្រោងរោងចក្រកាន់តែប្រសើរ នៅកម្ពុជា (BFC) បានកត់សម្គាល់ឃើញថា ករណីកម្មករក្រោមអាយុនៅក្នុងវិស័យកាត់ដេរបានបង្ហាញការធ្លាក់ចុះយ៉ាងខ្លាំងពី ៧៤ ករណីក្នុងឆ្នាំ ២០១៤ ដល់ ១០ ករណីនៅក្នុងរបាយការណ៍បច្ចុប្បន្ន។ ការធ្លាក់ចុះនេះ គឺជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធស្តីពីពិធីសារពលកម្មកុមាររវាងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា។ សេចក្តីថ្លែងការណ៍បញ្ជាក់ថា៖ «យើងមានសេចក្តីសោមនស្សរីករាយដោយកត់សម្គាល់ថា ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការនេះក៏ត្រូវបានទទួលស្គាល់ផងដែរដោយគណៈកម្មាធិការនៃអ្នកជំនាញ ស្តីពីការអនុវត្តស្តង់ដាររបស់អង្គការអន្តរជាតិខាងការងារ (ILO) នៅក្នុងរបាយការណ៍ឆ្នាំ ២០១៨ របស់ខ្លួន»។ សេចក្តីថ្លែងការណ៍បន្តថា៖ «ខណៈយើងកត់សម្គាល់ភាពរីកចម្រើនយ៉ាងច្រើនចំពោះលក្ខខណ្ឌការងារនៅក្នុងរយៈកាល ១ ទសវត្សរ៍ចុងក្រោយក្នុងប្រទេសកម្ពុជា យើងទទួលស្គាល់ថា កិច្ចខិតខំប្រឹងប្រែងជាបន្តគឺជាភាពចាំបាច់នៅក្នុងការគាំទ្រវប្បធម៌អនុលោមភាពក្នុងវិស័យកាត់ដេរនៅកម្ពុជា»។ សេចក្តីថ្លែងការណ៍ដដែលបន្តថា ភាពជាដៃគូត្រីភាគីរវាងអង្គការអន្តរជាតិខាងការងារព្រមទាំងអ្នកបញ្ជាទិញនិងរោងចក្រដែលផ្តោតលើដំណោះស្រាយចីរភាពគឺជាភាពចាំបាច់ដើម្បីធានាឲ្យមានភាពប្រសើរឡើងរយៈពេលវែង។

ប៉ុន្តែរបាយការណ៍របស់គម្រោងរោងចក្រកាន់តែប្រសើរក៏បង្ហាញថា មានការកើនឡើងក្នុងករណីពលករកុមារដែលមានអាយុក្រោម១៥ឆ្នាំ នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ហើយលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅតែជាបញ្ហាប្រឈមចំពោះកម្មករធ្វើការនៅក្នុងរោងចក្រតាមរយៈការស្ទង់មតិរបស់គម្រោងរោងចក្រកាន់តែប្រសើរ។ តាមរបាយការណ៍ឲ្យដឹងថាចាប់ពីខែឧសភា ឆ្នាំ ២០១៧ ដល់ ខែមិថុនា ឆ្នាំ ២០១៨ មានករណីប្រើប្រាស់ពលករកុមារក្រោមអាយុមានចំនួន ១០ ករណីក្នុងនោះមាន ២ ករណីកើតឡើងក្នុងរោងចក្រស្បែកជើង ហើយមាន ៨ ករណីទៀតបានកើតឡើងក្នុងរោងចក្រកាត់ដេរ។ របាយការណ៍បានបង្ហាញថា៖ «អង្គការបានរកឃើញចំនួនពលករក្រោមអាយុ ១៥ ឆ្នាំមានចំនួន ១០ ករណីដែលក្នុងនោះពលករសុទ្ធតែជាកុមារីក្នុងនោះមាន ៤ ករណីបានទទួលស្គាល់ដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងគម្រោងរោងចក្រកាន់តែប្រសើរ និងបានបញ្ជូន

ឲ្យទៅបណ្តុះបណ្តាលនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្រសួង»។ របាយការណ៍បន្ថែមថា៖ «មានចំនួន ៨៥ ភាគរយ (៣៩៤ រោងចក្រ) មិនមានបំពាក់បរិក្ខារពេទ្យគ្រប់គ្រាន់ និងបុគ្គលិកពេទ្យទេ នៅពេលរោងចក្រមួយមានកម្មករចាប់ពី ៥០ នាក់ឡើងទៅរោងចក្រត្រូវមានបំពាក់បរិក្ខារពេទ្យគ្រប់គ្រាន់ហើយត្រូវតែនៅក្បែរកម្មករធ្វើការងាយស្រួលក្នុងការចេញ-ចូលមានខ្យល់ចេញចូលល្អ មិនមានសំឡេងរំខានផ្តល់ភាពងាយស្រួយដល់កម្មករស្រីមានចំនួនវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាគ្រប់គ្រាន់ ដោយផ្អែកទៅលើចំនួនកម្មករ និងមានគ្រឿងបរិក្ខារគ្រប់គ្រាន់ និងការផ្គត់ផ្គង់»។

លោក យុន ថារ៉ូ អ្នកសម្របសម្រួលរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ថ្លែងថាពលកម្មកុមារមានការរីករាលដាលខ្លាំងនៅកម្ពុជា ហើយមានការរីករាលដាលគ្រប់វិស័យតាំងពីវិស័យសេវាកម្មរហូតដល់វិស័យសំណង់។

ទោះយ៉ាងណាក្តីមានឪពុកម្តាយខ្លះបានជំរុញកូនមិនគ្រប់អាយុរបស់ពួកគេ ដែលបានបោះបង់ការសិក្សាឲ្យទៅធ្វើការនៅតាមរោងចក្រ ដោយសារត្រូវការចំណូល។ ឪពុកម្តាយខ្លះក្លែងបន្លំអត្តសញ្ញាណដើម្បីបង្ហាញថា កូនខ្លួនគ្រប់អាយុដែលអាចធ្វើការបាន ហើយករណីនេះធ្វើឲ្យរោងចក្រត្អូញថាពួកគេទៅវិញទេ ជាជនរងគ្រោះ៕

## បង្ក្រាបកន្លែងរកស៊ីសេវាផ្លូវភេទជ្រកក្រោមផ្លាក ទីតាំងម៉ាស្សាមួយកន្លែង នៅសៀមរាប

http://www.arey-news.com/ (ថ្ងៃទី 06 December 2018 ម៉ោង 9:00 am)

សៀមរាប៖ តាមប្រសាសន៍របស់លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានប្រាប់ឲ្យដឹងថា មុនកម្លាំងធ្វើសកម្មភាព កម្លាំងជំនាញបានចុះស្រាវជ្រាវរហូតឈានដល់ការឃាត់ខ្លួនបានថៅកែហាងម៉ាស្សាម្នាក់ឈ្មោះ ហ៊ុន ចាន់សេន ភេទស្រី អាយុ៣២ឆ្នាំ បានឃាត់ខ្លួនបានបញ្ជាលោក កើត វណ្ណារេត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប ព្រមទាំងស្ត្រីរកស៊ីផ្លូវភេទបានចំនួន៥នាក់ផងដែរ។

យោងតាមផេក ផ្សព្វផ្សាយអប់រំក្រសួងមហាផ្ទៃ បានឲ្យដឹងថា នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានចុះបង្ក្រាបកន្លែងរកស៊ីផ្លូវភេទដែលជ្រកក្រោមផ្លាកទីតាំងម៉ាស្សាឃីហោ៨៩៨៩ ក្នុងភូមិខ្នា សង្កាត់ជ្រាច ក្រុមសៀមរាប ខេត្តសៀមរាប។ ក្រោយពីការឃាត់ខ្លួនថៅកែ ម៉ាស្សារួច កម្លាំងជំនាញបានរៀបចំបញ្ជូនស្ត្រីរកស៊ីផ្លូវភេទទាំង៥នាក់ទៅមន្ទីរសង្គមកិច្ចខេត្តដើម្បីអប់រំកែប្រែ និងផ្តល់ជំនាញផ្សេងៗដែលពួកគាត់អាចទទួលយកបានផងដែរ៕

# ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨

## មន្ត្រីជាន់ខ្ពស់នគរបាលជាតិជួបអង្គការ IOM

http://cambodiapolice.com/policekh/ 5:00 pm 6 ធ្នូ 2018

(បាត់ដំបង)៖ អគ្គស្នងការរងនគរបាលជាតិ នាយឧត្តមសេនីយ៍ ហ៊ូ សាគុណ ដែលជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន បានជួបពិភាក្សាការងារជាមួយប្រធានគំរោងអង្គការ IOM លោក Breft Dickson និងសហការី ៧រូប ដើម្បីពិភាក្សាស្វែងយល់អំពីលំហូរចំណាកស្រុករបស់ប្រជាពលរដ្ឋខ្មែរប្រចាំថ្ងៃនៅច្រកតំបន់អូរអន្លក់ និងច្រកតំបន់ អូរវំដួល ព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តបាត់ដំបង។ អង្គការ IOM International Organization for Migrant គឺជាអង្គការអន្តរជាតិពិនិត្យអ្នកធ្វើចំណាកស្រុក។

ជំនួបដែលបានធ្វើកាលពីថ្ងៃទី៣ធ្នូឆ្នាំ២០១៨ បានចូលរួមពីមេបញ្ជាការរងនគរបាលជាតិប្រចាំទិសភូមិភាគទី៥. ស្នងការរងនគរបាលខេត្តបាត់ដំបង, មេបញ្ជាការវរៈ៨១៩ និងប្រធានច្រកទ្វារតំបន់ព្រំដែនផងដែរ។ នាយឧត្តមសេនីយ៍ហ៊ូ សាគុណ បានថ្លែងថាក្នុងជំនួបនោះ គឺអង្គការ IOM ចង់សិក្សាស្រាវជ្រាវអំពីទិន្នន័យរបស់ប្រជាពលរដ្ឋខ្មែរ

ឆ្លងដែនប្រចាំថ្ងៃពិតប្រាកដ ហើយនឹងប្រព័ន្ធគ្រប់គ្រងទិន្ន័យ ព្រមទាំងបច្ចេកទេសសំរាប់ត្រួតពិនិត្យការចេញ-ចូលរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែននាពលបច្ចុប្បន្ន ។ នាយឧត្តមសេនីយ៍ ហ៊ូសាគុណ បានថ្លែងថាកិច្ចពិភាក្សាបានផ្តោតលើការធ្វើ ចំណាកស្រុករបស់ពលរដ្ឋខ្មែរ នៅ ច្រកតំបន់អូរអន្លក់ និងច្រកតំបន់អូរជ្រៃដួល។ លោកបានរាយការណ៍ថា មានលំហូរចំណាកស្រុករបស់ប្រជាពល រដ្ឋនៅទីនោះ មានចំនួន០៤ប្រភេទរួមមាន៖ ពលករទៅធ្វើការព្រឹកនិងវិលវិញល្ងាចជាមួយនឹងលិខិតឆ្លងកាត់ព្រំ ដែនឬ Border pass, ប្រជាពលរដ្ឋទៅទិញ ទំនិញនៅផ្សារថៃ, ជនជាតិថៃនិងខ្មែរធ្វើដំណើរទៅវិញទៅមកក្នុង ការផ្លាស់ប្តូរទំនិញឬធ្វើទេសចរណ៍, ការធ្វើ ដំណើរទៅពិនិត្យសុខភាពឬដំណើរទេសចរណ៍។

ក្រោយជំនួបស្វែងយល់អំពីចំណាកស្រុក ក្រុមការងារបានបន្តចុះទៅពិនិត្យដល់ទីតាំងប៉ុស្តិ៍ទាំងពីរនៅ តាមបណ្តោយព្រំដែន។ នាយឧត្តមសេនីយ៍ហ៊ូ សាគុណ បានថ្លែងថាក្រោយការពិភាក្សានិងពិនិត្យលើករណីចំណាក ស្រុកតាមបណ្តោយព្រំដែនរួច ភាគីកម្ពុជាបានសំណូមពរដល់អង្គការ IOM នូវមធ្យោបាយមួយចំនួន ក្នុងនោះរួម មានការស្នើជួយឧបត្ថម្ភសម្ភារៈបច្ចេកទេស និងការបន្តជួយបណ្តុះបណ្តាលដល់នគរបាលការពារព្រំដែនទាក់ ទងនឹងការគ្រប់គ្រងសន្តិសុខតាមព្រំដែន។ នៅក្នុងកិច្ចពិភាក្សានោះផងដែរ ភាគី IOM បានបញ្ជាក់ថាក្នុង គម្រោងទី២របស់ប្រទេសកាណាដាIOM នឹងជួយសិក្សាអំពីការកត់ត្រាទិន្ន័យលំហូរពលករឆ្លងកាត់ព្រំដែនតាមកម្មវិធីExcel និងគំរូសៀវភៅកត់ត្រាដែលកំពុងសហការជាមួយបណ្ឌិតសភាកម្ពុជាដើម្បីទៅបណ្តុះបណ្តាលមន្ត្រីនៅតាមច្រកទ្វារព្រំដែន ៕

## ថៃបញ្ជូនពលរដ្ឋខ្មែរ៧នាក់មកកម្ពុជាវិញតាមច្រកអានសេះ

http://www.rasmeinews.com/ December 6, 2018, 4:54 PM

ដោយៈសៅវ៉ាន់ឌី/ព្រះវិហារ៖ កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨ អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន៧នាក់ មកឱ្យអាជ្ញាធរកម្ពុជាវិញ ដែលអាជ្ញាធរថៃចាប់ឃុំឃាំងរយៈពេល២ឆ្នាំពីបទឆ្លងដែនខុសច្បាប់ចូលទៅកាប់ឈើគ្រញូង នៅក្នុងទឹកដីថៃតាមច្រកអានសេះ ស្ថិតនៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

មន្ត្រីទំនាក់ទំនងព្រំដែនច្រកតំបន់អានសេះបានឱ្យនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨នេះថា ជាពលរដ្ឋ ខ្មែរទាំង៧នាក់ ត្រូវអាជ្ញាធរថៃចាប់ខ្លួន កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៦កន្លងទៅ ស្ថិតនៅក្នុងភូមិសាស្រ្ត ស្រុកណាំយុន ខេត្តឧប៊ុន ប្រទេសថៃ។ ពីបទលួចឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូង តាមចំណុចព្រលានតាទុំ នៅក្នុងភូមិសាស្រ្ត ភូមិឈើទាលគង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ បើគិតថ្ងៃដែលអាជ្ញាធរថៃធ្វើការដោះលែងមកវិញគឺប្រជាពលរដ្ឋខ្មែរទាំង៧នាក់នេះ ជាប់ឃុំឃាំងក្នុងម្នាក់ៗ២ឆ្នាំមកហើយ។ មន្ត្រីដដែលបានបន្តថា ពលរដ្ឋខ្មែរទាំង៧នាក់នេះ រួមមានទី១៖ ឈ្មោះ សូ រ៉ែន ភេទប្រុស អាយុ៤៤ឆ្នាំ, ទី២៖ ឈ្មោះ កែវ យុទ្ធ ភេទប្រុស អាយុ៣៦ឆ្នាំ, អ្នកទាំង២ នេះ រស់នៅភូមិឈើទាលគង ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ,។ ទី៣៖ ឈ្មោះ ខន ភីអិច ភេទប្រុស អាយុ១៨ឆ្នាំ, ទី៤៖ ឈ្មោះ អៀង ឯក ភេទប្រុស អាយុ២៥ឆ្នាំ,ទី៥៖ ឈ្មោះ យ៉ន រឹមសុខ ភេទប្រុស អាយុ៥៦ឆ្នាំ អ្នកទាំង៣នេះ រស់នៅភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ, ។ទី៦៖ ឈ្មោះ យាង កែន ភេទប្រុស អាយុ២៩ឆ្នាំ និងទី៧៖ ឈ្មោះ ទិត្យ សៀ ភេទប្រុស អាយុ៣៤ឆ្នាំ ឈ្មោះទាំង០២នាក់នេះរស់នៅភូមិសង្កែរ ឃុំសង្កែរ១ ស្រុកឆែប ខេត្តព្រះវិហារ។

បន្ទាប់ពីធ្វើការអប់រំណែនាំរួចសមត្ថកិច្ចទំនាក់ទំនងព្រំដែនច្រកតំបន់អានសេះបានឱ្យវិលត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន ដើម្បីជួបជុំក្រុមគ្រួសារ និងសាច់ញាតិ៕S/

## ចៅក្រមបន្តបើកការស៊ើបសួរ ស្ត្រីពពោះ១១នាក់បន្ទាប់ពីឃុំខ្លួន២១ថ្ងៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៨ ម៉ោង ១៩:១៥ ឃីម ប៊ុនណាក់

រាជធានីភ្នំពេញ ៖ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៦ ខែធ្នូនេះ បានបង្គាប់ទៅអនុរក្សពន្ធនាគារព្រៃស ឲ្យនាំខ្លួនស្ត្រីពពោះជំនួសចំនួន១១នាក់ សាកសួរឡើងវិញនៅក្នុងសំណុំរឿងបទ.លក់ដូរមនុស្សសម្រាប់ឆ្លងដែន និងបទធ្វើអន្តរការីរវាងអ្នកសុំកូនពពោះជំនួស។ ស្ត្រីទាំង១១នាក់នោះត្រូវបានតំណាងអយ្យការធ្វើការចោទប្រកាន់ជាផ្លូវការ និងចៅក្រមស៊ើបសួរ បានសម្រេចឃុំខ្លួនដាក់ពន្ធនាគារជាបណ្ដោះអាសន្ន អស់រយៈពេល២១ថ្ងៃកន្លងមក។

គួរំលឹកថា កាលពីល្ងាចថ្ងៃទី១៥ វិច្ឆិកា ចៅក្រមសើបសួរបានចេញដីកាឃុំស្ត្រីចំនួន១១នាក់ ពីបទ លក់ដូរមនុស្ស សម្រាប់ឆ្លងដែន និងបទធ្វើអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ តាមមាត្រា១៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ។ ជនត្រូវចោទទាំង១១នាក់ ត្រូវបានសមត្ថកិច្ចប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រាជធានីភ្នំពេញ បញ្ជូនទៅកាន់ពន្ធនាគារហើយនាថ្ងៃទី១៦ វិច្ឆិកា ឆ្នាំ២០១៨។

កាលពីថ្ងៃទី១៤ ខែវិច្ឆិកាចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញបានសម្រេចឃុំខ្លួនជន ជាប់ចោទ៤នាក់ពីបទ សមគំនិត ក្នុងអំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន និងធ្វើអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ តាមមាត្រា១៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស មាត្រា២៩ និងមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ ដែលមាន១.ឈ្មោះ ចេង សំអុល ភេទប្រុស ២.ឈ្មោះ អៀង ម៉ាន់ ភេទប្រុស ៣.ឈ្មោះ សុខ ឃឿន ភេទស្រី និង៤.ឈ្មោះ ខៀវ វណ្ណា ភេទស្រី។

ជនជាប់ចោទទាំង១៥នាក់ខាងលើនេះ ត្រូវបានឃាត់ខ្លួន កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងមូលដ្ឋានខណ្ឌសែនសុខ ដោយមានការសម្របសម្រួល ពីលោក គុជ គឹមឡុង ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ បានចុះធ្វើការបង្ក្រាបជាក់ស្ដែង ករណី អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន និងបទអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ នៅចំណុចទីតាំងចំនួន៣កន្លែង ក្នុងមូលដ្ឋានខណ្ឌសែនសុខ។

ជាលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន បានធ្វើការឃាតខ្លួនជនជាប់ចោទចំនួន១៥នាក់ ក្នុងនោះមានអ្នកមើលការខុសត្រូវ(មេការស្រី) ចំនួន២នាក់ អ្នករត់ម៉ូតូកង់បីប្រុសចំនួន២នាក់ ស្ត្រីមានផ្ទៃពោះចំនួន១១នាក់ និង៣នាក់ទៀតរត់គេចខ្លួន។ វត្ថុតាងដកហូតរួមមាន លិខិតឆ្លងដែនចំនួន១ក្បាល ឯកសារពេទ្យមួយចំនួន ស៊ីរ៉ាង និងថ្នាំពេទ្យ (ប្រើរួច និងមិនទាន់ប្រើ)មួយចំនួន និងម៉ូតូកង់បីចំនួន២គ្រឿង៕

## អ្នកទោសវៀតណាម ជាប់ពន្ធនាគារនៅថៃ ស្នើសុំផ្ទេរ មកជាប់ពន្ធនាគារនៅខ្មែរវិញ

https://www.dap-news.com/ ByID:114 Posted on 07 December 2018 | 12:27

ភ្នំពេញ៖ បើតាមសេចក្ដីរាយការណ៍ ពីស្ថានទូតខ្មែរប្រចាំប្រទេសថៃ មានអ្នកទោសជាជនជាតិវៀតណាមកំពុងជាប់ពន្ធនាគារនៅថៃ ប៉ុន្តែបែរជាស្នើសុំផ្ទេរមកជាប់ពន្ធនាគារនៅកម្ពុជាវិញ ខណៈ បច្ចុប្បន្នអ្នកទោសជនជាតិខ្មែរចំនួន ២៩១០នាក់ (ស្ត្រីចំនួន ២៦៩នាក់ បុរសចំនួន ២៦៤១នាក់) កំពុងជាប់ពន្ធនាគារនៅថៃ ។

យោងតាមសេចក្ដីជូនដំណឹង របស់ស្ថានទូតខ្មែរប្រចាំប្រទេសថៃ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨បានឲ្យដឹងថា ស្ថានទូតខ្មែរប្រចាំប្រទេសថៃ បានចុះសួរសុខទុក្ខទណ្ឌិត តាមមន្ទីរឃុំឃាំងជាច្រើនរៀងរហូត។ ចំពោះបញ្ហាផ្ទេរទណ្ឌិត គឺត្រូវអនុវត្តតាមកិច្ចព្រមព្រៀង ស្ដីពី ការផ្លាស់ប្ដូរអ្នកទោស រវាងកម្ពុជា និងថៃ ដែលមានដូចជា៖ ទី១-បទល្មើស ដែល

អាចផ្ទេរអ្នកទោសបានលុះត្រាបទល្មើសនោះ ត្រូវជាប់ពន្ធនាគារចាប់ពីមួយឆ្នាំឡើងទៅ , ២- ទណ្ឌិតដែលអាចផ្ទេរបាន លុះត្រាទណ្ឌិតនោះ ត្រូវជាប់ទោស២/៣ នៃទោសសរុប និងទី៣-ទណ្ឌិតដែលអាចផ្ទេរបាន លុះត្រាសាម៉ីខ្លួនស្នើសុំជាលាយលក្ខអក្សរ ។ សេចក្តីជូនដំណឹងបន្ថែមថា "កន្លងមកមានអ្នកទោសខ្លះ ជាជនជាតិវៀតណាម ហើយសុំផ្ទេរមកជាប់ពន្ធនាគារនៅកម្ពុជា ប៉ុន្តែករណីនេះ ស្ថានទូតមិនអាចដោះស្រាយបានទេ ដូច្នេះស្ថានទូតត្រូវទៅមើលអ្នកទោសនោះថា គាត់សញ្ជាតិអ្វីពិតប្រាកដ ព្រោះស្ថានទូតអាចដោះស្រាយបានលុះត្រា តែអ្នកទោសនោះជាជនជាតិខ្មែរ"។ ប្រភពឲ្យដឹងទៀតថា មានអ្នកទោសខ្លះសុំផ្ទេរ មកជាប់នៅពន្ធនាគារកម្ពុជា ដោយផ្ទាល់មាត់ លុះដល់ស្ថានទូត ឲ្យធ្វើពាក្យស្នើសុំផ្ទាល់ខ្លួន ដើម្បីបញ្ជាក់ថា ខ្លួនស្ម័គ្រចិត្តមកបន្តជាប់ពន្ធនាគារនៅកម្ពុជាវិញ បែរជាគាត់មិនព្រម ធ្វើលិខិតស្នើសុំទាល់តែសោះ។ ស្ថានទូតមិនអាចបង្ខិតបង្ខំទណ្ឌិត ឲ្យផ្ទេរមកកម្ពុជាបានទេ បើសាម៉ីខ្លួនមិនស្ម័គ្រចិត្ត ផ្ទេរមកកម្ពុជា៕
ដោយៈ នឿត សម្ផស្ស

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨

## ជនជាតិចិនចំនួន៩នាក់ត្រូវបានសមត្ថកិច្ចខេត្តសៀមរាបឃាត់ខ្លួនពាក់ព័ន្ធករណីចែកចាយរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ(តាមប្រព័ន្ធអ៊ីនធើណិត)

http://cambodiapolice.com/policekh/ 4:10 pm 9 ធ្នូ 2018

សៀមរាបៈ កាលពីវេលាម៉ោង១០ព្រឹកថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ កម្លាំងការិយាល័យស៊ើបអង្កេតនិងអនុវត្តនីតិវិធី សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងសៀមរាប និងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ស្វាយដង្គំ-សង្កាត់ស្លក្រាម ដឹកនាំសម្របសម្រួលនីតិវិធីដោយលោក ជួន សុបញ្ញា ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប បានចុះបង្រ្កាបករណីចែកចាយរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ(តាមប្រព័ន្ធអ៊ីនធើណិត)នៅក្នុងទីតាំងចំនួន ០៣ទីតាំងផ្សេងគ្នាឃាត់ខ្លួនជនជាតិចិន៩នាក់។

ទីតាំងទី១-ផ្ទះលេខ E២១ បុរីអាក់ខេត ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុង/ខេត្ត សៀមរាប ដោយឃាត់ខ្លួនមនុស្ស០១នាក់ រួមនឹងវត្ថុតាងមួយចំនួន។ ២-ផ្ទះវីឡាជួល ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុង/ខេត្ត សៀមរាប ឃាត់ខ្លួនមនុស្ស ០៥នាក់ រួមនឹងវត្ថុតាងមួយចំនួន។

៣-បន្ទប់លេខ៣០៥ ផ្ទះសំណាក់មហាមាន ភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុង/ខេត្ត សៀមរាប ឃាត់ខ្លួនមនុស្ស ០៣នាក់ រួមនឹងវត្ថុតាងមួយចំនួន។

ជនសង្ស័យទាំង០៩នាក់រួមមានៈ

១-PAN ZHIFU ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ G៤៣៦៧១៥៧៣ ទិដ្ឋាការប្រភេទទេសចរណ៍។ ២-HUANG XINFA ភេទប្រុស កើតឆ្នាំ១៩៩៥ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EE១៦២៤៨០១ ទិដ្ឋាការប្រភេទទេសចរណ៍។ ៣-HUANG FULONG ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EC៧៤០១១៥០ ទិដ្ឋាការប្រភេទEB។ ៤-WEI JIBO ភេទប្រុស កើតឆ្នាំ១៩៩៦ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EE២៦២២៩៨៧ ទិដ្ឋាការប្រភេទទេសចរណ៍។ ៥-GU SHENGFENG ភេទប្រុស កើតឆ្នាំ១៩៩៨ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EE២០២៩២០៥ ទិដ្ឋាការប្រភេទទេសចរណ៍។ ៦-LI WEIMING ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EE២០២៩២០៦ ទិដ្ឋាការប្រភេទទេសចរណ៍។ ៧-PAN XIADONG ភេទ ប្រុស កើតឆ្នាំ ១៩៨៧ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EC២៣០៣៦២១ ទិដ្ឋាការប្រភេទទេសចរណ៍។ ៨-PAN ZONGJI ភេទប្រុស កើតឆ្នាំ១៩៨២ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខED១៦៦៧២០៥ ទិដ្ឋាការប្រភេទEI។ ៩-

DAI GUANGQIANG ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ EE៦៣៦៩៥៨៤ ទិដ្ឋាការប្រភេទ EI។

បច្ចុប្បន្នជនសង្ស័យទាំង០៩នាក់ ត្រូវបានលោក ជួន សុបញ្ញា ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប សម្រេចឲ្យឃាត់ខ្លួនបណ្ដោះអាសន្ននៅស្នងការដ្ឋាននគរបាលខេត្តសៀមរាបដើម្បីរៀបចំកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តសៀមរាបដើម្បីចាត់ការបន្តតាមនីតិវិធី ៕

## ស្ត្រីម្នាក់នេះមិនធម្មតាទេ.. នារីមិនតិចជាង៣០នាក់រងគ្រោះព្រោះតែគាត់

https://www.khmerload.com/news/ 16:14 December 09, 2018

ខេត្តក្រចេះ ៖ ស្ត្រីជាមេខ្យល់ក្នុងអំពើជួញដូរមនុស្សខុសច្បាប់ឲ្យទៅធ្វើការនៅក្រៅ ប្រទេសម្នាក់ទៀត ត្រូវបានតុលាការឃុំខេត្តក្រចេះ សម្រេចចេញដីកាឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគារខេត្ត ក្រោមបទ ចោទ ប្រកាន់ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លង ដែន។ ស្ត្រីជាខ្យល់ក្នុងអំពើជួញដូរមនុស្សអតីតធ្លាប់ជាបុគ្គលិកក្រុមហ៊ុននាំពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ដែលត្រូវបានរដ្ឋាភិបាលបញ្ឈប់ក្រុមហ៊ុនមិនឲ្យធ្វើអាជីកម្មនោះឈ្មោះ ផូ មឿន អាយុ៣១ឆ្នាំ រស់នៅខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវបានលោក ញិល ប៊ុនលី ចៅក្រម ស៊ើបសួរនៃសាលាដំបូខេត្តក្រចេះ សម្រេចធ្វើការឃុំខ្លួននៅថ្ងៃទី៨ ខែធ្នូ។

ស្នងការរងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតជនខេត្ត លោកស្រី វរសេនីយ៍ឯក នៅ រតនា បានប្រាប់ឲ្យដឹងថា ស្ត្រីជាមេខ្យល់រូបនេះ ត្រូវកម្លាំងសមត្ថកិច្ចបានស្រាវជ្រាវចាប់ខ្លួននៅរាជធានីភ្នំពេញ។ ហើយការចាប់ខ្លួនស្ត្រីរូបនេះពីកម្លាំងសមត្ថកិច្ច គឺបានធ្វើឡើងទៅតាមពាក្យបណ្ដឹងរបស់ឱពុកម្ដាយក្មេងស្រីរងគ្រោះអាយុ២៧ឆ្នាំម្នាក់រស់នៅឃុំចង្រ្កង់ ស្រុកចិត្របុរី ដែលស្ត្រីរូបនេះបានបោកបញ្ឆោតនាងឲ្យទៅធ្វើការនៅប្រទេសម៉ាឡេស៊ី តាមរយៈក្រុមហ៊ុននាំពលករតាំងពីឆ្នាំ២០១៤ ហើយរហូតមកទល់នឹងពេលនេះត្រូវបានបាត់ដំណឹង។ បើតាមលោកស្រីស្នងការរងបានឲ្យដឹងទៀតថា ក្រោយការចាប់ខ្លួន និងសាកសួរ នគរ បាលជំនាញបានរកឃើញថា ក្រោយបញ្ចប់ការងារពីបុគ្គលិកក្រុមហ៊ុននាំពលករ ដែលរាជរដ្ឋាភិបាលបានបិទមិនឲ្យមានអាជីវកម្ម ស្ត្រីជាមេខ្យល់រូបនេះ និងបក្សពួក២នាក់ផ្សេងទៀតនៅតែបន្តលួចធ្វើជំនួញ ការនាំនារីទៅក្រៅប្រទេសដោយខុសច្បាប់បន្តទៀត។ លោកស្រីបញ្ជាក់ថា មាននារីចំនួនជាង៣០នាក់ដែលត្រូវបានស្ត្រីជាមេខ្យល់រូបនេះ និង បក្សពួកពីរនាក់ដែលគេចខ្លួនបានបោកបញ្ឆោតពួកគេនាំចេញឲ្យទៅធ្វើការនៅប្រទេសម៉ាឡេស៊ីដោយខុសច្បាប់។ នារីដែលរងគ្រោះទាំងចំនួនជាង៣០នាក់ដែលត្រូវបានពួកគេបាននាំយកចេញក្រៅប្រទេស ក្នុងនោះភាគច្រើនមានរស់នៅខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ លោកស្រីវរសេនីយ៍ឯក នៅ រតនា បានអះអាងថា ចំពោះជន២នាក់ប្ដីប្រពន្ធ២នាក់ផ្សេង ទៀតដែលនៅពីក្រោយខ្នងស្ត្រីសង្ស័យលើជំនួញជួញដូរមនុស្សឆ្លងដែននេះ ពេលនេះពួកគេ កំពុងតែគេចខ្លួន ហើយនគរបាលកំពុងតែស្រាវជ្រាវចាប់ខ្លួនផងដែរ៕

## ពលរដ្ឋខ្មែរម្នាក់ ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការផលិតវីដេអូឯកសារ«ម្ដាយខ្ញុំលក់ខ្ញុំ»

https://thmeythmey.com/ 08, Dec 2018 , 5:42 pm

លោក រ៉ាត់ រដ្ឋមុនី ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន តាមសំណើររបស់រដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី ៧ ខែធ្នូ នៅទីក្រុងបាងកក។ អ្នកស្រី ឡុង គីមហ៊ាង ដែលជាភរិយារបស់លោក រដ្ឋមុនី ប្រាប់សារព័ត៌មានថ្មីៗថា ស្វាមីរបស់ខ្លួណត្រូវបានចាប់ខ្លួនត្រូវបានចាប់ខ្លួន ដោយសារពាក់ព័ន្ធនឹងការជួយផលិតវីដេអូឯកសារដែលមានចំណងជើងថា«ម្ដាយខ្ញុំលក់ខ្ញុំ» ឲ្យសារព័ត៌មានRT។ អ្នកស្រី ឡុង គីមហ៊ាង ដែលនៅជាមួយស្វាមីគ្រាដែលអាជ្ញាធរថៃចាប់ខ្លួននោះបានបន្ត

ថា ការចាប់ខ្លួននេះកើតឡើង នៅពេលដែលស្វាមី និងអ្នកស្រី ព្យាយាមស្នើសុំទិដ្ឋាការធ្វើដំណើរទៅប្រទេសហូឡង់។ ពាក់ព័ន្ធនឹងការចាប់ខ្លួននេះ អ្នកស្រី ឡុង គីមហ៊ាង បារម្ភថាប្តីរបស់ខ្លួនអាចប្រឈមនឹងការជាប់ពន្ធនាគារព្រោះតែជួយផលិតវីដេអូឯកសារដែលនិយាយពីការពិតដែលកើតឡើងនៅកម្ពុជា ខណៈអាជ្ញាធរថៃកំពុងរៀបចំនីតិវិធី ដើម្បីបញ្ជូនស្វាមីរបស់ខ្លួនមកកម្ពុជាវិញ។ អ្នកស្រី ឡុង គីមហ៊ាង បញ្ជាក់ដូច្នេះ៖«ខ្ញុំជឿថា វីដេអូឯកសារដែលប្តីខ្ញុំជួយផលិតក្នុងនាមជាអ្នកបកប្រែ និងអ្នកសម្ភាសន៍ នោះគឺជារឿងពិត ហើយខ្ញុំបារម្ភថា នៅពេលប្តីខ្ញុំត្រូវបញ្ជូនមកដល់កម្ពុជា គេនឹងដាក់សម្ពាធឲ្យគាត់ឆ្លើយតាមអ្វីដែលគេចង់បាន។ បើគាត់មិនព្រមឆ្លើយតាម គាត់អាចត្រូវជាប់ពន្ធនាគារ»។

ពាក់ព័ន្ធនឹងវីដេអូឯកសារដ៏រសើបនេះ ស្ត្រីជាម្តាយ និងកូនស្រី នៅក្នុងវីដេអូឯកសារនោះក៏ត្រូវបានអាជ្ញាធរប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ហៅទៅសាកសួរផងដែរ។ នៅក្នុងពេលសាកសួរ ពួកគេសារភាពថាបានទទួលប្រាក់២០០ដុល្លារ ជាថ្នូរនឹងការសម្តែងនៅក្នុងវីដេអូឯកសារនោះ។ វាមិនមែនជារឿងពិត ដែលបានកើតឡើងចំពោះពួកគេនោះទេ។ នេះបើតាមកាសែតខ្មែរថាម ដែលបានស្រង់សម្តីលោក កែវ ធា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ។

គួររំឭកថា វីដេអូឯកសារដ៏រសើបដែលមានចំណងជើង«ម្តាយខ្ញុំ លក់ខ្ញុំ» ត្រូវបានផ្សព្វផ្សាយដោយសារព័ត៌មានរុស្ស៊ីធូដេ(RT) កាលពីអំឡុងខែតុលាកន្លងទៅ។ វីដេអូឯកសារនេះនិយាយពី យុវតីកម្ពុជា ត្រូវបានម្តាយលក់ព្រហ្មចារីដោយសារតែមានជីវភាពខ្វះខាត៕

## កាន់លិខិតឆ្លងដែនប្រើទិដ្ឋាការ១៤ថ្ងៃចូលមកប្រទេសថៃ ហើយជួលគេទៅតដោយមិនទៅខ្លួនឯង អាចនឹងក្លាយទៅជាអ្នកទោសដោយមិនដឹងខ្លួន"

https://www.facebook.com/CMT ពលករខ្មែរ ថ្ងៃពុធទី០៦ខែធ្នូ ឆ្នាំ២០១៨

នារីជនជាតិខ្មែរម្នាក់ឈ្មោះ ពៅ វ៉ាន់ណា អាយុ ២៧ឆ្នាំ កាន់លិខិតឆ្លងដែន លេខ N00760894 ត្រូវបានត្រូវកម្លាំងអាជ្ញាធរថៃប្រចាំច្រកអន្តរជាតិខ្លង់ទ្បឹកស្រុកអារញ្ញប្រាថេត ធ្វើចាប់ខ្លួនបន្ទាប់អាជ្ញាធរថៃបានរកឃើញថា នៅលើលិខិតឆ្លងដែនរបស់នាងមានវ៉ែត្រាចេញចូលពីច្រកព្រំដែនឡែមដែលលេខកូដ (B47) តាមកតាមកញ្ញាក់របស់សម្តកិច្ចត្រានេះសម្តកិច្ចមិនបានបើកយកមកប្រើការឡើយ។

តាមការរៀបរាប់នាងបានប្រាប់អាជ្ញាធរថៃអោយដឹងថា នាងបានចូលមកធ្វើការនៅឯទីក្រុងបាងកកប្រទេសថៃរួចហើយមានមេខ្យល់អ្នករត់ឯកសារជាជនជាតខ្មែរ ដោយមិនស្គាល់ឈ្មោះ មកទំនាក់ទំនងនាងទទួលយកលិខិតឆ្លងដែនរបស់នាងទៅវ៉ែត្រា ដើម្បីបន្តសុពលភាពស្នាក់នៅក្នុងប្រទេសថៃបន្តទៀត ដោយមិនចាំបាច់សាមីខ្លួនធ្វើដំណើរទៅជាយដែននោះទេ ដោយគិតថ្លៃសេវាកម្មជាប្រាក់ម្តងចំនួន៣០០០បាត ដោយប្រើពេលវេលាត្រឹមតែ២ថ្ងៃប៉ុណ្ណោះក៏ទទួលបានលិខិតឆ្លងដែនមានស្នាមវ៉ែត្រារបស់សម្តកិច្ចអន្តោប្រវេសន៍ព្រំដែន ដោយនាងមិនដឹងថាជាត្រាក្លែងក្លាយ នាងព្រមទាំងអះអាងទៀតថាមានពលរដ្ឋខ្មែរធ្លាប់ត្រូវក្រុមអ្នករត់ឯកសារពួកនេះបោកអស់ជាច្រើននាក់ និងមានអ្នកខ្លះទៀតចាញ់បោកអស់ប្រាក់ហូតដល់៨០០០បាត។

បច្ចុប្បន្នរូបនាងត្រូវសម្តកិច្ចថៃធ្វើការចោទប្រកាន់ពីបទប្រើត្រាក្លែងក្លាយរួចកសាងសុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ចាប់ខ្លួនបុរសម្នាក់ធ្វើទារុណកម្មលើកូន ពេលសុំទានមិនបាន គ្មានលុយទិញគ្រឿងញៀនជក់ ទិញស្រាផឹក

http://www.cen.com.kh/archives/ December 11, 2018

បន្ទាយមានជ័យ ៖ កងកម្លាំងមូលដ្ឋានកងរាជអាវុធហត្ថក្រុង បានចុះប្រតិបត្តិការបង្រ្កាបនិងចាប់ខ្លួនបុរសម្នាក់ក្នុងករណី ប្រើអំពើហឹង្សា និងធ្វើទារុណកម្មលើកូនបង្កើត នៅពេលសុំទានមិនបាន ព្រោះត្រូវការលុយយកទៅទិញគ្រឿងញៀនជក់ និងទិញស្រាផឹក ដែលប្រព្រឹត្តកាលពីថ្ងៃទី៦ ខែ ធ្នូ ឆ្នាំ២០១៨ នៅចំណុចភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៩ខែធ្នូ បានឲ្យដឹងថា ផ្អែកលើចម្លើយសារភាពរបស់ជនសង្ស័យ យោងតាមការបំភ្លឺរបស់ប្រជាពលរដ្ឋ និងយោងតាមរបាយការណ៍របស់មូលដ្ឋានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែតផងនោះ ជនសង្ស័យខាងលើ អាចត្រូវចោទពីបទ ហឹង្សា និងធ្វើទារុណកម្មលើកុមារ។ បច្ចុប្បន្នកម្លាំងជំនាញបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ ទៅតុលាការ ដើម្បីចាត់ការទៅតាមនីតិវិធី ។

លោកវរសេនីយ៍ត្រី នួន នីណារ៉ូ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថក្រុងក្រុងប៉ោយប៉ែត បានឲ្យដឹងថា ៖ ដោយមើលឃើញព័ត៌មានផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម ដែលបង្ហាញវីដេអូ ១ក្លិប របស់កុមាររងគ្រោះមានឈ្មោះ ធី នុល (ហៅ ប៉ូយ) អាយុ ៤ឆ្នាំ ៨ខែ ត្រូវឳពុកវាយធ្វើបាប បង្ខំឲ្យដើរសុំទាន តាមផ្សារ និងទីប្រជុំជននានាក្នុងក្រុងប៉ោយប៉ែត ។ ក្រោយពីទទួលបានព័ត៌មានស្ដីពីករណីខាងលើ លោកបានរាយការណ៍ជូនលោក ឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ដើម្បីស្នើសុំគោលការណ៍ចុះអនុវត្តន៍តាមនីតិវិធី ។ ក្រោយពីទទួលបានការអនុញ្ញាតពីលោកឧត្តមសេនីយ៍ត្រី មេបញ្ជាការកងរាជអាវុធហត្ថខេត្តរួចមក លោកបានដឹកនាំកម្លាំងចុះប្រតិបត្តិការស្រាវជ្រាវ រហូតឈានដល់ការឃាត់ខ្លួនជនសង្ស័យបានចំនួន ១នាក់ ឈ្មោះ ហ៊ុំ រ៉ា តេទ ប្រុស អាយុ ៣៦ ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ដើម្បីយកមកសាកសួរ ។ បន្ទាប់ពីធ្វើការឃាត់ខ្លួន និងទទួលបានចម្លើយសារភាពរបស់ជនសង្ស័យខាងលើ កម្លាំងជំនាញបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ ទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ដើម្បីចាត់ការបន្ត។ ចំណែកកុមាររងគ្រោះ កម្លាំងកងរាជអាវុធហត្ថបានប្រគល់ជូនទៅជីដូនបង្កើតរបស់កុមាររងគ្រោះ មានឈ្មោះ សោម សារ៉េត អាយុ ៦៤ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។ ដោយមើលឃើញពីស្ថានភាពជីវភាពរបស់ជីដូនកុមាររងគ្រោះជួបការលំបាក លោកវរសេនីយ៍ត្រី នួន នីណារ៉ូ និងសហការីបាននាំយកអំណោយមួយចំនួនជូនពួកគាត់ ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ បានបញ្ជាក់ឲ្យដឹងថា បន្ទាប់ពីកម្លាំងជំនាញអាវុធហត្ថខេត្តធ្វើការសាកសួរ ជនសង្ស័យបានឆ្លើយសារភាពថា ៖ ខ្លួនពិតជាបានប្រើហឹង្សាទៅលើកូនពិតប្រាកដមែន នៅពេលដែលខ្លួនសុំទានមិនបាន ព្រោះខ្លួនត្រូវការលុយយកទៅទិញគ្រឿងញៀនជក់ និងទិញស្រាផឹក៕ ដោយ ៖ កូឡាប

## ជប៉ុនជោគជ័យអនុម័តច្បាប់អន្តោប្រវេសន៍ថ្មី ដោយបើកទ្វារកាន់តែធំទទួលពលករបរទេស

https://thmeythmey.com/ 09, Dec 2018 , 10:29 pm

ក្រុមបក្សប្រឆាំងជប៉ុន ទាញក្បាលមេក្រូពីប្រធានសភា ក្នុងគោលបំណងផ្អាកការប្រកាសឲ្យចាប់ផ្ដើមបោះឆ្នោតអនុម័តច្បាប់អន្តោប្រវេសន៍ថ្មី នៅសភាជាន់ខ្ពស់ កាលពីថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០១៨។ សភាជាន់ខ្ពស់ជប៉ុន (Upper house) នៅថ្ងៃសៅរ៍ទី០៨ ខែធ្នូ បានអនុម័តច្បាប់អន្តោប្រវេសន៍ដ៏ចម្រូងចម្រាស់មួយ ដោយអនុញ្ញាតឲ្យពលករបរទេសរាប់ម៉ឺននាក់ មករស់នៅ និងបម្រើការក្នុងប្រទេសខ្លួន។ ច្បាប់ថ្មីនេះ នឹងបើកទ្វារជប៉ុនកាន់តែធំទូលាយ ក្នុង

គោលដៅជួយដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម ដែលកើតចេញពីការថយចុះនៃកំណើតប្រជាជន និងការកើនឡើងនៃចំនួនមនុស្សចាស់ជរា។

ច្បាប់គ្រប់គ្រងជនអន្តោប្រវេសន៍ថ្មី ដែលទើបតែត្រូវបានសភាជាន់ទាបសម្រេចអនុម័ត កាលពីថ្ងៃទី ២៧ ខែវិច្ឆិកាកន្លងទៅ ជាចុងក្រោយ ត្រូវបានអនុម័តនៅក្នុងព្រឹទ្ធសភាជប៉ុន ក្នុងសំឡេងគាំទ្រ ១៦១ ទល់នឹង ៧៦។ ក្រោមប្រព័ន្ធអន្តោប្រវេសន៍ថ្មីនេះ រដ្ឋាភិបាលជប៉ុនមានគោលដៅទទួលយកពលករបរទេសប្រមាណ ៣៤៥ ០០០ នាក់ ក្នុងវិស័យកំពុងខ្វះខាតកម្លាំងពលកម្ម រួមមាន សំណង់ កសិកម្ម សេវកម្មដឹកជញ្ជូន ថែទាំសុខភាព និងវិស័យផ្សេងៗទៀត ក្នុងរយៈពេល៥ឆ្នាំ។

បើតាមទីភ្នាក់ងារព័ត៌មាន AFP នាយករដ្ឋមន្ត្រីជប៉ុន ស៊ីនហ្សូ អាបេ បានបញ្ជាក់ទៅកាន់សភាជប៉ុនកាលពីថ្ងៃទី ០៦ ខែធ្នូថា៖ «យើងមានបំណងចាប់ផ្ដើមច្បាប់ថ្មីនេះ ក្នុងខែមេសា ឆ្នាំ២០១៩ ដោយសារតែយើងត្រូវការផ្លាស់ប្ដូរប្រព័ន្ធថ្មីមួយ ក្នុងគោលដៅជួយដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្ម ដែលកំពុងជួបប្រទះសព្វថ្ងៃនេះ»។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះ ច្បាប់ដ៏ចម្រូងចម្រាស់មួយនេះត្រូវបានលេចរូបរាងឡើង ក្នុងរយៈពេលប្រមាណជាង២ខែប៉ុណ្ណោះ ក្រោយពីលោកស៊ីនហ្សូ អាបេ បានប្រកាសស្នើគម្រោងប្រព័ន្ធអន្តោប្រវេសន៍ថ្មីនេះ ទោះបីជាក្រុមបក្សប្រឆាំងទាមទារឲ្យមានការតស៊ូមតិលម្អិតជាងនេះក៏ដោយក្ដី។

តាមពិតទៅ ជប៉ុនមានប្រពៃណីរឹតត្បិតចំពោះការទទួលយកពលករទេស មកធ្វើការក្នុងប្រទេសខ្លួន លើកលែងតែ ពលករមានជំនាញខ្ពស់ ជាពិសេសក្នុងវិស័យសុខាភិបាល។ ប៉ុន្តែចំពោះប្រព័ន្ធថ្មីនេះ គេមើលឃើញថា វាជាការផ្លាស់ប្ដូរដ៏ធំមួយរបស់ក្រុងតូក្យូទាក់ទងនឹងគោលនយោបាយអន្តោប្រវេសន៍របស់ខ្លួន។

## ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

## ពលករខ្មែរ ជាង១លាននាក់ ចាប់យកការងារ ក្រៅប្រទេស ទាំងស្របច្បាប់- មិនស្របច្បាប់

https://www.dap-news.com/ ByID:030 Posted on 12 December 2018 | 18:50

ភ្នំពេញ៖ សម្ដេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា មានពលករកម្ពុជា រហូតដល់ជាង១លាននាក់ បានចាប់យកជម្រើសការងារក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ ។ សម្ដេចលើកឡើងក្នុងពិធី "ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស១២ធ្នូ" លើកទី១២ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ នៅសាលមហោស្រព កោះពេជ្រថា ក្នុងចំណោម១លាននាក់នេះ ដែលមានពលករស្នាក់នៅ និងធ្វើការមិនមានច្បាប់ទម្លាប់ មិនមែនជាកំហុសរបស់ពលករតែឯងទេ តែដើម្បីជីវភាពទើបរកការងារនៅក្រៅប្រទេស។ ដូច្នេះសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសទាំងពីរ មានភារៈកិច្ចរួមគ្នាការពារចំពោះភាពខ្វះចន្លោះ នៃច្បាប់វិធានការប្រព័ន្ធ និងរបៀបរបបការងារឥរិយាបថ មន្ត្រីអនុវត្តន៍ ក៏ដូចជានិយោជកផ្ទាល់ ដែលអាចជំរុញឲ្យមានបរិយាកាសការងារល្អ ឬអាចធ្វើឲ្យមានភាពខុសច្បាប់ បទល្មើស ឬអំពើកេងប្រវ័ញ្ចនានាកើតឡើង។ សម្ដេចបន្ថែមថា មានពលករមិនតិចទេដែលបាននិងកំពុងរងគ្រោះថ្នាក់ ក៏ដូចជាប្រឈមគ្រោះថ្នាក់ ដោយមិនទាន់មានការដោះស្រាយសមស្រប បាត់ដំណឹងក្នុងអំឡុងពេលធ្វើការងារ ត្រូវបញ្ជូនចេញទៅឆ្ងាយ គ្មានទំនាក់ទំនង ឬក៏អាចបាត់បង់ជីវិតជាដើម។ សម្ដេចគូសបញ្ជាក់ថា បញ្ហាទាំងអស់នេះមិនអាចប្រទេសណាមួយដោះស្រាយតែឯកឯងបានឡើយ ព្រោះជាបញ្ហាពាក់ព័ន្ធរវាងគ្នា ហេតុនេះហើយទើបបានជាទាមទារឲ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយការទទួលខុសត្រូវ និងសមធម៌រវាងសមត្ថកិច្ចពាក់ព័ន្ធគ្រប់ផ្នែក នៃប្រទេសបញ្ជូននិងប្រទេសទទួល ដើម្បីកំណត់ឲ្យច្បាស់ថាអ្នកណាជាជនល្មើសត្រូវផ្ដន្ទាទោស និងអ្នកណាជាជនរងគ្រោះ ត្រូវសង្គ្រោះការពារ ដោយត្រូវទប់ស្កាត់កុំឲ្យមានរឿងនេះកើតឡើងទៀត៕ ដោយ នឿត សម្ផស្ស

## ច្បាប់ទាក់ទងការពរពោះជំនួស ក្រសួងមហាផ្ទៃឲ្យក្រសួងកិច្ចការនារី-យុត្តិធម៌ សិក្សា

http://www.rasmeinews.com/ December 12, 2018, 6:18 PM

ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រគល់ភារកិច្ចជូនលោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លោក អង្គវង្សវឌ្ឍានា សិក្សាច្បាប់ទាក់ទងការពរពោះជំនួស។ ការថ្លែងនេះ នៅក្នុងទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស កាលពីរសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ នៅសាលលមហោស្រពកោះពេជ្រ។ សម្ដេចក្រឡាហោមបានអំពាវនាវដល់ប្រជាពលរដ្ឋកុំចាប់យកការពរពោះជំនួសជាមធ្យោបាយដោះស្រាយជីវភាព។ សម្ដេចបានបញ្ជាក់ថា អំពើពរពោះជំនួស គឺជាអំពើអមនុស្សធម៌។ សម្រាប់កម្ពុជាយើងកំពុងសិក្សាអំពីបញ្ហានេះ គឺប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌ សិក្សាពីច្បាប់ទាក់ទងការពរពោះជំនួស។ ក្នុងរយៈពេលកំពុងសិក្សាច្បាប់នេះ គឺមិនអោយបញ្ហានេះប៉ះពាល់ដល់ប្រជាពលរដ្ឋទេ។

សូមជម្រាបថា ករណីពរពោះជំនួសនេះ សមត្ថកិច្ចបានចាប់ខ្លួនស្ត្រីស៊ីឈ្នួលពរពោះជំនួស និងមេខ្យល់នាពេលកន្លងមកនេះ ប្រមាណជិត ៥០នាក់។ ដោយក្នុងនោះ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ កន្លងទៅ នៅចំណុចផ្ទះវីឡាលេខ២៧A ផ្លូវ៣៤៨ និងផ្ទះវីឡាលេខ៩A ផ្លូវ៣៤៨ ស្ថិតនៅក្នុងបុរី វិមានភ្នំពេញ តាមបណ្ដោយផ្លូវលេខ៥ ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីពរពោះជំនួសចំនួនជាង៣០នាក់។ ហើយកាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីពរពោះជំនួស និងមេខ្យល់ចំនួនជាង ១០នាក់ គឺនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ការឃាត់ខ្លួនស្ត្រីពរពោះជំនួសនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខណៈពេលដែលពួកគេបម្រុងនឹងចេញដំណើរទៅក្រៅប្រទេស។

តាមចម្លើយរបស់នារីពរពោះជំនួសបានឱ្យដឹងថា ក្នុងកូន១ដែលពួកគាត់ពរពោះជំនួសនេះ ទទួលបានប្រាក់កំរៃចំនួន ១ម៉ឺនដុល្លារ គិតចាប់ពីខែដំបូង ឱ្យចំនួន៥០០ដុល្លារ ខែបន្ទាប់ ៣០០ដុល្លារ រហូតដល់កើត ទើបទទួលបានចំនួន ៦ពាន់ដុល្លារបន្ថែមទៀត។ ចំពោះការថែទាំគភ៌ ការប្រសូត្រ គឺជាបន្ទុករបស់ក្រុមហ៊ុន។ លក្ខណៈពិសេសនៃការពរពោះជំនួសក្នុងករណីនេះ គឺពេលជិតដល់ត្រូវឆ្លងទន្លេ ប្រសូត្រ គឺក្រុមហ៊ុនបញ្ជូនស្ត្រីពរពោះទៅប្រទេសចិនសម្រាលកូនរួចទើបបញ្ជូនមកស្រុកខ្មែរវិញ ហើយប្រគល់លុយបង្គ្រប់ ១ម៉ឺនដុល្លារ។

គួរបញ្ជាក់ថា កម្ពុជានឹងមានច្បាប់ពរពោះជំនួស ដើម្បីទប់ស្កាត់ការធ្វើពាណិជ្ជកម្មមនុស្ស ស្របពេលដែលសេចក្ដីពង្រាងច្បាប់នេះ កំពុងស្ថិតក្នុងដៃក្រសួងយុត្តិធម៌ ដែលត្រៀមបើកកិច្ចពិភាក្សាជាមួយអន្តរក្រសួងក្នុងពេល ឆាប់ៗនេះ។ ក្រសួងនឹងបញ្ជូនសេចក្ដីព្រាងច្បាប់ពរពោះជំនួសនេះ ទៅក្រសួង កិច្ចការនារី ដើម្បីឱ្យពិនិត្យលើលក្ខណៈបច្ចកទេសឡើងវិញ មុននឹងដាក់ចូលក្នុងកិច្ចប្រជុំអន្តរក្រសួង៕សរន

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៖ សមត្ថកិច្ចកំពុងបើកការ ស្រាវជ្រាវករណីម្ដាយ លក់កូន ដើម្បីឲ្យដឹងថា រឿងពិត ឬប្រឌិត

https://www.dap-news.com/ ByID:030 Posted on 12 December 2018 | 19:46

ភ្នំពេញ ៖ ក្រោយពីលោក វ៉ាត់ រដ្ឋមុនី ប្រធានសហព័ន្ធសហជីពកម្មករ សំណង់កម្ពុជា (CCTUF) ត្រូវបានអាជ្ញាធរ ថៃចាប់ខ្លួនពាក់ព័ន្ធការ ផលិតយន្តឯកសារ មួយក្រោមចំណងជើង ថា"ម្ដាយខ្ញុំ លក់ខ្ញុំ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថាសមត្ថកិច្ចកំពុង បើកការស្រាវជ្រាវ យ៉ាងយកចិត្តទុកដាក់បំផុតចំពោះករណីនេះ ដើម្បីឲ្យដឹងថា តើរឿងនេះពិត ឬប្រឌិត?

សូមរំលឹកថាលោក ព៉ាត់ រដ្ឋមុនី ប្រធានសហព័ន្ធសហជីពកម្មករ សំណង់កម្ពុជា (CCTUF) ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅក្នុងទីក្រុង បាងកក ប្រទេសថៃកាលពីថ្ងៃទី៧ ធ្នូ ពាក់ព័ន្ធការផលិត យន្តឯកសារស្តីពីការលក់កូនស្រី។ ការចាប់ខ្លួននេះ គឺធ្វើឡើងតាមសំណើផ្លូវការ របស់អាជ្ញាធររដ្ឋាភិបាលកម្ពុជា ក្រោយពីលោកបានចូលរួមផលិតខ្សែភាពយន្តឯកសារ "ម្តាយខ្ញុំ លក់ខ្ញុំ"ជាមួយទូរទស្សន៍RT របស់រុស្ស៊ី។ សម្រាប់អាជ្ញាធរខ្មែរ ខ្សែភាពយន្តឯកសារនេះធ្វើឲ្យប៉ះពាល់ដល់មុខមាត់របស់កម្ពុជា។

ក្នុងពិធី"ទិវាជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ" លើកទី១២នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ សម្តេច ស ខេង បានមានប្រសាសន៍ថា ជុំវិញករណីនេះសម្តេចខ្លួនឯងផ្ទាល់ក៏មិនទាន់ហ៊ានសន្និដ្ឋានថា ពិតកម្រិតណា ឬមិនពិតកម្រិតណានោះទេ ខណៈកម្លាំងសមត្ថកិច្ចកំពុងតែ បើកការស្រាវជ្រាវ រកអ្នកទទួលខុសត្រូវធ្វើ យ៉ាងយកចិត្តទុកដាក់នៅឡើយ។ សម្តេចមានប្រសាសន៍ថា "មានរឿងមួយដែរកន្លងទៅនេះ គឺមានខ្សែវីដេអូមួយ បានចងក្រងនូវសកម្មភាព មួយអំពីម្តាយលក់កូន ឥឡូវនេះកំពុងស្ថិតក្នុងដំណាក់កាលស្រាវជ្រាវសិក្សា ពីព្រោះថាយកទៅផ្សាយ នៅទូរទស្សន៍ RT តើរឿងនោះជារឿងពិត ឬក៏ជារឿងប្រឌិត បានចងក្រងខ្សែភាគយន្តអីចឹង យើងកំពុងតែសិក្សាទេខ្ញុំមិនហ៊ានវាយតម្លៃទេថា នឹងវាពិតកម្រិតណា ឬមិនពិតកម្រិតណានោះទេ។ប៉ុន្តែយ៉ាងណាក៏ក្នុងសមត្ថកិច្ចត្រូវសិក្សា និងស្រាវជ្រាវឲ្យបានត្រឹមត្រូវ ដើម្បីយើងរកវិធីការឲ្យសមស្របពីព្រោះកាលណាយើងមិនដឹងរឿងពិតដល់កម្រិតណា។ រហូតមកដល់ពេលយើងកំពុងសស្ថិតនៅការស្រាវជ្រាវ។តែក៏បានព័ត៌មានខ្លះហើយ ពិសេសពីតួអង្គដែរដើរតួក្នុងរឿងនេះ តែយើងត្រូវការប្រភពព័ត៌មានផ្សេងៗទៀត តែមកទល់ពេលនេះព័ត៌មានយើងទទួលបាន យើងអត់ទាន់ធ្វើការសន្និដ្ឋានដាក់លាក់ថាយ៉ាងម៉េចនោះទេ"។

យោងតាមការចេញផ្សាយរបស់វិទ្យុបារាំង បានឲ្យដឹងថា អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ(Human Rights Watch) នៅថ្ងៃទី១១ ធ្នូនេះ បានចេញថ្លែងការណ៍ដោយអំពាវនាវកុំឲ្យអាជ្ញាធរថៃបញ្ជូនលោកព៉ាត់ រដ្ឋមុនី ដែលបានចូលរួមផលិតភាពយន្តឯកសារស្តីពីការលក់កូនស្រីជាមួយទូរទស្សន៍រុស្ស៊ី មកឲ្យអាជ្ញាធរកម្ពុជា។ មិនតែប៉ុណ្ណោះ Human Rights Watch ក៏បានស្នើឲ្យអាជ្ញាធរថៃដោះលែងលោកព៉ាត់ រដ្ឋមុនី ជាបន្ទាន់ផងដែរ។

បច្ចុប្បន្ន លោកព៉ាត់ រដ្ឋមុនី ត្រូវបានអាជ្ញាធរថៃឃុំខ្លួននៅក្នុងមណ្ឌលឃុំខ្លួនជនអន្តោប្រវេសន៍ ដើម្បីរង់ចាំអាជ្ញាធរខ្មែរទៅនាំខ្លួនមកកាន់ប្រទេសកម្ពុជា។ នេះបើតាមការបញ្ជាក់ឲ្យដឹងពីអ្នកស្រីឡុង គីមហ៊ាង ដែលជាភរិយាលោក ព៉ាត់ រដ្ឋមុនី នៅលើទំព័រកាសែតខ្មែរថាមស៍នៅថ្ងៃនេះ។ អ្នកស្រីបានសម្តែងការបារម្ភថា ប្តីអ្នកស្រីនឹងត្រូវអាជ្ញាធរយកមកឃុំខ្លួនក្នុងពន្ធនាគារដោយគ្មានការស៊ើបអង្កេតដោយយុត្តិធម៌នៅកម្ពុជា។ ចំណែកទូរទស្សន៍RT (Russia Today) វិញ ក៏សម្តែងនូវការព្រួយបារម្ភខ្លាំងផងដែរចំពោះការឃុំខ្លួននេះ។ RT បានបញ្ជាក់ប្រាប់កាសែតថាមស៍ថានេះ ខ្លួនកំពុងតែធ្វើគ្រប់យ៉ាងដែលអាចធ្វើទៅបាន ដើម្បីជួយដោះស្រាយបញ្ហានេះដែលក្នុងនោះ រួមមានទាំងតាមរយៈផ្លូវទូតផងដែរ៕ ដោយ អេង ប៊ូធេង

## សម្តេចក្រឡាហោម ស ខេង៖ កម្ពុជានៅតែបន្តទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លា ដោយមិនអនុញ្ញាតឲ្យជនល្មើស មានឱកាសពង្រីកសកម្មភាពឡើយ

http://www.freshnewsasia.com/ 2018-12-12

(ភ្នំពេញ)៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨នេះ បានថ្លែងអះអាងថា រាជរដ្ឋាភិបាលកម្ពុជានឹងនៅតែការប្តេជ្ញាចិត្តខ្ពស់ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ដោយមិន

អនុញ្ញាតឲ្យជនល្មើស មានឱកាសពង្រីកសកម្មភាពឡើយ។ ការអះអាងយ៉ាងដូច្នេះ បានធ្វើឡើងក្នុងឱកាសដែលសម្តេចក្រឡាហោម ស ខេង តំណាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា អញ្ជើញចូលរួមជាអធិបតី ក្នុងទិវាជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១២ ឆ្នាំ២០១៨ ក្រោមប្រធានបទ «រួមសហការគ្នាបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស» នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨នេះ។

ក្នុងឱកាសនោះ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា «ខ្ញុំសូមបញ្ជាក់អំពីជំហរជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយ ក្នុងចំណោមអាទិភាពជាច្រើន សម្រាប់ការលើកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស»។ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរូបនេះ បានបន្ថែមទៀតថា អំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋ ដែលជាជនល្មើសជួញដូរមនុស្ស បានប្រើគ្រប់កលល្បិច ដើម្បីកេងប្រវ័ញ្ច រំលោភបំពាន លើមនុស្សផងគ្នា ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា និងអាយុជីវិតរបស់មនុស្សផងគ្នា ដែលចង់រស់រាន ជួបជុំគ្រួសារ និងសេចក្តីសុខដែរនោះ។

សម្តេចក្រឡាហោម ស ខេង បានសង្កត់ធ្ងន់ថា «រាជរដ្ឋាភិបាលកម្ពុជា នឹងនៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ ឲ្យកាន់តែខ្លាំងក្លា ដោយមិនអនុញ្ញាឲ្យជនល្មើស មានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ»។ សម្តេចក្រឡាហោម បន្តទៀតថា ជនល្មើសមិនបានបោះបង់មហិច្ឆិតារបស់ខ្លួនឡើយ ហើយខិតខំរិះរកគ្រប់ល្បិចកលតាមគ្រប់រូបភាព មានបណ្តាញមេខ្យល់ប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ ឆ្លងដែនពីប្រទេសមួយ នៅប្រទេសមួយ និងមានប្រព័ន្ធទំនាក់ទំនងកាន់តែទំនើប ដើម្បីគេចវេសពីសមត្ថកិច្ច។សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងរិះរកគ្រប់វិធានការ និងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនានា ដើម្បីការពារប្រជាពលរដ្ឋពីបទល្មើសដ៏ស្មុគស្មាញនេះ។

ជាមួយគ្នានោះ សម្តេចក្រឡាហោម បានលើកឡើងថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាននិងកំពុងជំរុញអនុវត្តយុទ្ធសាស្ត្រទាំងបួន របស់ផែនការជាតិ ដែលមានជាអាទ៍ ការងារបង្ការទប់ស្កាត់ កិច្ចការពារជនរងគ្រោះ ការពង្រឹងការអនុវត្តច្បាប់ និងការពង្រឹងកិច្ចសហការ ជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងប្រទេស ក៏ដូចជាជាមួយប្រទេសនានាក្នុងតំបន់ និងក្នុងពិភពលោក ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់៕

## សម្តេច ហ៊ុន សែន៖ ពលករខ្មែរធ្វើការនៅបរទេស មិនមែនជារឿងអាក្រក់ឬគួរឲ្យខ្មាសអៀនទេ

https://thmeythmey.com/ 12, Dec 2018 , 3:37 pm

ភ្នំពេញ៖ ក្នុងជំនួបជាមួយកម្មករ-កម្មការិនីនៅខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១២ ខែធ្នូ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា គ្រប់កម្មករដែលបម្រើការងារនៅក្រៅប្រទេស មិនមែនសុទ្ធតែជារឿងគួរឲ្យខ្មាសអៀន ឬរឿងអាក្រក់នោះទេ។ ផ្ទុយទៅវិញ ការនាំពលករខ្មែរទៅធ្វើការនៅបរទេស គឺពួកគេនាំមកវិញនូវប្រាក់ចំណូលសម្រាប់ប្រទេសជាតិ។ ប្រធានគណបក្សកម្ពុជា បានបញ្ចេញសារដ៏វែងអន្លាយនៅក្នុងទំព័រហ្វេសប៊ុកថា ៖«សូមបងប្អូនកុំយល់ច្រឡំ ឬគិតខុស ក្នុងពេលដែលបងប្អូនទៅធ្វើការនៅបរទេស។ សូម្បីថៃក៏គេបញ្ជូនកម្មករទៅធ្វើការនៅប្រទេស កូរ៉េ ជប៉ុន ហ្វីលីពីន និងសហរដ្ឋអាមេរិកជាដើម។ ពួកគេបាននាំមកវិញនូវប្រាក់ចំណូលជាច្រើនសម្រាប់ប្រទេសគេ»។

ថ្លែងចំពោះមុខកម្មករ-កម្មការិនី ក្នុងខេត្តកំពង់ស្ពឺ ប្រមុខរដ្ឋាភិបាល បាននិយាយថា លោកកំពុងខិតខំស្វែងរកទីផ្សារការងារក្រៅប្រទេស ដូចជា ប្រទេសកូរ៉េ, ជប៉ុន និងប្រទេសអារ៉ាប់ ដើម្បីផ្តល់ការងារដល់ពលរដ្ឋខ្មែរ-អ៊ិស្លាម ផងដែរ។ នាយករដ្ឋមន្ត្រីកម្ពុជា បានអះអាងថា កន្លងមកលោកក៏បានជួយដោះស្រាយពលករដែលចាញ់បោកមេខ្យល់យកទៅធ្វើការនៅបរទេសខុសច្បាប់។ ជាមួយគ្នាផងដែរ ប្រមុខរដ្ឋាភិបាល បានជំរុញឲ្យក្រសួងការងារ និងក្រសួងយុត្តិធម៌ ពន្លឿងដោះស្រាយរឿងបណ្តឹងរបស់ក្រុមសហជីព។

សូមបញ្ជាក់ថា សហគ្រាសដែលនាំយកពលករខ្មែរទៅធ្វើការនៅបរទេសមានដូចជា ប្រទេសចិនចំនួន១៨រោងចក្រ, កូរ៉េចំនួន៤រោងចក្រ និងសិង្ហបុរី១រោងចក្រ ហើយពួកគេភាគច្រើនធ្វើការជាអ្នកកាត់ដេរសម្លៀកបំពាក់, ផលិតស្បែកជើង, កាបូប សម្ភារធ្វើដំណើរ, ខ្សែរូត, សម្ភារសម្រាប់ព្យួរសំលៀកបំពាក់ និងផលិតតង់។ ផលិតផលទាំងនោះត្រូវបានក្រុមហ៊ុន នាំចេញទៅផ្សារអន្តរជាតិ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងប្រទេស៕

## អាជ្ញាធរថៃបានបញ្ជូនសកម្មជនសិទ្ធិការងារលោក រ៉ាត់ រត្នមុនី ទៅកម្ពុជាវិញហើយ

https://www.rfa.org/khmer/news/ *ដោយ សុ ជីវី* 2018-12-12

មន្រ្តីអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) ប្រចាំក្រុងបាងកក លោក ស៊ូណៃ ផាស៊ុក (Sunal Phasuk) និងភរិយារបស់លោក រ៉ាត់ រត្នមុនី គឺលោកស្រី ឡុង គឹមហ៊ាង ថ្លែងបញ្ជាក់ដូចគ្នា អំពីការបញ្ជូនខ្លួនលោក រ៉ាត់ រត្នមុនី ទៅកម្ពុជា នៅល្ងាចថ្ងៃទី១២ ធ្នូ។ លោកស្រីមិនដឹងថា អជ្ញាធរថៃ បញ្ជូនប្តីលោកស្រីទៅកម្ពុជា តាមយន្តហោះ ឬតាមឡាននោះទេ ហើយរហូតមកដល់ពេលនេះ លោកស្រីថា មិនទាន់ដឹងពីទីកន្លែងរបស់ប្តីលោកស្រីនៅទីណាឡើយទេ ក្នុងប្រទេសកម្ពុជា ព្រោះអាជ្ញាធរកម្ពុជាបិទបាំងព័ត៌មាននេះ លោកស្រីស្នើសុំឲ្យអង្គការជាតិ និងអន្តរជាតិតាមដានករណីប្តីលោកស្រីឲ្យបានជិតដល់ និងស្នើសុំអាជ្ញាធរ និងតុលាការឲ្យស៊ើបអង្កេតប្រមូលភស្តុតាងត្រឹមត្រូវឡើងវិញ មិនមែនជានីតិវិធីតាមចាប់ចងប្តីលោកស្រីនោះទេ។ លោកស្រីបន្តថា ប្តីលោកស្រីមិនបានផលិតវីដេអូ ដើម្បីបង្ខូចកិត្តិយស្ត្រីខ្មែរ ឬប្រទេសខ្មែរនោះទេ។

ប្រធានសហព័ន្ធសហជីពកម្មករសំណង់កម្ពុជា (CCTUF) លោក រ៉ាត់ រត្នមុនី ត្រូវបានប៉ូលីសថៃឃាត់ខ្លួន កាលពីថ្ងៃទី៧ ធ្នូ នៅទីក្រុងបាងកក ខណៈលោក និងគ្រួសារកំពុងព្យាយាមរត់គៀសខ្លួនបន្តទៅប្រទេសហុល្លង់ (Netherland)។ ពេលចាប់ខ្លួន ប៉ូលីសថៃបានប្រាប់ទៅភរិយារបស់លោកថា ពួកគេទទួលបានសំណើពីសមត្ថកិច្ចកម្ពុជា ឱ្យឃាត់ខ្លួន និងបញ្ជូនលោក រ៉ាត់ រត្នមុនី ត្រឡប់ទៅកម្ពុជាវិញ។ អាជ្ញាធរកម្ពុជា ចោទលោកថា បានប្រឌិតឯកសារក្លែងក្លាយ ក្នុងរឿងភាពយន្តឯកសារ ដែលលោកផលិតអំពីការជួញដូរផ្លូវភេទ ទៅប្រទេសកម្ពុជា។

សមត្ថកិច្ចកម្ពុជាក៏បានចោទលោកថា បានឱ្យលុយទៅតួអង្គម្តាយកូន ២នាក់ ចំនួន ២០០ដុល្លារ ជាថ្នូរនឹងការនិយាយកុហកក្នុងភាពយន្តឯកសារ។ ទាំងសមត្ថកិច្ច និងអ្នកនាំពាក្យរបបក្រុងភ្នំពេញសុទ្ធតែអះអាងដូចគ្នាថា ករណីនេះមិនអាចលើកលែងឱ្យបានឡើយ ព្រោះលោក រ៉ាត់ រត្នមុនី បានប្រឌិតរឿងប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍របស់ជាតិ។ ពួកគេអះអាងថា ត្រូវតែនាំខ្លួនសកម្មជនសិទ្ធិការងាររូបនេះ ឱ្យមកទទួលទោសតាមផ្លូវច្បាប់នៅកម្ពុជា។

ភាពយន្តឯកសារ មានចំណងជើងថា "ម្តាយខ្ញុំ លក់ខ្ញុំ" ដែលមានរយៈពេលជាង ២៧នាទីនោះ គឺបង្ហាញពីនារីវ័យក្មេងមិនទាន់គ្រប់អាយុ ៣នាក់ ត្រូវបានលក់ឱ្យបម្រើផ្លូវភេទ ដើម្បីដោះស្រាយជីវភាពគ្រួសារក្រីក្រលំបាក។ ភាពយន្តឯកសារនេះ មានចំនួនចូលទស្សនាជាង ១លាន ៤សែនដង លើបណ្តាញយូធូប (You Tube) និងជាង ៥សែនដងនៅលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) គឺជាវីដេអូសង្ខេបផ្តោតលើគ្រួសារមួយ នៃអតីតពលរដ្ឋបឹងកក់ ដែលរងការបណ្តេញចេញដោយបង្ខំ៕

# សាលាដំបូងខេត្តសៀមរាប សម្រេចឃុំខ្លួនបណ្ដោះអាសន្ន ជនជាតិចិន ៩នាក់ ក្រោមបទចោទចែកចាយរូបភាពអាសអាភាសកុមារ

https://www.rfa.org/khmer/news/ ដោយ ហេង វស្នី 2018-12-12

ជនជាតិចិន ៣នាក់ ក្នុងចំណោម ៩នាក់ នៅខេត្តសៀមរាប ដែលនគរបាលខេត្តសៀមរាប ចុះឃាត់ខ្លួនសង្ស័យធ្វើសកម្មភាពចែកចាយរូបអាសអាភាសរបស់កុមារ កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៨។

សាលាដំបូងខេត្តសៀមរាប សម្រេចឃុំខ្លួនបុរសជនជាតិចិន ៩នាក់ ដែលសង្ស័យពីបទចែកចាយរូបភាពអាសអាភាសរបស់កុមារតាមប្រព័ន្ធអ៊ីនធើណេតជាបណ្ដោះអាសន្ន។

សង្គមស៊ីវិលខេត្តសៀមរាប ស្វាគមន៍ចំណាត់ការផ្លូវច្បាប់នេះ និងទាមទារឲ្យរឹតបន្តឹង លើជនបរទេសឲ្យបានខ្លាំង កុំឲ្យកើតមានរឿងអាស្រូវ ដូចនៅខេត្តព្រះសីហនុ។

ប្រធានលេខាធិការដ្ឋានរដ្ឋបាល និងជាអ្នកនាំពាក្យសាលាដំបូងខេត្តសៀមរាប លោក យិន ស្រាង ប្រាប់អាស៊ីសេរីថា ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួន បុរសជនជាតិចិន៩នាក់ បណ្ដោះអាសន្ននៅក្នុងពន្ធនាគារខេត្ត តាមបទចោទប្រកាន់របស់តំណាងអយ្យការខេត្ត ពីបទចែកចាយរូបភាពអាសអាភាសរបស់កុមារ។ បើទោះបែបណា អ្នកនាំពាក្យតុលាការរូបនេះ មិនផ្ដល់ព័ត៌មាន អំពីកុមាររងគ្រោះទេ៖ «ចៅក្រមគាត់បានឃុំខ្លួន ពួកគាត់ហើយ ឃុំខ្លួនបណ្ដោះអាសន្នណា។ ឥឡូវពួកគាត់កំពុងនៅពន្ធនាគារខេត្តសៀមរាប។ សំណួរ៖ បទចោទរក្សាទុកដដែល ឬយ៉ាងណា? ឆ្លើយ៖ បាទ! នៅដដែល»។

កាលពីថ្ងៃទី៨ ធ្នូ កងកម្លាំងការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធីនៃស្នងការនគរបាលខេត្តសៀមរាប រួមជាមួយកងកម្លាំងចម្រុះរបស់អធិការដ្ឋាននគរបាលក្រុងសៀមរាប ប៉ុស្តិ៍រដ្ឋបាលសង្កាត់ស្វាយដង្គំ និងសង្កាត់ស្លក្រាម បានចុះឃាត់ខ្លួនជនជាតិចិន ៩នាក់ នៅទីតាំង ៣កន្លែង។ ក្នុងនោះ ជនជាតិចិនម្នាក់ ឃាត់ខ្លួននៅក្នុងបុរីមួយ ឈ្មោះ អាក់ខេត នៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ៥នាក់ ឃាត់ខ្លួននៅក្នុងផ្ទះវិឡាជួល នៅភូមិគ្រួស សង្កាត់ស្វាយដង្គំ និង ៣នាក់ទៀត ឃាត់ខ្លួនបាននៅក្នុងបន្ទប់ផ្ទះសំណាក់ឈ្មោះ មហាមាន ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម។ ប្រតិបត្តិការនោះ សមត្ថកិច្ចបានដកហូត សម្ភារៈបច្ចេកវិទ្យាជាច្រើនជាភស្តុតាង។ ជនជាតិចិនទាំង ៩នាក់នោះ ត្រូវបានចោទប្រកាន់ថា បានធ្វើសកម្មភាពចែកចាយរូបភាពអាសអាភាសរបស់កុមារ តាមប្រព័ន្ធអ៊ីនធើណេត។

នៅមុនការចាប់ខ្លួនជនជាតិចិន នៅខេត្តសៀមរាប ២ថ្ងៃ គឺកាលពីថ្ងៃទី៦ ធ្នូ សមត្ថកិច្ចបានបញ្ជូនជនសង្ស័យជនជាតិចិន ចំនួន ២៣៥នាក់ ឲ្យត្រលប់ទៅប្រទេសចិនវិញ ដោយសង្ស័យថា ជាក្រុមឆបោក គំរាមកំហែង និងជំរិតទារប្រាក់ជនជាតិចិនដូចគ្នា តាមប្រព័ន្ធទូរគមនាគមន៍ (VOIP)។

របាយការណ៍របស់ក្រសួងមហាផ្ទៃ ចេញផ្សាយកាលពីខែកញ្ញា បង្ហាញថា ជនជាតិចិននៅកម្ពុជាមានចំនួន ២១ម៉ឺននាក់ ក្នុងនោះជនជាតិចិនកំពុងរស់នៅច្រើនជាងគេ គឺនៅខេត្តព្រះសីហនុមានចំនួនជាង ៧ម៉ឺន ៨ពាន់នាក់។ ចំពោះជនជាតិចិន ដែលរងការចុះចាប់ខ្លួន ដល់ទីតាំងនិងបណ្ដេញចេញ ពីប្រទេសកម្ពុជា ទៅប្រទេសចិនវិញ គិតត្រឹមខែធ្នូនេះ មានចំនួន ៦០៨នាក់។ បទល្មើសដែលប្រព្រឹត្តច្រើនជាងគេ គឺបទគំរាមជំរិត និងឆបោកតាមប្រព័ន្ធទូរគមនាគមន៍ (VOIP)។

អ្នកអង្កេតសមាគមសិទ្ធិមនុស្ស អាដហុក ខេត្តសៀមរាប លោក ច័ន្ទ ចំរើន ស្វាគមន៍ចំណាត់ការផ្លូវច្បាប់ លើជនបរទេស ដើម្បីព្រមានកុំឲ្យជនបរទេសផ្សេងទៀត ចាត់ទុកប្រទេសកម្ពុជា ជាទីតាំងប្រព្រឹត្តិបទល្មើសអាសអាភាស។ លោកឲ្យដឹងថា កន្លងមក អាជ្ញាធរខេត្តសៀមរាប ធ្លាប់បង្ក្រាបករណីជនបរទេសចែកចាយរូបភាពអាសអាភាស របស់កុមារ តាមប្រព័ន្ធអ៊ីនធើណេតម្ដងហើយ ប៉ុន្តែមិនមែនជាជនជាតិចិនទេ៖ «សម្រាប់សង្គមស៊ីវិល យើងសាទរ ចំពោះ

ការអនុវត្តច្បាប់»។ សង្គមស៊ីវិលរូបនេះ ក្រើនរំលឹកឲ្យអាជ្ញាធរខេត្តសៀមរាប ទប់ស្កាត់បទល្មើស ដែលប្រព្រឹត្តិដោយជនជាតិចិន លើទឹកដីខេត្តទេសចរណ៍មួយនេះ ឲ្យបានប្រសើរ កុំបណ្តែតបណ្តោយឲ្យជនជាតិចិនបង្ករឿងអាស្រូវ ដូចនៅខេត្តព្រះសីហនុ ព្រោះខេត្តសៀមរាប ជាទឹកដីទេសចរណ៍ប្រវត្តិសាស្ត្រខ្មែរ៕

## ជនល្មើសជួញដូរមនុស្ស ប្រើគ្រប់កលល្បិច ដើម្បីកេងប្រវ័ញ្ច រំលោភបំពាន ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា

http://www.cen.com.kh/archives/ December 13, 2018

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ដែលជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងថា អំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋ ដែលជាជនល្មើសជួញដូរមនុស្ស បានប្រើគ្រប់កលល្បិច ដើម្បីកេងប្រវ័ញ្ច រំលោភបំពាន លើមនុស្ស ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា និងអាយុជីវិតរបស់មនុស្ស ដែលចង់រស់រាន ជួបជុំគ្រួសារ និងសេចក្តីសុខ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជានឹងនៅតែការប្តេជ្ញាចិត្តខ្ពស់ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ដោយមិនអនុញ្ញាតឲ្យជនល្មើសមានឱកាសពង្រីកសកម្មភាពឡើយ។

សម្តេចក្រឡាហោម ស ខេង តំណាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា អញ្ជើញចូលរួមជាអធិបតី ក្នុងទិវាជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១២ ឆ្នាំ២០១៨ ក្រោមប្រធានបទ រួមសហការគ្នាបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨នៅកោះពេជ្រ។ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា "ខ្ញុំសូមបញ្ជាក់អំពីជំហរជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយ ក្នុងចំណោមអាទិភាពជាច្រើន សម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ រាជរដ្ឋាភិបាលកម្ពុជា នឹងនៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ ឲ្យកាន់តែខ្លាំងក្លា ដោយមិនអនុញ្ញាឲ្យជនល្មើស មានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ។

សម្តេចក្រឡាហោម បានអះអាងថា រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងរិះរកគ្រប់វិធានការ និងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនានា ដើម្បីការពារប្រជាពលរដ្ឋ ពីបទល្មើសដ៏ស្មុគស្មាញនេះ ខណៈជនល្មើសមិនបានបោះបង់មហិច្ឆតារបស់ខ្លួនឡើយ ហើយខិតខំរិះរកគ្រប់ល្បិចកលតាមគ្រប់រូបភាព មានបណ្តាញមេខ្យល់ប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ ឆ្លងដែនពីប្រទេសមួយ នៅប្រទេសមួយ និងមានប្រព័ន្ធទំនាក់ទំនងកាន់តែទំនើប ដើម្បីគេចវេសពីសមត្ថកិច្ច៕ ដោយ ៖ កូឡាប

## លោក ស ខេង៖ មានកម្មកររាប់ម៉ឺននាក់នៅប្រទេស ថៃ ដែលមិនទាន់ស្របច្បាប់

https://www.postkhmer.com/ *គង់ មេត្តា* | Publication date 13 December 2018 | 09:10 ICT

ភ្នំពេញៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ពីម្សិលមិញបានថ្លែងថា នៅមានកម្មករចំណាកស្រុកកម្ពុជាប្រមាណរាប់ម៉ឺននាក់ទៀតនៅក្នុងប្រទេសថៃ ដែលមិនទាន់ទទួលបានភាពស្របច្បាប់ពេញលេញ ដើម្បីការពារសុវត្ថិភាពពួកគេ បើទោះបីជាដំណោះស្រាយរាជរដ្ឋាភិបាលនៃប្រទេសទាំង ២ បានសហការគ្នាបង្កើតនីតិវិធី និងប្រព័ន្ធផ្តល់ភាពស្របច្បាប់ជូនពលករក្នុងប្រទេសថៃដែលជាប្រទេសគោលដៅក៏ដោយ។

ប៉ុន្តែស្ថិតក្នុងស្ថានភាពបែបនេះ អង្គការសង្គមស៊ីវិលក៏បានស្នើឲ្យរដ្ឋាភិបាលធ្វើយ៉ាងណាត្រូវរៀបចំធ្វើលិខិតឆ្លងដែនឲ្យមានតម្លៃសមរម្យ និងបង្កើតការិយាល័យឲ្យបានច្រើន ដើម្បីផ្តល់ភាពងាយស្រួលដល់កម្មករក្នុងការធ្វើលិខិតឆ្លងដែន ដែលអាចជួយឲ្យកម្មករមានភាពស្របច្បាប់ក្នុងការធ្វើចំណាកស្រុក។

នៅក្នុងសុន្ទរកថារបស់លោកឧបនាយករដ្ឋមន្ត្រី ស ខេង ដែលបានថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី ១២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រដែលបានប្រារព្ធឡើង ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលោក ស ខេង ថ្លែងថា ក្នុងរយៈពេលពីខែកក្កដា ឆ្នាំ ២០១៧ ដល់ខែមិថុនា ឆ្នាំ ២០១៨ និងបច្ចុប្បន្នមានកម្មករប្រមាណជាង ៥០ ម៉ឺននាក់ ត្រូវបានផ្តល់នូវឯកសារច្បាប់មួយចំនួនដូចជាឯកសារបញ្ជាក់អត្តសញ្ញាណប័ណ្ណអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការងារក្នុងរយៈពេលកំណត់ និងនៅទីតាំងការងារជាក់លាក់មួយតាមរយៈនីតិវិធី ផ្តល់ភាពស្របច្បាប់ជូនរវាងប្រទេសកម្ពុជា និងថៃ។ លោក ស ខេង មានប្រសាសន៍ថា៖ «តែទោះបីជាយ៉ាងណាក្តីការផ្តល់ភាពស្របច្បាប់ក្នុងដំណាក់កាលនេះ គឺគ្រាន់តែជាដំណោះស្រាយបណ្តោះអាសន្នតែប៉ុណ្ណោះ។ ព្រោះថាអ្នកដែលទទួលបានការអនុញ្ញាតតាមផ្លូវច្បាប់ តាមប្រព័ន្ធដែលជាការព្រមព្រៀងគ្នាក្នុងអនុស្សរណៈមានតែប្រមាណ ៤០ ម៉ឺននាក់ប៉ុណ្ណោះ។ ដូច្នេះនៅមានរាប់ម៉ឺននាក់ទៀតនៅមិនទាន់ទទួលបានភាពស្របច្បាប់ពេញលេញ ដែលអាចការពារសុវត្ថិភាពបាននៅឡើយទេ»។

លោក ស ខេង ក៏បានកត់សម្គាល់ដែរថាមានកម្មករចំណាកស្រុកខ្មែរដែលធ្វើការនៅផ្នែកនេសាទគឺមានភាពងាយរងគ្រោះច្រើនជាងគេ ដែលទាមទារឲ្យមានការការពារជាច់ដោយឡែក។ លោកបានបញ្ជាក់ថា៖ «ក្នុងពេលនោះពលករនេសាទជាមុខសញ្ញានៃការទទួលភាពរងគ្រោះច្រើនជាងគេដែលចាំបាច់ត្រូវមានកិច្ចព្រមព្រៀងកំណត់លក្ខខណ្ឌដោយឡែកស្តីពីកិច្ចការពារសុវត្ថិភាព និងសិទ្ធិពលករនេសាទ ដែលអាចរក្សាបានផលប្រយោជន៍ទាំងនិយោជិត និងទាំងនិយោជក»។ លោក ស ខេង ថ្លែងថាមានពលករកម្ពុជារហូតជាង ១ លាននាក់បានចាប់យកជម្រើសការងារក្រៅប្រទេស និងកំពុងធ្វើការនៅក្រៅប្រទេស ដោយស្របច្បាប់ក្តី និងមិនស្របច្បាប់ក្តី។ លោក ស ខេង បញ្ជាក់៖ «មានពលករមិនតិចទេដែលបាននិងកំពុងតែរងគ្រោះថ្នាក់ក៏ដូចជាប្រឈមនឹងគ្រោះថ្នាក់។ យើងមិនទាន់បានដឹងច្បាស់ទេថាមានពលករប៉ុន្មាននាក់ដែលបាននិងកំពុងតែមានបញ្ហាដោយមិនទាន់មានការដោះស្រាយ ឬមានការដោះស្រាយ ដោយមិនសមស្រប ឬកំពុងបាត់ដំណឹងក្នុងអំឡុងពេលការងារព្រោះតែត្រូវបានគេបញ្ជូនចេញទៅឆ្ងាយគ្មានទំនាក់ទំនងរងគ្រោះថ្នាក់បាត់បង់ជីវិត ឬកំពុងស្ថិតក្នុងការឃុំខ្លួនដោយមិនមានមូលហេតុសមស្របជាច្រើន»។

លោកក៏បានកត់សម្គាល់ផងដែរថា មានការកើតឡើងនូវអំពើជួញដូរមនុស្សដែលបាននិងកំពុងបង្កក្នុងរូបភាពជួលឲ្យពពោះជំនួស ដើម្បីជួញដូរទារក និងនាំចេញទៅក្រៅប្រទេសនៅក្នុងប្រទេសកម្ពុជា។ លោកថ្លែងថា៖ «សកម្មភាពបែបនេះមិនត្រឹមតែជាសកម្មភាពខុសច្បាប់ប៉ុណ្ណោះទេ តែក៏បានជះឥទ្ធិពលដល់វប្បធម៌ប្រពៃណីជាតិសីលធម៌រស់នៅក៏ដូចជាប៉ះពាល់ដល់សុខភាព និងអាយុជីវិតស្ត្រីដែលជាមាតានិងទារក សូមដាស់តឿនដល់ប្រជាពលរដ្ឋទាំងឡាយសូមកុំប្រកាន់យកអំពើពពោះជំនួសជាមធ្យោបាយក្នុងការដោះស្រាយជីវភាពព្រោះជាអំពើអមនុស្សធម៌ ជាអំពើបាបនិងជាបទល្មើស។ លោក ស ខេង និយាយថាស្ត្រីពពោះជំនួសបានយល់ព្រមចិញ្ចឹមកូនដែលខ្លួនស៊ីឈ្នួលពពោះជំនួស។ គ្រួសារ និងស្ត្រីក្រីក្រជាច្រើនបានព្យាយាមប្រឹងប្រែងរកមធ្យោបាយដើម្បីដោះស្រាយជីវភាពខ្លួន និងចិញ្ចឹមកូន ទោះជាលំបាកយ៉ាងណាក៏ដោយ តែមិនបានប្រកាន់យកជម្រើសលក់ ឬបោះបង់កូនដែលខ្លួនបានពពោះដើម្បីដោះស្រាយការលំបាករបស់ខ្លួនឡើយ។ លោកបញ្ជាក់ថា៖ «ជាថ្មីម្តងទៀតខ្ញុំសូមរំឭកដាស់តឿនចំពោះមន្ត្រីរាជរដ្ឋាភិបាលទាំងឡាយដែលបាន និងកំពុងតែសាងបញ្ហាឃុបឃិត និងសហការជាមួយជនល្មើសជួញដូរមនុស្ស

និងអំពើពាក់ព័ន្ធទាំងឡាយទោះបីដោយចេតនាក្តីអចេតនាក្តីត្រូវផាប់កែខ្លួនឲ្យបានល្អ ព្រោះរដ្ឋាភិបាលត្រូវធ្វើការកែទម្រង់គ្រប់វិស័យរាប់ទាំងឥរិយាបថការងាររបស់មន្ត្រីរាជការ»។

លោក Dy The Hoya មន្ត្រីអង្គការ Central ដែលជាអង្គការសិទ្ធិការងារបានថ្លែងថា កម្មករដែលមិនទាន់ទទួលបានភាពស្របច្បាប់អាចប្រឈមបញ្ហាមួយចំនួន ជាពិសេសត្រូវបានថៅកែកេងប្រវ័ញ្ច និងអាចត្រូវមន្ត្រីប៉ូលិសថៃគាបសង្កត់ទាមទារប្រាក់។ លោកបញ្ជាក់ថា៖ «គាត់អាចត្រូវប៉ូលីសថៃចាប់បញ្ជូនមកវិញ ហើយគាត់ត្រូវរស់នៅរបៀបលួចលាក់ និងអាចប្រឈមនឹងការកេងប្រវ័ញ្ច។ ខ្ញុំគិតថាដើម្បីឲ្យកម្មករទទួលបានភាពស្របច្បាប់ រដ្ឋាភិបាលត្រូវធ្វើឲ្យតម្លៃលិខិតឆ្លងដែនមានតម្លៃសមរម្យ និងបង្កើតការិយាល័យឲ្យបានច្រើន»៕

## សម្តេច ស ខេង អំពាវនាវកុំស៊ីឈ្នួលពពោះជំនួស ព្រោះជាអំពើខុសច្បាប់

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 13 December, 2018

ភ្នំពេញ ៖ ក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី១២ ធ្នូ ឆ្នាំ២០១៨ នេះ សម្តេច ស ខេង បានអំពាវនាវដល់ប្រជាពលរដ្ឋកុំស៊ីឈ្នួលពពោះជំនួស ដើម្បីជាមធ្យោបាយក្នុងការដោះស្រាយជីវភាព ពីព្រោះការពពោះជំនួស ជាអំពើបាប និងជាអំពើខុសច្បាប់។ ជាមួយគ្នានេះ សម្តេច ស ខេង ក៏បាន ស្នើដល់អាជ្ញាធរពាក់ព័ន្ធត្រូវរួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស និងបង្ក្រាទប់ស្កាត់បទល្មើសដទៃទៀត ផងដែរ។

សូមបញ្ជាក់ថា កន្លងទៅសមត្ថកិច្ច បានចាប់ឃាត់ខ្លួនស្ត្រីពពោះជំនួស៣២នាក់ និងមនុស្ស៥នាក់ទៀតជាមេខ្យល់ ក្នុងនោះមានជនជាតិចិនម្នាក់ផងដែរ។ ការពពោះជំនួស ជាអំពើមួយខុសច្បាប់ ដែលចាត់ទុកជាបទល្មើសការជួញដូរមនុស្សផងដែរ។ ទោះជាយ៉ាងនេះក្តី រហូតមកដល់ពេលនេះ មានស្ត្រីស៊ីឈ្នួលពពោះជំនួសមួយចំនួន ត្រូវបានដោះ លែងឲ្យត្រឡប់ទៅផ្ទះវិញហើយ ដោយភ្ជាប់ជាមួយលក្ខខណ្ឌត្រូវចិញ្ចឹមកូនដោយខ្លួនឯង៕

## រូបភាពនៃការជួញដូរមនុស្ស មិនត្រឹមតែជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទនោះទេ

http://kleykley.sabay.com.kh/ *ថ្ងៃទី ១២ ធ្នូ ២០១៨ ម៉ោង* 16:16

លោកស្រី ជួញ សុធែ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងថា រូបភាពនៃអំពើជួញដូរមនុស្សមិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ ប៉ុន្តែក៏មានបាតុភាពមួយចំនួនទៀត ដែលទំនោរទៅរកអំពើជួញដូរសរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន ដែរហៅថា អំពើជួលពពោះជំនួស។ ការថ្លែងនេះ ធ្វើឡើងនៅក្នុងទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ នៅសាលមហោស្រពកោះពេជ្រ ក្រោមអធិបតីភាពសម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកស្រីលើកឡើងថា នេះជាកង្វល់ថ្មីទៀត ដែលគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាននឹងកំពុងតែដាក់វិធានការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបឱ្យបានទាន់ពេលវេលា និងសិក្សាអំពីបរិបទច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធបន្ថែមទៀត ដើម្បីជៀសវាងការរីកដាលនៃបទល្មើស ដែលនាំឱ្យបង្កគ្រោះថ្នាក់កាន់តែច្រើនឡើង ដល់ជីវិតមនុស្ស។ ការធ្វើទេសន្តប្រវេសន៍ ក៏នៅតែជាប្រធានបទដ៏សំខាន់ផងដែរ ដែលត្រូវថ្លឹងថ្លែងអំពីផលចំណេញ និងផលប៉ះពាល់ ពោលគឺត្រូវធ្វើការសម្រេចចិត្តដោយប្រុងប្រយ័ត្ន។

រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់ ក្នុងការការពារប្រជាពលរដ្ឋពីភាពរងគ្រោះទាំងឡាយដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឱ្យមានវិនាសកម្មជាថ្មីដល់មនុស្សជាតិ ហើយបាននឹងកំពុងក្លាយជាទាសភាពសម័យទំនើប គួរឱ្យភ័យខ្លាច និងស្អប់ខ្ពើម។ លោកស្រី ជួញ សុធែ បន្ថែម។ ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាននៃគ

ណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានអំពាវនាវដល់គ្រប់ក្រសួងស្ថាប័នក្នុងរាជរដ្ឋាភិបាល ដែលពាក់ព័ន្ធជាតិ និងអន្តរជាតិ រួមសហការគ្នា បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស៕ អត្ថបទ៖ សោភា

## មន្ត្រីជាន់ខ្ពស់អគ្គស្នងការដ្ឋាននគរបាលជាតិបំភ្លឺរឿងការស្នើថៃបញ្ជូនខ្លួន រ៉ាត់ រ័ត្នមុនី

http://cambodiapolice.com/policekh/ 3:36 pm 12 ធ្នូ 2018

(ភ្នំពេញ) មន្ត្រីជាន់ខ្ពស់អគ្គស្នងការដ្ឋាននគរបាលជាតិ បានបកស្រាយពន្យល់ជុំវិញការសុំរកកិច្ចសហប្រតិបត្តិការពីអាជ្ញាធរថៃ ក្នុងការប្រគល់ជនសង្ស័យផលិតវីដេអូឯកសារមិនពិតដែលធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់កិត្តិយសប្រទេសកម្ពុជា និងស្ត្រីខ្មែរ ។

គួររំលឹកថា ខ្សែវីដេអូឯកសារមិនពិតរឿង «ម្តាយខ្ញុំ លក់ខ្ញុំ» រៀបចំដោយឈ្មោះ រ៉ាត់ រ័ត្ន មុនី និងបានបង្ហោះតាមប្រព័ន្ធយូធូបនិងបណ្តាញសង្គមផ្សេងៗ បានធ្វើអោយសាធារណជន មានការយល់ច្រឡំអំពីរឿងហេតុ ដែលមិនមានការកើតឡើងសោះនោះទេ។ ខ្សែភាពយន្តឯកសារដែលមានរយៈពេល២៧នាទី ផ្សព្វផ្សាយដោយទូរទស្សន៍ Russia Today និងបានសង្ខេបមកនៅត្រឹមប្រមាណជាង២នាទី បានផ្តោត លើតួអង្គស្ត្រី៣នាក់ ដែលរួមមានម្តាយនិងកូនស្រីឈ្មោះកែវ ម៉ាឡៃ និងឈ្មោះ យៀង ស្រីម៉ិច និងស្ត្រីម្នាក់ទៀត ឈ្មោះ អ៊ុន ស្រីពេជ្រ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ បានមានប្រសាសន៍ក្នុងសន្និសីទកាសែតថ្ងៃទី១២ធ្នូឆ្នាំ២០១៨ នៅអគ្គស្នងការដ្ឋាននគរបាលជាតិបញ្ជាក់ថា ក្រោយការស្រាវជ្រាវរបស់សមត្ថកិច្ច ក្រុមជំនាញ គេបានសង្ស័យលើការផលិតឯកសារមួយគ្មានការពិត ដែលធ្វើអោយប៉ះពាល់យ៉ាងខ្លាំង ដល់កិត្តិយសប្រទេសកម្ពុជានិងស្ត្រីខ្មែរ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានថ្លែងថាខ្សែវីដេអូនោះ គឺបានបន្ទាបបន្ថោកដល់ស្ត្រីជាមាតា ដែលបានលក់ព្រហ្មចារីយ៍កូនស្រីរបស់ខ្លួន។

ក្រោយការស៊ើបអង្កេតនិងមានការបំភ្លឺពីស្ត្រី២នាក់ គឺម្តាយនិងកូនស្រី ឈ្មោះកែវ ម៉ាឡៃ និងឈ្មោះ យៀង ស្រីម៉ិច ការពិតបានបង្ហាញថា ពួកគេបានទទួលលុយចំនួន ២០០ដុល្លារ ជាថ្នូរនឹងការនិយាយកុហកក្នុងភាពយន្តឯកសារនេះ។ កញ្ញា យៀង ស្រីម៉ិច ក្រោយមកក៏បានបង្ហោះវីដេអូបកស្រាយក្នុងបណ្តាញសង្គមហ្វេសប៊ុកដែរថា សកម្ម ភាពរបស់នាងក្នុងភាពយន្តឯកសារនោះ គ្រាន់តែជាការសម្តែង មិនមែនជាការពិតឡើយ ហើយពាក្យសម្តីដែលនាងនិងម្តាយនាងនិយាយទាំងប៉ុន្មាន សុទ្ធតែទន្ទេញតាមអត្ថបទរៀបចំដោយឈ្មោះ រ៉ាត់ រ័ត្នមុនី តែប៉ុណ្ណោះ ។ យោងតាមស្ត្រីជាម្តាយនិងកូន បានប្រាប់សមត្ថកិច្ចថា ឈ្មោះ រ៉ាត់ រ័ត្នមុនី បានប្រាប់ពួកគេទាំង២ថា ការថតនោះ គឺក្នុងរឿង «ប្រទេសខ្មែរ ក្រោយរបបប៉ុលពត» ។ ក្នុងការល្បួងអោយពួកគេថតរឿងនោះទៀត ក៏មានជនបរទេស៤រូប ដែលបានជួយថតនិងរៀបចំឈុតឆាកអោយទាំងអស់ ។ ម្តាយនិងកូនស្រីឈ្មោះ កែវ ម៉ាឡៃ និងឈ្មោះ យៀង ស្រីម៉ិច បានស្នើអោយសមត្ថកិច្ចជួយរកយុត្តិធម៌អោយពួកគេដើម្បីភាពស្អាតស្អំ។

សេចក្តីរាយការណ៍បានបង្ហាញថា ខ្សែភាពយន្តដែលកុហកថារឿង «ប្រទេសខ្មែរ ក្រោយរបបប៉ុលពត» នោះ បានកែចំណងជើងក្លាយជារឿង «ម្តាយខ្ញុំ លក់ខ្ញុំ» ដែលបង្កអោយមានការយល់ច្រឡំពីសាធារណជន។ ឈ្មោះ រ៉ាត់ រ័ត្នមុនី និងភរិយា ឈ្មោះឡុង គឹមហ៊ាង ក្នុងពេលដែលខ្សែភាពយន្តឯកសារមិនពិតនេះបានបង្ហោះក្នុងបណ្តាញសង្គម និងធ្វើអោយមានការផ្អើលពីសាធារណជននោះ ពួកគេក៏បានគៀសខ្លួនចេញទៅប្រទេសថៃ ដើម្បីធ្វើការរកគេចខ្លួនចេញទៅរកប្រទេសទី៣។ អាជ្ញាធរកម្ពុជា បានស្វែងរកកិច្ចសហប្រតិបត្តិការពីអាជ្ញាធរថៃ ដើម្បីស្នើសុំឱ្យភាគីថៃបញ្ជូនលោក រ៉ាត់ រ័ត្នមុនី ដើម្បីធ្វើការសាកសួរអំពីការពិតក្នុងការផលិតវីដេអូរឿង «ម្តាយខ្ញុំ លក់ខ្ញុំ»។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានថ្លែងថា យោងតាមការស្រាវជ្រាវនិងសាក្សីបានរកឃើញថា គឺមានតែឈ្មោះ វ៉ាត់ វ័ន្នមុនី តែម្នាក់នោះទេ ដែលអាចបំភ្លឺក្នុងរឿងនេះបាន ទើបអាជ្ញាធរកម្ពុជាបានស្នើរកការកិច្ចសហប្រតិបត្តិការពីអាជ្ញាធរថៃនោះ។ សមត្ថកិច្ចនគរបាលកម្ពុជាបានរំពឹងថា ថៃដែលតែងមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយនឹងកម្ពុជា នឹងប្រគល់ជនសង្ស័យ វ៉ាត់ វ័ន្នមុនី នេះ អោយសមត្ថកិច្ចកម្ពុជានាពេលខាងមុខនេះដើម្បីស្វែងរកយុត្តិធម៌ដល់ស្ត្រីជាម្តាយនិងកូនស្រីទាំង២នាក់នេះ។ ភាពស្វះស្វែងរកយុត្តិធម៌របស់សមត្ថកិច្ចចំពោះស្ត្រីរងគ្រោះទាំង ២ ត្រូវបានស្ត្រីជាភរិយា ជនសង្ស័យឈ្មោះ ឡុង គឹមហ៊ាង បានចោទថា គឺជាអំពើអយុត្តិធម៌ចំពោះប្តីរបស់គាត់។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានមានប្រសាសន៍បដិសេធ។ អគ្គស្នងការរងនគរបាលជាតិ បានថ្លែងថា ផ្ទុយទៅវិញ «នោះគឺជាការរកយុត្តិធម៌ អោយប្តីរបស់គាត់នោះទៅវិញទេ។ ប្តីគាត់បានគេចខ្លួនមិនព្រមចូលមកបំភ្លឺសមត្ថកិច្ច។ យើងត្រូវតាមរកប្តីរបស់គាត់ដើម្បីចូលមកបំភ្លឺក្នុងរឿងនេះ។ យើងមិនមែនយកប្តីរបស់គាត់មកធ្វើទារុណកម្មនោះឡើយ។»

ឯកឧត្តម ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានថ្លែងថា ក្នុងនាមជាសមត្ថកិច្ច គឺ«យើងមានកិច្ចខិតខំប្រឹងប្រែងខ្លាំងណាស់។ វិធានការណ៍និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រឆាំងការជួញដូរមនុស្ស គឺបាននិងកំពុងតែអនុវត្តយ៉ាងសកម្ម។ រាជរដ្ឋាភិបាលថែមទាំងបានបង្កើតដល់គណៈកម្មការជាតិប្រឆាំងការជួញដូរមនុស្សនេះទៀតផង ដែលជាយន្តការថ្នាក់ជាតិមួយដែលបានដាក់ចេញនូវគោលនយោបាយជម្រុញអោយកម្លាំងអនុវត្តច្បាប់។»

នៅជាមួយគ្នានេះផងដែរ វិទ្យុខ្មែរមួយនៅក្រៅស្រុកមួយ បានសម្ភាសន៍ជាមួយនឹងតួអង្គស្រីម្នាក់ទៀត ឈ្មោះ អ៊ុន ស្រីពេជ្រ ដែលអះអាងវីដេអូដែលផលិតនោះ គឺជាសាច់រឿងពិតរបស់នាង។ តាមរយៈនោះទៀត ឈ្មោះអ៊ុន ស្រីពេជ្រ បានទទួចសុំអោយអាជ្ញាធរកម្ពុជា ទម្លាក់ចោលការចោទប្រកាន់បញ្ឈប់ការចង់ចាប់ខ្លួនជនសង្ស័យ វ៉ាត់ វ័ន្នមុនី។ មន្ត្រីសមត្ថកិច្ចនគរបាលបានថ្លែងថា ក្នុងរឿងទាក់ទងនឹងឈ្មោះ អ៊ុន ស្រីពេជ្រនោះ នគរបាលបានព្យាយាមស្វែងរកការបំភ្លឺផងដែរ ប៉ុន្តែមិនអាចទាក់ទងបាននោះឡើយ។ សមត្ថកិច្ចបានថ្លែងថា គេកំពុងមានការងឿងឆ្ងល់ដែរថា នារីឈ្មោះ អ៊ុន ស្រីពេជ្រ ដែលអះអាងថា នាងត្រូវគេលក់ខ្លួននោះ ចុះហេតុអ្វីបានជាស្ត្រីនោះ មិនមកប្តឹងកម្លាំងសមត្ថកិច្ចដើម្បីឲ្យជួយរកយុត្តិធម៌? និងហេតុអ្វីបែរជាទៅជាការពារឈ្មោះ វ៉ាត់ វ័ន្នមុនី ដែលជាអ្នកពង្រីករឿងអាស្រូវរបស់ខ្លួននាងនោះទៅវិញ?៕

## តុលាការផ្តន្ទាទោសបុរសអង់គ្លេស និងប្រពន្ធវៀតណាមដាក់ពន្ធនាគារ៥ឆ្នាំ លើបទល្មើសទិញពេស្យាចារកុមារ

https://www.chnchannel.com/ *ថ្ងៃទី* 12 *ខែ ធ្នូ ឆ្នាំ* 2018 39

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨នេះ លោកស្រី ថ្លាង ផាណែត ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី បានប្រកាសសាលក្រមសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំ ពីបទ ទិញពេស្យាចារកុមារ និងបទអូសទាញពេស្យាចារកុមារ។ សាលក្រមតុលាការក៏បាន បង្គាប់ឱ្យជនត្រូវចោទសងជម្ងឺចិត្តឱ្យកុមារីវៀតណាមប៣នាក់ ក្នុងទឹកប្រាក់ចំនួន១២,០០០ដុល្លារផងដែរ ហើយបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់បើជនជាប់ចោទកើតទុក្ខមិនសុខចិត្តនិងសាលក្រម ។

ជនជាប់ចោទដែលតុលាការផ្តន្ទាទោសមានទី១ឈ្មោះ Cliv Robert Kingsley អាយុ៦៨ឆ្នាំ ជនជាតិអង់គ្លេស ។ ទី២ឈ្មោះ ជា សុចាន់ធី អាយុ២៧ឆ្នាំ ជនជាតិវៀតណាម ។ Robert Kingsley និងជា សុចាន់ធី ត្រូវបានសមត្ថកិច្ចប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចាប់ខ្លួនកាលពីថ្ងៃទី ២៩មេសា ឆ្នាំ២០១៧ នៅក្នុងផ្ទះរបស់ពួកគេក្នុងសង្កាត់ទួទំពូង១ខណ្ឌចម្ការមន ជាមួយនិងកុមារីវៀតណាមក្មេងៗ៤នាក់ ។ ការចាប់ខ្លួនលោក រ៉ូបឺតនិងប្រពន្ធ ជន

ជាតិវៀតណាមដោយសារអោជ្ញាធររកឃើញថា លោករ៉ូប៊ីតបានអូសទាញកុមារីវៀតណាមក្មេងៗមកធ្វើជាកូនចិញ្ចឹម ហើយក៏ឆ្លៀតកេងប្រវ័ញ្ចផ្លូវភេទជាមួយក្មេងៗទាំងនោះ ។ នៅក្នុងសវនាការអេសាជារណៈកាលពីដើមខែធ្នូ លោក រ៉ូប៊ីត និងប្រពន្ធ របស់គាត់បានបដិសេធចំពោះការចោទប្រកាន់ ប៉ុន្តែលោកគ្មានភស្តុតាងដើម្បីដោះបន្ទុកទេ ៕ដោយ៖ អ៊ី បញ្ញា

## ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨

### លោក ស ខេង ៖ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 13 December, 2018

ភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តបន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបន្តខិតខំប្រឹងប្រែង ដើម្បីអោយប្រជានកម្ពុជា និងមនុស្សជាតិ ទទួលបានការគោរពសិទ្ធ សេចក្តីថ្លៃថ្នូ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនា។

ថ្លែងក្នុងពិធីអបអសាទរទិវា ជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ១២ ធ្នូ លើកទី១២ កាលពីសៀលថ្ងៃទី ១២ ខែធ្នូ នេះ នៅសាលមហោស្រពកោះពេជ្រ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកអំពើជួញដូរមនុស្សជាបទឧក្រិដ្ឋ និងប្តេជ្ញាចិត្តទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះឲ្យបានខ្លាំងក្លា ដោយមិនអនុញ្ញាត្តិឲ្យជនល្មើសមានឱកាសពង្រីកសកម្មភាពបង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះ។ លោកបញ្ជាក់ថា បទល្មើសជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្មឆ្លងដែន ដែលកាន់តែស្រួចស្រាល និងគ្រោះថ្នាក់ជាទីបំផុត ដល់មនុស្សជាតិ ជាពិសេស ក្នុងចំណោមពលករទេសន្តរអន្តោប្រវេសន៍ ដែលបានចាកចេញទៅធ្វើការងារនៅក្រៅប្រទេស និងជនភៀសខ្លួនទាំងក្មេងចាស់ប្រុសស្រីដោយមិនរើសមុខ។

ម្យ៉ាងវិញទៀត ជនល្មើសកាន់តែប្រហើន មានកលល្បិចកាន់តែខ្ពស់ មានណ្តាញប្រទាក់ក្រឡាគ្នាកាន់តែស្មុកស្មាញ ឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយ និងមានប្រព័ន្ធទាក់ទងកាន់តែទំនើបដែលបង្កការលំបាកដល់សមត្ថកិច្ច និងរដ្ឋាភិបាលនៃបណ្តាប្រទេសពាក់ព័ន្ធនានា ក្នុងការបង្ក្រាប និងផ្តន្ទាទោសជនល្មើសអោយមានប្រសិទ្ធភាព។ លោកបន្តថា ដើម្បីអោយប្រជនកម្ពុជា និងមនុស្សជាតិ ទទួលបានការគោរពសិទ្ធ សេចក្តីថ្លៃថ្នូ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនានេះ ដោយរួមសហកាជាមួយបណ្តាដៃគូពាក់ព័ន្ធនានាក្នុងតំបន់ និងលើពិភពលោក ដើម្បីរួមគ្នាបង្ក្រាបការជួញដូរមនុស្សគ្រប់រូបភាព និងផន្ទាទោសជនល្មើសអោយកាន់តែម៉ឺងម៉ាត់ ដើម្បីកាត់បន្ថយ និងលុបបំបាត់ប្រសិទ្ធភាពបទល្មើស។

ជាមួយគ្នានោះ សម្តេចក្រឡាហោម បានអំពាវនាវដល់បណ្តាប្រទេសពាក់ព័ន្ធទាំងអស់ ដែលបានចុះហត្ថលេខារួមគ្នាលើអនុស្សរណ និងកិច្ចព្រមព្រាងទ្វេភាគី ពហុភាគី ដើម្បីរួមគ្នាប្រឆាំងអំពើជួញដូរមនុស្ស គប្បីជំរុញការអនុវត្តន៍អោយមានប្រសិទ្ធភាព និងរួមគ្នាពិនិត្យលើចំណុចខ្វះខាតនៃកាអនុវត្ត ហើយរួមគ្នាកែលម្អអោយបានទាន់ពេលវេលា៕

### លោកស្រីជូ ប៊ុនអេង កំពុងធ្វើសន្និសីទ សារព័ត៌មាន ក្រោយចូលរួមប្រជុំ ទប់ស្កាត់ការ ជួញដូរមនុស្ស

https://www.dap-news.com/ ByID:112 Posted on 13 December 2018 | 15:56

ភ្នំពេញ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកស្រី ជូ ប៊ុនអេង នៅរសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨នេះ បាននឹងកំពុងធ្វើសន្និសីទសារ

ព័ត៌មាន ក្រោយចូលរួមកិច្ចប្រជុំ នៃការទប់ស្កាត់ការជួញដូរមនុស្សនៅប្រទេសម៉ារ៉ុក ស្តីពី"ដំណើរវេទិកាពិភពលោក ស្តីពីទេសន្តប្រវេស និងការអភិវឌ្ឍ" នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ៕

## កម្ពុជានិងបណ្តាប្រទេសនៅលើពិភពលោករួមគ្នាដោះស្រាយបញ្ហាទេសន្តរប្រវេសន៍

http://bayontv.com.kh/ 13/12/2018

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងថា នាពេលបច្ចុប្បន្ននេះប្រទេសកម្ពុជានិងបណ្តាប្រទេសនៅលើពិភពលោកទាំងអស់ បានកំពុងសហការរួមដៃគ្នា ដើម្បីដោះស្រាយបញ្ហាផ្សេងៗរបស់ទេសន្តរប្រវេសន៍ ខណៈករណីទេសន្តរប្រវេសន៍ គឺជាធនធានដ៏ធំមួយសម្រាប់អភិវឌ្ឍន៍ប្រទេសនីមួយៗ។ ថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយពីវិលត្រឡប់មកពីចូលរួម «វេទិកាពីភពលោក ស្តីពីទេសន្តរប្រវេសន៍ និង ការអភិវឌ្ឍន៍» និង«កិច្ចប្រជុំអន្តររដ្ឋាភិបាលជាន់ខ្ពស់ ដែលត្រូវអនុម័តលើកត្តិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍» នៅប្រទេសម៉ារ៉ុកនារសៀលថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០១៨នេះនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថាទាក់ទងនិងករណីទេសន្តរប្រវេសន៍ គឺបានកើនឡើងនៅលើពិភពលោក ដូច្នេះហើយ អ្នកដឹកនាំប្រទេសនីមួយៗបានកំពុងរួមគ្នាដោះស្រាយ ដើម្បីធ្វើយ៉ាងណាកុំឲ្យពួកគេមានបញ្ហាអ្វីកើនឡើងឬរំលោភសិទ្ធិរបស់ពួកគេនិងក្រុមគ្រួសារ។

លោកជំទាវ រដ្ឋលេខាធិការក៏បានឲ្យដឹងផងដែរថា វេទិកាពីភពលោក ស្តីពី ទេសន្តរប្រវេសន៍និង ការអភិវឌ្ឍន៍នេះគឺបានប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ គិតចាប់ ពីថ្ងៃទី ៥ ដល់ ៧ ខែ ធ្នូ ឆ្នាំ ២០១៨នឹងកិច្ចប្រជុំ អន្តររដ្ឋាភិបាលជាន់ខ្ពស់ ដែលត្រូវអនុម័តលើកត្តិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ មានរយៈពេល២ ថ្ងៃ គិតចាប់ពី ថ្ងៃ ទី ១០ ដល់ ១១ ខែ ធ្នូ ឆ្នាំ ២០១៨ដោយមានថ្នាក់ដឹកនាំនៃបណ្តាប្រទេសនៅលើពិភពលោកជិតពីររយប្រទេសចូលរួម។ លោកជំទាវបានបន្ថែមថា វេទិកានេះគឺបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ហើយក៏ជាការផ្លាស់ប្តូរការដោះស្រាយនូវបទពិសោធន៍នានាទាក់ទងនឹងបញ្ហាទេសន្តរប្រវេសន៍ពីបណ្តាប្រទេសនានាជូនដល់កម្ពុជាផងដែរ ខណៈបច្ចុប្បន្នប្រទេសកម្ពុជាមានប្រជាជនរបស់ខ្លួនធ្វើទេសន្តរប្រវេសទាំងស្របច្បាប់និងខុសច្បាប់ជាងមួយលាននាក់នោះ៕

## អារ៉ាប៊ីសាអូឌីត ស្នើឲ្យមានពលករខ្មែរ ទៅធ្វើការនៅ ប្រទេសខ្លួន

https://www.dap-news.com/ ByID:030 Posted on 13 December 2018 | 19:04

ភ្នំពេញ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ នៃគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងថា ថ្នាក់ដឹកនាំប្រទេសអារ៉ាប៊ីសាអូឌីត មានគោលបំណងស្នើសុំឲ្យ មានពលករខ្មែរទៅធ្វើការ នៅប្រទេសរបស់ខ្លួន ក្នុងពេលដែលពលករខ្មែរ បានចំណាកស្រុក ទៅធ្វើការនៅជាច្រើន តែសម្រាប់អារ៉ាប៊ីសាអូឌីត ពុំមានពលករខ្មែរ ពីមុនមកទេ។

ក្នុងសន្និសីទសារព័ត៌មាន ក្រោយចូលរួមកិច្ចប្រជុំ នៃការទប់ស្កាត់ការជួញដូរមនុស្ស នៅប្រទេស ម៉ារ៉ុក ស្តីពី "ដំណើរ វេទិកា ពិភពលោកស្តីពី ទេសន្តប្រវេស និងការអភិវឌ្ឍ" នៅរសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ លោកស្រី ជូ ប៊ុនអេង បានមានប្រសាសន៍ថា "ប្រទេសអារ៉ាប៊ីសាអូឌីតដែលបានជួបសន្ទនា ជាមួយខ្ញុំគាត់បានប្រាប់ថា អារ៉ាប់មានបំណងឲ្យមានពលករខ្មែរទៅធ្វើការនៅប្រទេសគាត់"។

ចំពោះ បញ្ហានេះ លោកស្រីក៏បានស្នើសុំឲ្យកំណត់ វិស័យទាំងឡាយដែលអាចបញ្ជូន ពលករ ទៅធ្វើការបាន ។ ក្នុងនោះលោកស្រីអះអាងថា ខាងអារ៉ាប៊ីសាអូឌីតបានឆ្លើយថា វិស័យដែលទៅ ធ្វើការនៅអារ៉ាប់ មិនមែនយកអ្នកគ្មានជំនាញទេ គឺអាចមានជាវិស្វករ ជំនួយការវិជ្ជសាស្ត្រ និងផ្នែក ផ្សេងៗទៀត ហើយក៏បានស្នើភាគីកម្ពុជា គួរតែត្រៀមខ្លួន

ឲ្យបានល្អ ក្នុងការបណ្ដុះបណ្ដាលនូវ ធនធាន របស់ខ្លួន ដើម្បីមានភាពងាយស្រួល ទៅធ្វើការនៅក្រៅប្រទេស ។ លោក ស្រីបន្ថែមថា កម្ពុជា-អារ៉ាប៊ីសាអូឌីតនឹងមានអនុស្សារណៈចុះកិច្ចព្រមព្រៀងជាមួយគ្នាដើម្បីការពារពលករ។ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក៏បានសង្កត់ធ្ងន់ថា ក្រោយមានសំណើបែបនេះ ក៏បានបញ្ជូនព័ត៌មានទៅក្រសួង ការងាររួចហើយ ដើម្បីត្រៀមខ្លួនជួបពិភាក្សាជាមួយសហភាពអារ៉ាប៊ីត ដែលចង់ឲ្យមានការជួបប្រជុំឆាប់ៗនេះ គឺយ៉ាងយូរ ត្រឹមត្រីមាសទីមួយ ឆ្នាំ២០១៩ ៕ ដោយ នឿត សម្ផស្ស

## តុលាការសាកសួរ ប្រធានសហជីពម្នាក់ ករណីផលិតខ្សែវីដេអូ "ម្ដាយខ្ញុំ លក់ខ្ញុំ"

https://www.dap-news.com/ ByID:112  Posted on 13 December 2018 | 16:39

ភ្នំពេញ ៖ នគរបាលក្រសួងមហាផ្ទៃ នៅរសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨នេះ បញ្ជូនប្រធានសហជីពកម្មករសំណង់ម្នាក់ ដែលមានមូលដ្ឋាននៅប្រទេសថៃ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសាកសួរករណី ផលិតខ្សែវីដេអូរឿង "ម្ដាយខ្ញុំ លក់ខ្ញុំ" ។

លោក លី សុផាណា អ្នកនាំពាក្យអយ្យការអមសាលា ដំបូងរាជធានីភ្នំពេញ បញ្ជាក់ថា ជនសង្ស័យក្នុងរឿងក្ដីនេះ ឈ្មោះ ប៉ាត់ រដ្ឋមុនី ត្រូវបានលោក ខៀវ ផល្លា ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ ធ្វើការសាកសួរ ។

កាលពីសប្ដាហ៍មុន អ្នកស្រី ឡុង គីមហ៊ាង ត្រូវជាភរិយាលោក ប៉ាត់ រដ្ឋមុនី បានប្រាប់អ្នកកាសែតថា ស្វាមីរបស់អ្នកស្រីឈ្មោះ ប៉ាត់ រដ្ឋមុនី ជាភ្នាក់ងារសារព័ត៌មានរុស្ស៊ីធូដេ RT ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ហើយបញ្ជូនមកឲ្យរាជរដ្ឋាភិបាលកម្ពុជាវិញតាមការស្នើសុំ ។ អ្នកស្រី ឡុង គីមហ៊ាង អះអាងថា ការចាប់ខ្លួនស្វាមីពាក់ព័ន្ធការផលិតវីឌីអូឯកសារមានចំណងជើងថា "ម្ដាយខ្ញុំលក់ខ្ញុំ" របស់សារព័ត៌មានរុស្ស៊ីធូដេ (RT)។

សូមបញ្ជាក់ថា "ម្ដាយខ្ញុំលក់ខ្ញុំ" និយាយពីស្ត្រីខ្មែរលក់កូនស្រីខ្លួនឯងដោយសារតែជីវភាពខ្វះខាត និងរៀបរាប់ពីស្ថានភាព នៃការប្រកបអាជីវកម្មផ្លូវភេទនៅកម្ពុជា បានធ្វើឲ្យរាជរដ្ឋាភិបាលខឹងសម្បារព្រោះជាការមួលបង្កាច់កិត្យានុភាព កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ស្ត្រីខ្មែរ ។ សមត្ថកិច្ចកម្ពុជាបានបកស្រាយថា វីឌីអូនោះគឺជាការប្រឌិតឡើងដើម្បីធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់កម្ពុជា ។

លោក ប៉ាត់ រដ្ឋមុនី ប្រធានសហព័ន្ធសហជីពកម្មករ សំណង់កម្ពុជា (CCTUF) ត្រូវបានអាជ្ញាធរថៃ ចាប់ខ្លួននៅក្នុងទីក្រុង បាងកក ប្រទេសថៃ កាលពីថ្ងៃទី៧ ធ្នូ ពាក់ព័ន្ធការផលិត យន្តឯកសារស្ដីពីការលក់ កូនស្រី។ ការចាប់ខ្លួននេះ គឺធ្វើឡើងតាមសំណើផ្លូវការ របស់អាជ្ញាធរកម្ពុជា៕ គិរី

## សង្គមស៊ីវិលរិះគន់របបក្រុងភ្នំពេញដែលមិនអាចទប់ស្កាត់ចំណាកស្រុកខុសច្បាប់បាន

https://www.rfa.org/khmer/news/ *ដោយ ម៉ៅ សុជានី* 2018-12-12

មន្ត្រីកម្មវិធីសិទ្ធិការងារនៃអង្គការសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថាសង់ត្រាល់(Central) លោក ឌី ថេហូយ៉ា និយាយថា កត្តាដែលជំរុញពលករខ្មែរចេញទៅធ្វើការងារនៅប្រទេសថៃខុសច្បាប់ព្រោះការបំពេញបំពេញឯកសារគឺភាគស្មុគស្មាញ ប្រើរយៈពេលយូរ និងចំណាយអស់លុយច្រើន។ ដូច្នេះមន្ត្រីសង្គមស៊ីវិលរូបនេះ យល់ថា ការទប់ស្កាត់ឬការមានវិធានការត្រឹមស្វែងចាប់មេខ្យល់គឺមិនទាន់គ្រប់គ្រាន់ទេះ «ឯកសារធ្វើម៉េចឲ្យមានគ្រប់គ្នាមានលទ្ធភាពធ្វើ រយៈពេលនៃភាពស្របច្បាប់កុំឲ្យវង់ចាំរយៈពេលវែងពេក ហើយកុំឲ្យមានភាពស្មុគស្មាញនៃការធ្វើឯកសារ និងអស់លុយច្រើនពេក»។លោកថា សមត្ថកិច្ចថៃកំពុងសម្រុកចុះចាប់ពលករខ្មែរដែលកំពុងធ្វើការ និងរស់នៅខុសច្បាប់លើទឹកដីថៃស្ទើររាល់ថ្ងៃ។ ជាងនេះទៅទៀត ពលករខ្មែរដែលត្រូវសមត្ថកិច្ចថៃចាប់ទៅដល់ទឹកដីខ្មែរហើយនោះពួកគេ

នៅតែបន្តលួចឆ្លង និងធ្វើការងារខុសច្បាប់ដដែល។ ប្រតិកម្មរបស់សង្គមស៊ីវិលដោយសារតែរបបក្រុងភ្នំពេញ ប្រកាសធ្វើយុទ្ធនាការបង្ក្រាប លើមេខ្យល់នាំពលករទៅធ្វើការងារនៅថៃខុសច្បាប់។

អ្នកនាំពាក្យរបបក្រុងភ្នំពេញ លោក ផៃ ស៊ីផាន បាននិយាយថា ដើម្បីទប់ស្កាត់ចំណាកស្រុកខុសច្បាប់របស់ពលករខ្មែរនៅប្រទេសនៅពេលនេះ សមត្ថកិច្ចកម្ពុជា កំពុងស្វែងរកចាប់មេខ្យល់ដែលនាំពលករទៅធ្វើការងារខុសច្បាប់នៅថៃ។ លោកបន្តថា ក្រុមមេខ្យល់ទាំងនេះគឺជាប្រភពដ៏សំខាន់មួយនៃការលួចនាំយកពលករទៅធ្វើការងារខុសច្បាប់៖ «ដើម្បីការពារនៃការជួញដូរនៃការជួញមនុស្សពីមេខ្យល់នៅក្នុងចំណុចឆ្លើយតបហ្នឹងយើងបានធ្វើការបង្ក្រាបមេខ្យល់»។

រីឯមន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា ឲ្យអាស៊ីសេរីដឹងថា ក្រុមពលរដ្ឋដែលត្រូវបញ្ជូនត្រឡប់មកកម្ពុជាទាំងនោះបាននាំគ្នាត្រឡប់ទៅធ្វើការងារនៅប្រទេសខុសច្បាប់វិញតាមច្រករបៀង។ លោកថា គឺអាជ្ញាធរនៅតាមច្រកទាំងនោះបានលុយពីពលករជាថ្នូរនៃការឆ្លងដែនខុសច្បាប់នេះ៖ «គឺទាក់ទងទៅតាមច្រកអូរបីជាន់ តាមច្រកម៉ាឡៃ ច្រកអូរជ្រៅក៏មានច្រើន អ្នកទទួលបានផលប្រយោជន៍ហ្នឹងធ្វើជាអ្នកមានអ្នកបានទិញឡានទិញអីជិះ»។

របាយការណ៍ក្រសួងមហាផ្ទៃបង្ហាញថា គិតត្រឹមពាក់កណ្ដាលឆ្នាំ២០១៨ ពលករខ្មែរ ១លាន ៥ម៉ឺននាក់ កំពុងបម្រើការងារនៅក្នុងប្រទេសថៃ ក្នុងនោះពលករស្របច្បាប់មានត្រឹមតែជិត ៥៥ម៉ឺននាក់ប៉ុណ្ណោះ។ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្ហាញរបាយការណ៍រយៈពេល១០ខែ ឆ្នាំ២០១៨ ថា សមត្ថកិច្ចថៃបានបញ្ជូនពលករខ្មែរដែលធ្វើការងារខុសច្បាប់នៅប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតជិត ៣ម៉ឺននាក់៕

## តុលាការសម្រេចឃុំខ្លួនអ្នកថតខ្សែភាពយន្ត "ម្ដាយខ្ញុំ លក់ខ្ញុំ" ក្នុងពន្ធនាគារជាបណ្ដោះអាសន្ន

http://kleykley.sabay.com.kh/ *ថ្ងៃនេះ ម៉ោង* 08:47

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឃុំខ្លួនលោក រ៉ាត់ រ័ត្នមុនី ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងជាអ្នកថតខ្សែភាពយន្តឯកសារ "ម្ដាយខ្ញុំ លក់ខ្ញុំ" ឱ្យសារព័ត៌មាន Russia Today (RT) ដាក់ពន្ធនាគារបណ្ដោះអាសន្ន និងចោទពីបទញុះញង់ឱ្យមានការរើសអើង។ ការសម្រេចនេះ ធ្វើឡើងកាលពីរសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨។

លោក លី សុផាណា ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យសាលាដំបូងរាជធានីភ្នំពេញ បានឱ្យដឹងថា តុលាការកំពុងពិនិត្យនិងចាត់ការសំណុំរឿងនេះ។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួន លោក រ៉ាត់ រ័ត្នមុនី បណ្ដោះអាសន្ន ពីបទញុះញង់ឱ្យមានការរើសអើង តាមបញ្ញត្តិមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌ។

យោងតាមមាត្រា៤៩៦ មានខ្លឹមសារថា៖ «បទញុះញង់ឱ្យមានការរើសអើងអំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា៤៩៤ នៃក្រមនេះ ធ្វើឱ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬហិង្សា ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិក នៃជាតិពន្ធ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយ ជាកំណត់នោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ៦លានរៀល ប្រសិនបើការញុះញង់នេះ គ្មានប្រសិទ្ធភាពទេ»។

លោក រ៉ាត់ រ័ត្នមុនី ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ខណៈដែលលោកកំពុងសុំទិដ្ឋាការទៅប្រទេសហុល្លង់។ បន្ទាប់មក លោកត្រូវបានបញ្ជូនមកដល់កម្ពុជា កាលពីយប់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។ បន្ទាប់ពីបញ្ជូនមកដល់កម្ពុជា សមត្ថកិច្ចបានបញ្ជូនខ្លួនលោក រ៉ាត់ រ័ត្នមុនី ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការសាកសួរអំពីដំណើររឿងនៃការថតខ្សែភាពយន្តឯកសារ "ម្ដាយខ្ញុំ លក់ខ្ញុំ"។

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ បានថ្លែងបញ្ជាក់នៅក្នុងសន្និសីទកាសែត កាលពីថ្ងៃទី១២ ខែធ្នូថា វីដេអូនេះ ត្រូវបានថតក្នុងចេតនាទុច្ចរិត បន្ថោកកិត្តិយសប្រទេសកម្ពុជា។ ហេតុនេះ ប៉ូលិស បានស្នើសុំព្រះរាជអាជ្ញា កោះហៅលោក រ៉ាត់ រ័ត្នមុនី មកបំភ្លឺ តែលោកបានគេចខ្លួនចេញទៅក្រៅប្រទេស។ ក្រោយ បំបែកសំណុំរឿងនេះ សមត្ថកិច្ចកម្ពុជា បានសុំកិច្ចសហការជាមួយសមត្ថកិច្ចថៃ ដើម្បីនាំខ្លួនលោក រ៉ាត់ រ័ត្នមុនី។

ខ្សែភាពយន្តឯកសារនេះ មានរយៈពេល ២៧នាទី ដោយបានរៀបរាប់លម្អិតអំពីគ្រួសារក្រីក្រនៅកម្ពុជា ដែល លក់ព្រហ្មចារីស្រីរបស់ពួកគេក្នុងតម្លៃប្រហែល ៤០០ដុល្លារក្នុងម្នាក់ៗ។ ខ្សែភាពយន្ត នេះបានបង្ហាញថានៅក្នុងក្លឹប រាត្រី និងខារ៉ាអូខេ ក្មេងស្រីជំទង់បានញ៉ាំភេសជ្ជៈ និងផ្តល់សេវាផ្លូវភេទដល់អតិថិជនបួនឬប្រាំនាក់ក្នុងមួយថ្ងៃ។ នៅ ក្នុងខ្សែភាពយន្តនេះ ក្មេងស្រីឈ្មោះ គៀង ស្រីម៉ិច បាននិយាយថា ម្តាយរបស់នាង បានបង្ខំឱ្យនាងចូលពេស្យាចារ។ នៅក្នុងក្លឹបខារ៉ាអូខេភ្ញៀវបានហៅឱ្យអង្គុយជាមួយពួកគេ។ ពួកគេបានឱ្យនាងផឹកស្រាបៀរ ជាមួយពួកគេ ដោយឱ្យនាង ពី ១០ ទៅ ២០ដុល្លារ ហើយប្រសិនបើទៅគេងជាមួយពួកគេ នោះនឹងទទួលបានច្រើនជាងនេះ៕ អត្ថបទ៖ សោភា

## ជប៉ុនប្រកាសទទួលពលករពីប្រទេសចំនួន៨ ក្នុងនោះក៏មានកម្ពុជាដែរ

http://mekong-post.com/ *ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី* 14 December, 2018

រដ្ឋាភិបាលជប៉ុន ប្រកាសទទួលយកជនបរទេស ក្នុងនាមជាពលករមានជំនាញជាក់លាក់ប្រមាណ ជាង១២ម៉ឺន ដល់១៥ម៉ឺននាក់ អាចមានសិទ្ធិរស់នៅក្នុងប្រទេសជប៉ុន។ រដ្ឋាភិបាលជប៉ុន បញ្ជាក់ថា ពលករមកពីប្រទេសចំនួន៨ ក្នុងនោះ ក៏មានពីប្រទេស វៀតណាម ហ្វីលីពីន និងកម្ពុជាផងដែរ។ ក្រៅពីនោះមាន ចិន ឥណ្ឌូនេស៊ី ថៃ និង មីយ៉ាន់ ម៉ា ដែលគម្រោងនេះ នឹងចាប់ផ្តើមដំណើរការនៅ ខែមេសា ឆ្នាំ២០១៩។

គួរបញ្ជាក់ដែរថា តាមរបាយការណ៍របស់ក្រសួងការងារនៃប្រទេសជប៉ុន បង្ហាញថា កាលពីឆ្នាំ ២០១៧ មានកម្ម សិក្សាការី ចំនួនជា ១លាន ៩សែននាក់ ដែលបំពេញការងារជាអ្នកថែទាំមនុស្សចាស់ នៅក្នុងប្រទេសជប៉ុន តែរដ្ឋាភិបា លជប៉ុននៅមានតម្រូវការការងារនេះ ប្រមាណ២លាន ៤ សែន នាក់បន្ថែមទៀត គិតដល់ឆ្នាំ២០២៥ខាងមុខ៕

## ៣នាក់បងប្អូនយំអង្វរឲ្យមហាជនជួយ ព្រោះថៅកែធ្វើបាបបង្ខំឲ្យដេកជាមួយភ្ញៀវ និង គំរាមដាក់គុក

http://khmer-global.com/ December 13, 2018

មិនថាអ្នកណានោះទេ កាលណាគ្រួសារមានលំបាកតែងតែតស៊ូរកការងារធ្វើផ្សេងៗទោះជិត ឬកន្លែងឆ្ងាយៗជា ច្រើនដូចជា នៅតាមទីក្រុង ឬអាចធ្វើចំណាកស្រុកទៅធ្វើការងារនៅប្រទេសគេទៀតផង។ កាលពីពេលថ្មីៗនេះមាន ករណីគួរឲ្យភ្ញាក់ផ្អើលមួយកើតឡើងដោយសារតែបងប្អូនបង្កើតស្រី ៣នាក់ជាកូនអ្នកកសិករ បានធ្វើការចែករំលែកវីដេ អូបង្ហាញពីទុក្ខលំបាករបស់ខ្លួនទៅឲ្យអ្នកលេងបណ្តាញសង្គមហ្វេសប៊ុកបានដឹងថា ដោយសារតែប្រាក់ជួយជីវភាព គ្រួសារមានការលំបាក ទើបសម្រេចចិត្តមកធ្វើការងារនៅទីក្រុងភ្នំពេញ ទាំង ៣នាក់បងប្អូនតែម្តង។

តែរឿងមិននឹកស្មាននោះបងស្រីទាំង ៣នាក់ មកធ្វើការចំកន្លែងមិនល្អដោយសារតែម្ចាស់ហាងតម្រូវឲ្យធ្វើការ ចាក់ស្រាឲ្យភ្ញៀវ អង្គុយកំដរភ្ញៀវ ផឹកស្រាជាមួយភ្ញៀវ ព្រមទាំងឲ្យភ្ញៀវឱបថើបសេរី និងគេងជាមួយភ្ញៀវទៀតផង។ ពួក គេបានប្រាប់ឲ្យដឹងទៀតថា ក្រោយពេលធ្វើការបែបនេះរយៈពេលខ្លី ពួកគេគិតថា វាមិនល្អហើយក៏មិនចង់ជ្រុលខ្លួន ជ្រៅជាងនេះ គាត់ទាំង៣ នាក់បានសម្រេចចិត្តដាក់ពាក្យឈប់ តែថៅកែមិនព្រមឲ្យឈប់ទេ ថែមទាំងដកហូតទូរសព្ទ គាត់ទាំង ៣នាក់ដែលភ្ញៀវទិញឲ្យ ហើយមិនបើកប្រាក់ខែឲ្យទៀតផង។

ឯរឿងមិននឹកស្មានមួយទៀតនោះ នារីទាំង ៣នាក់អះអាងថា ខ្លួនមិនខុសអ្វីសោះ បែរថៅកែហាងប្រើហិង្សាវ៉ៃ ប្អូនស្រីពីរដៃ ហើយគំរាមចាប់ដាក់គុកទាំងអស់គ្នាទៀត។ ប្រភពបានបញ្ជាក់ថា ហាងនោះមានឈ្មោះថា ភោជនីយ

ដ្ឋាន 168 មានទីតាំងស្ថិតនៅលើផ្លូវ 156 រាជធានីភ្នំពេញ។ សូមអំពាវនាវឲ្យអាជ្ញាធរមានសមត្ថកិច្ចចុះស៊ើបអង្កេតករណីនេះផង។ សេចក្តីលម្អិតមានក្នុងវីដេអូខាងក្រោម៕ (អត្ថបទ៖ និស្ស័យ Khmer-Global)

## រថយន្តឈ្នួលដឹកពលករខ្មែរទៅជាយដែនកើតគ្រោះថ្នាក់ចរាចរណ៍បណ្តាលអោយមានមនុស្សស្លាប់នៅកន្លែងកើតចំនួន០៣នាក់ និងរបួសធ្ងន់ចំនួន០៧នាក់

https://www.facebook.com/ *ពលករខ្មែរ* CMT ១៤/១២/២០១៨

រថយន្តឈ្នួលដឹកពលករខ្មែរទៅជាយដែនកើតគ្រោះថ្នាក់ចរាចរណ៍ បណ្តាលអោយមានមនុស្សស្លាប់នៅកន្លែងកើតចំនួន០៣នាក់ និងរបួសធ្ងន់ចំនួន០៧នាក់ ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះបានកើតឡើងកាលពីវេលាម៉ោង០៩:៤០នាទីព្រឹក ថ្ងៃសុក្រទី១៤ ខែធ្នូខែធ្នូ ឆ្នាំ២០១៨ នៅត្រង់ចំណុចស្រុកស្រះខ្វាន់ ខេត្តស្រះកែវ ប្រទេសថៃ។

## មន្ទីរការងារពិន័យចិនជាង ១ ពាន់នាក់ស្នាក់នៅធ្វើការងារដោយគ្មានចុះបញ្ជី

https://www.postkhmer.com/ *សុទ្ធ គឹមសឿន* | Publication date 14 December 2018 | 09:07 ICT

ស្វាយរៀង: ជនជាតិចិនចំនួនជាង ១ ពាន់នាក់ត្រូវបានផាកពិន័យ បន្ទាប់ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង និងសមត្ថកិច្ចចម្រុះបានរកឃើញថា កំពុងស្នាក់នៅ និងធ្វើការខុសច្បាប់នៅក្នុងកាស៊ីណូ ១ នៅក្រុងបាវិត។ យោងតាមលោក ហាស់ ប៊ុនធី ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាល និងវិជ្ជាជីវៈខេត្តស្វាយរៀង។ លោក ហាស់ ប៊ុនធី បានថ្លែងថាជនជាតិចិនចំនួន ១២៧៣ នាក់ក្នុងចំណោមជាង ២ ពាន់នាក់ត្រូវបានសមត្ថកិច្ចចម្រុះរកឃើញថា ពួកគេកាន់លិខិតឆ្លងដែនប្រភេទ E មកស្នាក់នៅប្រកបមុខរបរការងារគ្មានចុះបញ្ជី ឬធ្វើសៀវភៅការងារ។ ក្រោយពេលរកឃើញ មន្ត្រីជំនាញបានប្រាប់ និងណែនាំឲ្យពួកគេទៅបង់ប្រាក់ពិន័យ និងចុះបញ្ជីសៀវភៅការងារតាមច្បាប់នៅប្រទេសកម្ពុជា។ លោកបន្តថាការចុះធ្វើអធិការកិច្ចរកជនបរទេសរស់នៅ និងធ្វើការខុសច្បាប់ត្រូវបានធ្វើចាប់ពីដើមខែវិច្ឆិការហូតថ្ងៃទី ១១ ខែធ្នូ ហើយគ្រោងនឹងបញ្ចប់ទាំងស្រុងនៅទូទាំងក្រុងបាវិតនៅថ្ងៃទី ៣១ ធ្នូ ខាងមុខនេះ។ ក្រុងបាវិតមានកាស៊ីណូកំពុងដំណើរការចំនួន ១២ កាស៊ីណូក្នុងនោះជនបរទេសជាជនជាតិចិនភាគច្រើនធ្វើការងារនៅក្នុងកាស៊ីណូចំនួន ៣ រួមមាន កាស៊ីណូម៉ុកបាយ កាស៊ីណូហ្រ្គេន និងកាស៊ីណូឡឺម៉ាការ។

លោក ហាស់ ប៊ុនធី បានបញ្ជាក់ថា៖ «យើងមិនបានឃាត់ខ្លួនទេ គឺគ្រាន់តែតម្រូវឲ្យពួកគាត់បង់ប្រាក់ផាកពិន័យតាមច្បាប់ការងារកម្ពុជាយើង។ ឥឡូវពួកគាត់បាននាំគ្នាមកបង់ប្រាក់ និងធ្វើសៀវភៅការងារជាបណ្តើរៗហើយ។ យើងធ្វើបណ្តើរៗអ៊ីចឹងរហូតដល់ថ្ងៃទី ៣១ ធ្នូ ខាងមុខនេះព្រោះការងារនេះយើងត្រូវធ្វើជារៀងរាល់ឆ្នាំ»។ លោកបន្ថែមថាការងារនេះមានក្រុមការងារអធិការកិច្ចហត្ថពលកម្មបរទេសមកពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ, អគ្គនាយកដ្ឋានការងារ,ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរការងារ បណ្តុះបណ្តាល និងវិជ្ជាជីវៈ។

ចំណែកលោក អ៊ូ សុខឿន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបានឲ្យដឹងថាចាប់តាំងពីដើមឆ្នាំ ២០១៨ នេះមានជនបរទេសបានមកចុះបញ្ជីធ្វើសៀវភៅការងារក្នុងរដ្ឋបាលខេត្តស្វាយរៀងមានចំនួន ១១,០១៥ នាក់មាន ២៦ សញ្ជាតិក្នុងនោះភាគច្រើនជាជនជាតិចិន។ ក្នុងនោះមានជនបរទេសស្នាក់នៅប្រកបមុខរបររកស៊ី និងធ្វើការងារឆ្នាំ ២០១៨ នៅក្រុងបាវិតចំនួនជិត ២ ម៉ឺននាក់ ហើយមកធ្វើសៀវភៅការងារតែចំនួន ១១ ០១៥ នាក់ប៉ុណ្ណោះ ដូច្នេះជនបរទេសជាង ៨ ពាន់នាក់កំពុងប្រកបមុខរបររកស៊ី និងធ្វើការងារអត់ចុះបញ្ជីធ្វើសៀវភៅការងារនៅក្រុងបាវិត។

តាមសេចក្តីជូនដំណឹងរដ្ឋបាលខេត្តស្វាយរៀង បានចេញកាលពីដើមខែវិច្ឆិកានេះបង្ហាញថាម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ដែលកំពុងប្រកបអាជីវកម្មដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន

មណើយដ្ឋាន ម៉ាស្សា ខារ៉ាអូខេ ក្លិបកម្សាន្ត ឱស្ថថេក បៀរហ្គាដិន និងសេវាកម្មទេសចរណ៍ទាំងអស់ ដែលមានអាជ្ញាប័ណ្ណផុតសុពលភាពត្រូវប្រញាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណជាថ្មី។ ចំពោះអ្នកប្រកបអាជីវកម្មមិនធ្លាប់មានអាជ្ញាប័ណ្ណតាំងពីដើមត្រូវមកដាក់ពាក្យសុំអាជ្ញាប័ណ្ណឲ្យបានត្រឹមត្រូវតាមច្បាប់នៅអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្តស្វាយរៀង ឬនៅការិយាល័យច្រកចេញចូលតែ ១ ក្រុងបាវិត និងក្រុងស្វាយរៀងគិតចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ ជាកំណត់។ ចំពោះម្ចាស់អាជីវកម្មដែលមានអាជ្ញាប័ណ្ណផុតសុពលភាពម្ចាស់អាជីវកម្មទាំងនោះត្រូវដាក់ពាក្យសុំទៅក្រសួងទេសចរណ៍៕ Contact author: សុទ្ធ គឹមសឿន

## ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

### ពលករខ្មែរជាង៥០នាក់ត្រូវថៅកែបញ្ឈប់ពីការងារនិងមិនប្រគល់លិខិតឆ្លងដែនឲ្យពួកគេវិញ

https://www.rfa.org/khmer/ *ដោយ សេក បណ្ឌិត* 2018-12-16

ពលករខ្មែរធ្វើការងារនៅប្រទេសថៃឲ្យដឹងថា ថៅកែថៃបានបញ្ឈប់ពលករខ្មែរពីការងារជាង ៥០នាក់ និងមិនបានប្រគល់លិខិតឆ្លងដែនឲ្យពួកគេវិញនោះទេ។ សង្គមស៊ីវិលធ្វើការងារទាក់ទងសិទ្ធិពលករលើកឡើងថា នេះជាការរំលោភសិទ្ធិពលករធ្ងន់ធ្ងរ។ ពលករខ្មែរភាគច្រើនដែលត្រូវថៅកែបញ្ឈប់ពីការងារបានសម្រេចទៅប្រទេសកម្ពុជាវិញទាំងគ្មានលិខិតឆ្លងដែនក្នុងការធ្វើដំណើរ។ ពួកគេមិនហ៊ានបន្តរស់នៅប្រទេសថៃទៀតទេ ដោយខ្លាចសមត្ថកិច្ចថៃចាប់ខ្លួន។ ការបញ្ឈប់ពីការងារនេះ គឺធ្វើឡើងភ្លាមៗ មិនបានជូនដំណឹងទៅពលករឲ្យដឹងមុន ដើម្បីមានពេលរកការងារផ្សេងធ្វើនោះទេ។

តំណាងពលករខ្មែរ លោក រស់ ប៊ុនធឿន ប្រាប់អាស៊ីសេរីថា ពលករខ្មែរដែលត្រូវថៅកែបញ្ឈប់ពីការងារនោះភាគច្រើនជាពលករទើបមកធ្វើការងារមានរយៈ ពីរ ទៅបី ខែ និងមិនទាន់ពេញសិទ្ធិ។ លោកបន្តថា មូលហេតុដែលថៅកែដកហូតលិខិតឆ្លងដែនពីពលករខ្មែរនោះ ព្រោះគេលើកឡើងថា ពលករទាំងនោះជំពាក់ថ្លៃធ្វើលិខិតឆ្លងដែនរបស់ថៅកែរោងចក្រ៖ «យើងសុំលិខិតឆ្លងដែនក៏គេមិនឲ្យយើងដែរគេថាយើងមកធ្វើការអត់ទាន់គ្រប់លក្ខណៈការងារណាមួយគេអត់ទាន់កាត់លុយថ្លៃលិខិតឆ្លងដែនហ្នឹងដាច់»។ លោក រស់ ប៊ុនធឿន បន្តឲ្យដឹងទៀតថា រោងចក្រដែលបញ្ឈប់ពលករនោះជារោងចក្រដំឡើងគ្រឿងអេឡិចត្រូនិក ករណីនេះកើតឡើងតាំងពីអំឡុងខែវិច្ឆិកា។ លោកបន្តថា ទោះពលករខ្មែរមិនពេញចិត្តចំពោះការបញ្ឈប់នេះ ប៉ុន្តែពួកគេមិនដឹងថា ត្រូវរកអន្តរាគមន៍ពីស្ថាប័នណានោះទេ។ លោកបន្តថា រហូតមកដល់ពេលនេះ នៅសល់តែពលករជាង ១០នាក់ប៉ុណ្ណោះដែលបន្តរស់នៅខុសច្បាប់នៅប្រទេសដើម្បីស្វែងរកការងារថ្មី៖ «ពលករនៅសល់ជាង ១០នាក់អីដែរ អត់ទាន់ទៅពួកគេ មានប្ដីមានប្រពន្ធនៅថៃអ៊ីចឹងហើយអ្នកណាទៅគេជួលឡានគេទៅទាំងយប់អ៊ីចឹង»។

អាស៊ីសេរីមិនទាន់អាចមានមធ្យោបាយ ដើម្បីសុំការបំភ្លឺករណីនេះពីមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃបាននៅឡើយទេ នៅថ្ងៃទី១៦ ខែធ្នូ។ ចំណែកអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ក៏មិនអាចសុំការបំភ្លឺបានដែរ ដោយទូរស័ព្ទរបស់លោករោទ៍ជាច្រើនដងតែគ្មានអ្នកទទួល។

តំណាងពលករខ្មែរប្រចាំប្រទេសថៃ លោក លី រតនរស្មី ដែលតែងចេញមុខទាមទារការគោរពសិទ្ធិពលកររិះគន់ថា រាល់ពេលពលករខ្មែរនៅប្រទេសថៃជួបការរំលោភបំពានលើពលករខ្មែរលោកមិនដែលឃើញស្ថានទូតខ្មែរប្រចាំប្រទេសថៃ ជួយអន្តរាគមន៍បានម្ដងណាឡើយ។ ទោះបែបនេះក្ដីតំណាងពលកររូបនេះ ស្នើទៅក្រុមហ៊ុនដែលនាំពលករ

មកធ្វើការងារប្រទេសថៃត្រូវអន្តរាគមន៍ជួយដល់ពលករដែលបញ្ហាការងារដូចនេះ ព្រោះពលករខ្មែរបានចំណាយលុយច្រើនណាស់ទៅឲ្យក្រុមហ៊ុននោះ៖ «ជួបបញ្ហានេះរាប់ពាន់លើកទៅហើយប៉ុន្តែរាល់ការស្នើសុំពីពលករមិនដែលមានលទ្ធផល»។

មន្ត្រីកម្មវិធីសិទ្ធិការងារនៃអង្គការសម្ពន្ធភាពការងារនិងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ លោក ឌី ថេហូយ៉ា និយាយថា នេះការរំលោភសិទ្ធិពលករធ្ងន់ធ្ងរលើពលករ ហើយការបញ្ឈប់ការងារនេះទៀតសោតមិនមែនជាកំហុសរបស់ពលករថៃមទៀតផង។ លោកបន្តថា អង្គការរបស់លោកនឹងតាមដានករណីដោយចិត្តទុកដាក់ក្រោយទទួលបានព័ត៌មាននេះ៖ «អត់មានការងារធ្វើជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនដែលបញ្ជូនពលករនេះ ជាការទទួលខុសត្រូវដោះស្រាយឲ្យគាត់»។ មន្ត្រីសិទ្ធិមនុស្សរូបនេះយល់ថា ករណីនេះពលករខ្មែរ អាចដាក់ពាក្យប្ដឹង ដើម្បីទាមទារប្រាក់សំណង ឬរកដំណោះស្រាយសមរម្យណាមួយ ដើម្បីជួយដល់ពលករដែលរងការរំលោភបំពាននេះ៕

## ស្ត្រីខ្មែរនៅតែបន្តរងគ្រោះជួញដូរផ្លូវភេទទៅរៀបការជាមួយបុរសចិន

https://www.rfa.org/khmer/ *ដោយ ម៉ៅ សុជានី* 2018-12-15

សង្គមស៊ីវិលលើកឡើងថា ស្ត្រីខ្មែរជាច្រើនដែលមានអាយុចន្លោះពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ បន្តចាញ់បោកមេខ្យល់ថា នឹងមានអនាគតល្អនៅពេលរៀបការជាមួយបុរសជនជាតិចិន នៅប្រទេសចិន។ ក៏ប៉ុន្តែស្ត្រីជាច្រើនបានសម្រេចវិលត្រឡប់មកស្រុកកំណើតវិញ ដោយមិនអាចទ្រាំទ្រនូវការរំលោភបំពានរាល់ទម្រង់រូបភាព រួមមានការវាយធ្វើបាបរូបរាងកាយ ផ្លូវចិត្ត និងការបង្ខំរួមភេទ ជាដើម។ តើមូលហេតុអ្វី បានជាការជួញដូរស្ត្រីខ្មែរ ទៅរៀបការជាមួយបុរសចិន នៅតែបន្តកើតមានឡើង? សង្គមស៊ីវិលជាតិ និងអន្តរជាតិ លើកឡើងដូចៗគ្នាថា ប្រការដែលស្ត្រីខ្មែរនៅតែបន្តរងគ្រោះ ចាញ់ល្បិចមេខ្យល់ជួញដូរផ្លូវភេទ និងសុខចិត្តទៅរៀបការជាមួយបុរសចិន គឺដោយសារភាពក្រីក្រ កម្រិតការសិក្សាទាប និងក្ដីស្រម័យថា ខ្លួននឹងមានភ័ព្វវាសនាល្អ មានលុយកាក់ ជួយក្រុមគ្រួសារទីទាល់ក្រ។ ក៏ប៉ុន្តែស្ត្រីរងគ្រោះ ភាគច្រើនត្រឡប់មកកម្ពុជាវិញ គ្មានអ្វីទាំងអស់ ហើយខ្លះរហូតដល់ទុកកូនចោល ជាមួយក្រុមគ្រួសារខាងប្ដី ដោយមិនដឹងថា ពេលណា នឹងបានជួបកូនៗរបស់ពួកគេ។ បន្ថែមពីនេះ មានស្ត្រីខ្មែរខ្លះ ត្រូវរងគ្រោះក្នុងការជួញដូរផ្លូវភេទ ដោយសារបុរសចិនបានលក់នាងបន្តពីម្នាក់ទៅម្នាក់ទៀត។

ប្រធានបណ្ដាញកម្មករធ្វើការតាមផ្ទះនៃសមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ អ្នកស្រី វ៉ុន សម្ផស្ស បានប្រាប់អាស៊ីសេរី កាលពីថ្ងៃទី១១ ខែធ្នូ ថា តាមការជួបផ្ទាល់ជាមួយស្ត្រីរងគ្រោះដែលវិលត្រឡប់ពីប្រទេសចិនវិញ ពួកគេច្រើនមានជំងឺផ្លូវចិត្ត ដោយសាររងគ្រោះធ្ងន់ធ្ងរពីការវាយធ្វើបាប ផ្លូវកាយផ្លូវចិត្ត និងបង្ខំរួមភេទច្រើនដងក្នុងមួយថ្ងៃ។ មិនតែប៉ុណ្ណោះ ស្ត្រីទាំងនោះត្រូវបានបុរសជាប្ដី បង្ខាំងទុកឲ្យនៅតែក្នុងផ្ទះ ធ្វើការធ្ងន់ជាច្រើនម៉ោង មិនបានសម្រាក និងមិនអាចទាក់ទងក្រុមគ្រួសារនៅស្រុកកំណើត ឬមិត្តភ័ក្តិ ដែលស្គាល់ទៅប្រទេសចិនដូចគ្នា ពីព្រោះបុរសជាប្ដី ភ័យខ្លាចប្រពន្ធខ្លួនរត់ចោល៖ «គឺគាត់ប្រឈមបញ្ហាច្រើន។ អ្នកខ្លះទៅបម្រើការ ឬទៅរៀបការនៅស្រុកចិន ពេលមកស្រុកខ្មែរវិញ គឺគាត់មានបញ្ហាសតិ ដោយសារគេធ្វើបាប អ្នកខ្លះយកទៅបម្រើអ្នកជាបុរស ជាប្ដី និងក្រុមគ្រួសារ គឺថាគ្រាន់តែមានថា ការជាមួយយើង ប៉ុន្តែយកយើងទៅធ្វើបាបដដែល»។

អ្នកស្រី វ៉ុន សម្ផស្ស បន្តថា អត្រាជួញដូរស្ត្រីខ្មែរឲ្យទៅរៀបការនៅប្រទេសចិន នៅតែមានការកើនឡើងខ្លាំង ដោយសារភាគច្រើនមេខ្យល់ដែលបោកប្រាស់ ស្ត្រីក្មេងៗទាំងនោះ គឺច្រើនជាក្រុមគ្រួសារ និងជាអ្នកជិតខាងដែលពួកគេស្គាល់ច្បាស់ និងទុកចិត្តជាទីបំផុត៖ «សម្រាប់ខ្ញុំ ការចាញ់បោកទៅស្រុកចិន មិនចុះថយទេ គឺកាន់តែកើនឡើងថែម

ទៀតបច្ចុប្បន្ន។ ពួកគាត់នៅស្រុកស្រែចម្ការ ចាញ់បោកមេខ្យល់ ដែលត្រូវជាសាច់ញាតិគាត់ ដែលកុហកថា នៅពេលមានគ្រួសារនៅស្រុកចិនហើយ មិនលំបាកទេ។ ខ្លះថា ពេលបានប្ដីបរទេសនឹងបានជីវភាពធូរស្រាល។ ប៉ុន្តែជាតុពិតអត់មានអ៊ីចឹងទេ»។

កាសែតបាងកកប៉ុស្ដិ៍ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ បានចុះផ្សាយអត្ថបទមួយមានចំណងជើងថា «ការជួញដូរកូនក្រមុំ នៅតំបន់ទន្លេមេគង្គ» ដោយរៀបរាប់ពីស្ត្រីខ្មែររងគ្រោះម្នាក់ឈ្មោះ ណារី ដែលទើបត្រឡប់មកដល់កម្ពុជាវិញពីប្រទេសចិន និងមានកូនប្រុសម្នាក់ទុកចោលនៅជាមួយប្ដី ដោយមិនអនុញ្ញាតឲ្យយកមកជាមួយម្ដាយ។ ណារីចំណាយពេល៦ឆ្នាំ រស់នៅជាមួយស្វាមីជនជាតិចិន ហើយពេលរៀបការ នាងមានអាយុ ១៧ឆ្នាំ។ នាងបាននិយាយថា បងប្រុសបង្កើត បានលួងលោមនិងបញ្ឆោតនាងឲ្យយល់ព្រមរៀបការ។

ប្រភពដដែលឲ្យដឹងផងដែរថា បញ្ហារៀបការជាមួយបុរសជនជាតិចិន ដែលកូនក្រមុំមិនដែលស្គាល់មុខនេះ គឺមានកើតឡើងយ៉ាងច្រើននៅតំបន់ទន្លេមេគង្គ ក្នុងនោះ រួមមានប្រទេសកម្ពុជា វៀតណាម ឡាវ និងប្រទេសភូមា ដែលក្នុងមួយឆ្នាំៗ មានកូនក្រមុំក្មេងៗ រាប់ម៉ឺននាក់ សុខចិត្តទៅរៀបការជាមួយស្វាមីចិន ដោយរំពឹងថា នឹងមានវាសនាល្អ មានលុយមានកាក់ជួយក្រុមគ្រួសារទីទាល់ក្រ និងសងប្រាក់ជំពាក់មីក្រូហិរញ្ញវត្ថុ។ ប្រភពបន្តថា បុរសចិនម្នាក់ៗ ត្រូវចំណាយប្រាក់ពីចន្លោះ ១ម៉ឺន ដល់១ម៉ឺន ៥ពាន់ដុល្លារ ដើម្បីទិញស្ត្រីមកធ្វើជាប្រពន្ធ។ បញ្ហាដែលបុរសចិន នៅប្រទេសចិន មិនអាចរកស្ត្រីចិនដូចគ្នា រៀបការជាមួយបាន ដោយសារតែនយោបាយ «គ្រួសារមួយ កូនមួយ» របស់រដ្ឋាភិបាលចិន រយៈពេល ៣សតវត្សកន្លងមកនេះ បណ្ដាលឲ្យខ្វះស្ត្រី ដោយគ្រួសារនីមួយៗ ចង់បានតែកូនប្រុសស្នងត្រកូល។ ប្រភពដដែលបន្តថា ស្ត្រីខ្លះដែលត្រូវបានមេខ្យល់ឆបោកថា អាចរកការងារធ្វើបានប្រាក់ខែច្រើន បែរជាត្រូវបានចាប់បង្ខំឲ្យរៀបការ និងត្រូវបានជួញដូរ ធ្វើជាស្ត្រីពេស្យាផងដែរ។ បន្ថែមពីនេះ ស្ត្រីរងគ្រោះទាំងនោះ ត្រូវបានអាជ្ញាធរចិន ចាប់ដាក់ពន្ធនាគារ ដោយសារគ្មានលិខិតឆ្លងដែនជាដើម។

អាស៊ីសេរីបានព្យាយាមទាក់ទង អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃលោកស្រី ជូ ប៊ុនអេង ជាច្រើនដងតាមទូរស័ព្ទតែគ្មានអ្នកទទួល។ ក៏ប៉ុន្តែលោកស្រី ជូ ប៊ុនអេង បានប្រាប់កាសែតបាងកកប៉ុស្ដិ៍ថា ពាណិជ្ជកម្មអាពាហ៍ពិពាហ៍នេះ កំពុងរីករាលដាលយ៉ាងខ្លាំង ហើយបញ្ហាធំបំផុត គឺលុយនេះហើយ ដែលជំរុញស្ត្រីខ្មែរសុខចិត្តទៅរៀបការជាមួយបុរសចិន។ លោកស្រីបញ្ជាក់ថា ស្ត្រីវ័យក្មេង និងស្រស់ស្អាត គឺមានតម្លៃខ្ពស់។ លោកស្រី ជូ ប៊ុនអេង បន្តថា តួលេខផ្លូវការរបស់ក្រសួងមហាផ្ទៃ បង្ហាញថា ស្ត្រីខ្មែរចំនួន ១ម៉ឺននាក់ បានចុះឈ្មោះក្នុងបញ្ជីរៀបការជាមួយបុរសចិន នៅបណ្ដាខេត្ត ហ្គួងដុង (Guandong) ហ្គីយូ (Guizhou) និងខេត្តយូណាន (Yunnan) នៃប្រទេសចិន។ ស្ត្រីក្មេងៗនិងស្រស់ស្អាតទាំងនោះរំពឹងថា ខ្លួននឹងមានវាសនាល្អអាចរស់នៅសុខដុមរមនា ជាមួយប្ដីជនជាតិចិន និងអាចសន្សំប្រាក់ យកមកផ្គត់ផ្គង់ក្រុមគ្រួសារទីទាល់ក្រ។

របាយការណ៍របស់អង្គការសហប្រជាជាតិប្រឆាំងការជួញដូរមនុស្ស ឲ្យដឹងថា ក្នុងអំឡុងឆ្នាំ២០១៥ មានស្ត្រីខ្មែរចំនួន ៨៥នាក់ ត្រូវបានជួយអន្តរាគមន៍និងដឹកត្រឡប់មកកម្ពុជាវិញ ក្រោយដែលស្ត្រីទាំងនោះ ត្រូវបានលក់ និងបង្ខំឲ្យរៀបការជាមួយបុរសចិន។ ស្ត្រីទាំងនោះ មានអាយុចន្លោះពី ១៨ឆ្នាំ ទៅ៣៥ឆ្នាំ ដែលភាគច្រើនចាញ់បោកមេខ្យល់ ដែលរស់នៅក្នុងសហគមន៍ជាមួយគេ។ ប៉ុន្តែកម្ពុជាមិនមានស្ថិតិច្បាស់លាស់ពីអត្រាស្ត្រីខ្មែរចេញទៅរៀបការជាមួយបុរសចិនក្នុងមួយឆ្នាំៗ និងត្រូវបានជួយសង្គ្រោះឲ្យវិលត្រឡប់មកកម្ពុជាវិញ ក្រោយទទួលរងការធ្វើបាប និងជួញដូរផ្លូវភេទទេ។

នាយិកាប្រតិបត្តិនៃអង្គការសីលការ លោកស្រី ធីតា យ៉ះ មានប្រសាសន៍ប្រាប់អាស៊ីសេរីថា អាជ្ញាធររបបក្រុងភ្នំពេញ ត្រូវពង្រឹងនិងពង្រីកវិធានការតឹងរ៉ឹងបន្ថែម ដើម្បីទប់ស្កាត់ការជួញដូរនិងការពារដល់ជនរងគ្រោះ។ លោកស្រីបន្តថា អាជ្ញាធរត្រូវតែយកចិត្តទុកដាក់ បំបាត់ឲ្យអស់នូវមេខ្យល់ដែលទៅឃោសនាបោកប្រាសនិងភូតកុហក នៅតាមភូមិ-ឃុំ បន្ថែមទៅនឹងបង្កើតកម្មវិធីផ្តល់ព័ត៌មាននិង ជួយសង្គ្រោះនៅតាមស្ថានទូត និងកុងស៊ុល នៅក្នុងប្រទេសចិន៖ «ខ្ញុំចង់ផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល ឲ្យលុបបំបាត់មេខ្យល់ដែលជាអ្នកដើរប្រមូលមនុស្ស ឲ្យបានច្រើនបំផុត។ ហើយបង្កើតជាមជ្ឈមណ្ឌលផ្សេងៗ ដើម្បីផ្តល់ប្រឹក្សាដល់អ្នកដែលចង់ទៅ ឲ្យបានដឹងច្បាស់ពីគ្រោះថ្នាក់ និងការប្រថុយប្រថាននេះ ព្រោះថាឥឡូវនេះ គឺមានទៅឆ្លងដែនតាមស្រុកយួនផង។ ហើយបន្ថែមនេះ ត្រូវមានភារៈជារី នៅស្ថានទូតសម្រាប់ទទួលបណ្តឹងពីជនរងគ្រោះ»។ ការឆបោកស្ត្រីខ្មែរទៅរៀបការនឹងជនជាតិចិន ធ្វើឡើងដោយមានបណ្តាញច្បាស់លាស់។

របាយការណ៍ស្រាវជ្រាវរបស់សមាគមសិទ្ធិមនុស្សអាដហុក (Adhoc) បានរកឃើញថា ក្រុមមេខ្យល់ បានរៀបចំជាពីរដំណាក់កាល។ ដំណាក់កាលទី១ មេខ្យល់បានចងក្រងគ្នាជាបណ្តាញ ដោយមួយក្រុមនៅក្នុងប្រទេសកម្ពុជា និងមួយក្រុមទៀតនៅប្រទេសចិន។ ក្រុមទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយឪពុកម្តាយ និងជនរងគ្រោះផ្ទាល់។ ក្រុមនៅក្នុងប្រទេស មេខ្យល់មានគ្នាច្រើន ដើរតាមភូមិ ឃុំ និងរោងចក្រកាត់ដេរ ដើម្បីបង្អុតពីកូនចៅ ឬសាច់ញាតិរបស់ខ្លួន ដែលមានប្តីជាជនជាតិចិន មានជីវភាពធូរធារ និងមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ដំណាក់កាលទី២ ក្រុមមេខ្យល់ទាំងនោះ បានរៀបចំលួចបញ្ជូនស្ត្រីរងគ្រោះឆ្លងប្រទេសដោយធ្វើលិខិតឆ្លងដែនទិដ្ឋាការនិងឯកសារអត្តសញ្ញាណប័ណ្ណ ដែលភាគច្រើនធ្វើដោយក្លែងបន្លំឈ្មោះ អាយុ និងអាសយដ្ឋានរបស់ជនរងគ្រោះ។ ករណីខ្លះស្ត្រីទាំងនោះ ត្រូវជិះយន្តហោះតាមច្រកអន្តរជាតិភ្នំពេញ និងករណីខ្លះទៀត ត្រូវបានមេខ្យល់ជាជនជាតិខ្មែរ ចិន និងវៀតណាម នាំចេញតាមច្រកព្រំដែនបាវិត ឬច្រកប្រទេសឡាវ។

## គ្រូពេទ្យជនជាតិអង់គ្លេសម្នាក់ជាប់ចោទពីបទរួមភេទជាមួយក្មេងស្រីមិនទាន់គ្រប់អាយុ

https://www.rfa.org/khmer/ *ដោយ ថន ថារ៉ូ* 2018-12-16

សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោសបុរសវ័យចំណាស់ និងជាវេជ្ជបណ្ឌិតជនជាតិអង់គ្លេសម្នាក់ ឲ្យជាប់ពន្ធនាគារ៥ឆ្នាំ ករណីរួមភេទនឹងកុមារីចាប់ពីអាយុ ៩ និង ១៣ឆ្នាំ។ លោក ខ្លីវ គ្រេស៊ី (Clive Cressy) អាយុ៧០ឆ្នាំ ធ្លាប់បង្រៀនភាសាអង់គ្លេសនៅកម្ពុជា ត្រូវបានអាជ្ញាធរកម្ពុជាចាប់ខ្លួននៅក្នុងផ្ទះជួលរបស់លោក ជាមួយប្រពន្ធជនជាតិវៀតណាម ដែលបានទាក់ទងក្មេងស្រីវៀតណាម មិនទាន់គ្រប់អាយុមកអោយរួមភេទជាមួយប្តីរបស់ខ្លួន ។ តុលាការរកឃើញថា លោក ខ្លីវ គ្រេស៊ី បានចំណាយប្រាក់រហូតដល់ ៣ពាន់ដុល្លារ ដល់ជនរងគ្រោះក្នុងការរួមភេទនៅពេលលោកមានចំណង់។ ជនរងគ្រោះជាកុមារទាំងនោះ ត្រូវបានបុរសរូបនេះនិងភរិយាយកមករស់នៅផ្ទះជាមួយ មុនពេលពួកគេត្រូវបានរំលោភផ្លូវភេទ។ លោក ខ្លីវ គ្រេស៊ី នឹងត្រូវបណ្តេញពីកម្ពុជាក្រោយពេលចេញពីពន្ធនាគារ។

តាមកាសែតបរទេស The Argus ស្រង់សម្តីមន្ត្រីតុលាការថា បុរសគ្រូពេទ្យជនជាតិអង់គ្លេសរូបនេះ បានចូលមករស់នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៥។ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ មន្ត្រីនគរបាលកម្ពុជា បានចូលទៅរំដោះក្មេងស្រីទាំងនោះក្នុងផ្ទះជួលរបស់ជនល្មើស ហើយចាប់បុរសរូបនេះ។ ចំណែកឯប្រពន្ធល្មើសនៅពេលនោះ បានរត់គេចខ្លួន តែត្រូវបានអាជ្ញាធរចាប់បានវិញ កាលពីខែមិថុនា ឆ្នាំ២០១៨នេះ។

# ចោរសាច់ញាតិមិនអស់ចិត្តបោកប្រពន្ធខ្លួនឯងយកទៅរៀបការជាមួយបរទេសជាថ្នូរលុយ ជិត២ម៉ឺនដុល្លារ

http://nokorwatnews.com/ 16/12/2018

ខេត្តសៀមរាបៈ កាលពីរសៀលថ្ងៃសុក្រ ៧ កើត ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០១៨ ជនរងគ្រោះបួននាក់ដែលជាក្រុមសាច់ញាតិ បាននាំគ្នាទៅដាក់ពាក្យបណ្តឹងនៅតុលាការ សុំទាមទារសំណងលុយសរុបជិត១០ម៉ឺនដុល្លារ ពីជនសង្ស័យម្នាក់ដែលបានឆបោកពួកគាត់មុនពេលសមត្ថកិច្ចចាប់ខ្លួន ។ មិនតែប៉ុណ្ណោះជនសង្ស័យថែមទាំងបានបោកប្រពន្ធរបស់ខ្លួនដោយយកនាងទៅឲ្យរៀបការជាមួយប្រុសផ្សេង នៅឯក្រុងភ្នំពេញជាថ្នូរនឹងទឹកប្រាក់ជិត២ម៉ឺនដុល្លារ ក្រោមរូបភាពរៀបការ ដើម្បីទៅនៅប្រទេសក្រៅទៀតផង ។

មន្ត្រីតុលាការខេត្តសៀមរាបបានឲ្យដឹងថា ជនសង្ស័យ ឈ្មោះ មាស រិទ្ធី ហៅ សែម សំណាង ភេទប្រុស អាយុ ៣៣ឆ្នាំ មានស្រុកកំណើតស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ កំពុងជាប់ពន្ធនាគារខេត្តសៀមរាប បន្ទាប់ពីសមត្ថកិច្ចខេត្តសៀមរាបចាប់ខ្លួន កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៨ តាមបណ្តឹងប្រពន្ធរបស់ខ្លួន (សុំមិនបញ្ចេញឈ្មោះ)។រីឯជនរងគ្រោះចំនួន៤នាក់ ដែលបានមកដាក់ពាក្យបណ្តឹងនៅតុលាការនោះ ទី១ឈ្មោះ ប៉េះ ណូ ភេទប្រុស, ទី២ ឈ្មោះ កាន់ ផម ភេទប្រុស, ទី៣ឈ្មោះ ផម ច្រិច ភេទស្រី និងទី៤ឈ្មោះជា សុខា ភេទស្រី។ ពួកគាត់មានទីលំនៅភូមិស្ទឹងថ្មី សង្កាត់ស្វាយដង្គំ ក្រុង/ខេត្តសៀមរាប។

ក្នុងបណ្តឹងរបស់ជនរងគ្រោះទាំង៤ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ សុទ្ធតែមានខ្លឹមសារដូចៗគ្នា ដោយប្តឹងឈ្មោះ មាស រិទ្ធី ហៅ សែម សំណាង ភេទប្រុសអាយុប្រហែល៣៣ឆ្នាំ បច្ចុប្បន្នកំពុងស្ថិតនៅក្នុងពន្ធនាគារខេត្តសៀមរាប ពីបទឆបោកប្រព្រឹត្តនៅក្រុងសៀមរាប កាលពីអំឡុងឆ្នាំ២០១៤ ហើយពួកគាត់ទាមទារសំណងសរុប៨ម៉ឺនដុល្លារ ដែលក្នុងនោះពីរនាក់២ម៉ឺនដុល្លារនិងពីរនាក់ទៀត៦ម៉ឺនដុល្លារ និងសុំឲ្យតុលាការផ្តន្ទាទោសជនឆបោកទៅតាមច្បាប់ ដោយសារចាញ់បោកជននេះតាមរយៈនាំទិញដីនិងបានតម្រូវឲ្យយកលុយទៅកក់ ម្តងពីរទៅបីពាន់ដុល្លារ រហូតអស់៨ម៉ឺនដុល្លារ។ លុះពេលទៅមើលដីជននោះកុហកថាជាប់រវល់រហូត។។

ប្រភពដដែលបានឲ្យដឹងទៀតថា ក្រុមជនរងគ្រោះបញ្ជាក់ប្រាប់ថា ក្រោយពេលបោកពួកគាត់រួចហើយ ជនខាងលើបានបោកប្រពន្ធរបស់ខ្លួនទៀត គឺបោកនាងយកទៅឲ្យរៀបការជាមួយប្រុសផ្សេង នៅឯក្រុងភ្នំពេញជាថ្នូរនឹងទឹកប្រាក់ជិត២ម៉ឺនដុល្លារ ក្រោមរូបភាពរៀបការដើម្បីទៅនៅប្រទេសក្រៅ។ តាមពិតជននេះ បានរៀបការជាមួយនាង ថែមទាំងមានចំណងដៃកូនតូចម្នាក់ទៀតរួចទៅហើយ។ក្រោយដឹងថា ប្តីរបស់ខ្លួនបានបោកប្រាស់ ដោយនាំយកទៅលក់ និងដោយអត់ទ្រាំនឹងទង្វើបែបនេះមិនបាន ទើបប្រពន្ធសម្រេចប្តឹងឲ្យសមត្ថកិច្ចចាប់ខ្លួននៅថ្ងៃ១៤ខែធ្នូឆ្នាំ២០១៨តែម្តង។សហការី

## រដ្ឋាភិបាលអារ៉ាប់រួម ស្នើឲ្យមានពលករខ្មែរ ទៅធ្វើការនៅទីនោះ

http://wmc.org.kh/ *ថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១៨ លៀ ស៊ីណា*

ភ្នំពេញ ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ នៃគណៈកម្មការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ប្រទេសអារ៉ាប់រួម (The United Arab Emirates ) មានបំណងចង់ឲ្យមានពលករខ្មែរ ទៅធ្វើការងារនៅប្រទេសរបស់ពួកគេ។ លោកស្រីបញ្ជាក់ថា ប្រទេសប្រទេសអារ៉ាប់រួម បានស្នើសុំជួប

ក្រសួងការងារដើម្បីពិភាក្សាលើកិច្ចការនេះ នៅក្នុងពេលឆាប់ៗ។ ការបញ្ជាក់របស់លោកស្រី ជូ ប៊ុនអេង ធ្វើឡើងកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ក្នុងសន្និសីទសារព័ត៌មានមួយនៅរាជធានីភ្នំពេញ ក្រោយពីលោកស្រី បានចូលរួមកិច្ចប្រជុំនៃការទប់ស្កាត់ការជួញដូរមនុស្សនៅប្រទេសម៉ារ៉ុក។ ប្រធានបទក្នុងកិច្ចប្រជុំដែលលោកស្រីរដ្ឋលេខាធិការក្រសួងមហាផ្ទៃទៅចូលរួមនោះគឺ ស្តីពី "ដំណើរវេទិកាពិភពលោកស្តីពី ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍន៍"។ លោកស្រីបានប្រាប់ឲ្យដឹងថា គណៈប្រតិភូនៃប្រទេសអារ៉ាប់រួម (The United Arab Emirates ) បានជួបលោកស្រីនៅប្រទេសម៉ារ៉ុក ដោយបញ្ជាក់ថា រដ្ឋាភិបាលអារ៉ាប់រួម មានបំណងស្នើសុំឲ្យមានពលករខ្មែរទៅធ្វើការនៅប្រទេសអារ៉ាប៊ីសារអូឌីត ៖«ចាស នៅក្នុងពេលដែលយើងបានទៅចូលរួមជាសមាជិកនៅក្នុងកិច្ចប្រជុំពិភពលោកនេះ។ យើងបានជួបជាមួយគណៈប្រតិភូនៃប្រទេសអារ៉ាប់រួម ដែលយើងហៅថា សហភាពអារ៉ាប់សារអូឌីត ដែលបានជួបសន្ទនា ដោយសារយើងគ្មានតំណាងខាងក្រសួងការងារទៅជាមួយ គឺគាត់បានជួបសន្ទនាដោយប្រាប់ថា អារ៉ាប៊ីមានគោលបំណងស្នើសុំជាពលករទៅធ្វើការនៅប្រទេសគាត់»។

អំឡុងនៃការជួបពិភាក្សាជាមួយ គណៈប្រតិភូប្រទេសអារ៉ាប់រួមនោះ លោកស្រី ប៊ុនអេង បានប្រាប់ឲ្យភាគីអារ៉ាប់រួម រៀបចំប្រាប់មកកម្ពុជា ឲ្យបានជាក់លាក់ពីវិស័យដែលប្រទេសអារ៉ាប់រួម មានបំណងទទួលយកពលករខ្មែរទៅធ្វើការ។ ជាការឆ្លើយតប មន្ត្រីរបស់ភាគីអារ៉ាប់រួម បានបញ្ជាក់ថា រដ្ឋាភិបាលអារ៉ាប់រួម មានបំណងទទួលយកពលករពីកម្ពុជា នៅលើច្រើនវិស័យ ហើយទទួលយកទាំងពលករគ្មានជំនាញ និងមានជំនាញ ៖«គាត់បានប្រាប់ថា វិស័យដែលទៅធ្វើការនៅប្រទេសអារ៉ាប់គឺមិនមែនយកតែអ្នកដែលគ្មានជំនាញទេ ចាស គឺអាចមានជាវិស្វករ ជំនួយការវិជ្ជសាស្ត្រ និងផ្នែកផ្សេងៗទៀតដែលលោកស្នើសុំថាកម្ពុជា គួរតែត្រៀមខ្លួនឲ្យបានល្អនៅក្នុងការបណ្តុះបណ្តាលធនធានរបស់ខ្លួននៅក្នុងទៅធ្វើការងារនៅក្រៅប្រទេស»។

ជុំវិញរឿងនេះ យោងតាមគេហទំព័រ Arabian Business បានផ្សាយកាលពីថ្ងៃទី១២ ខែធ្នូ បញ្ជាក់ថា រដ្ឋាភិបាលអារ៉ាប់រួម បានស្នើសុំឲ្យមានពលករបរទេសចូលប្រទេសរបស់ពួកគេ មិនមែនមានតែកម្ពុជាមួយទេ ពោលគឺមានប្រទេសមួយចំនួនទៀត ដែលមានដូចជា Rwanda, Nepal និងប្រទេសកម្ពុជា។

លោក Nasser bin Thani Al Hamli រដ្ឋមន្ត្រីធនធានមនុស្ស និង Emiratization របស់ប្រទេសអារ៉ាប់រួម បានប្រាប់សារព័ត៌មានថា ការស្នើឲ្យមានពលករបរទេសពីកម្ពុជា រ៉ាវ៉ាន់ដា និងប្រទេសនេប៉ាល់ នាពេលនេះ គឺដោយសារតែរដ្ឋាភិបាលនៃប្រទេសអារ៉ាប់រួម (The United Arab Emirates ) មានបំណងក្នុងការបង្កើនចំណងទាក់ទងក្នុងភាពជាដៃគូទ្វេភាគីឲ្យកាន់តែមានភាពល្អប្រសើរឡើង។

តែយ៉ាងណា លោកស្រី ជូ ប៊ុនអេង បានសង្កត់ធ្ងន់ថា មុនឈានដល់ការចុះអនុស្សរណៈទាក់ទិនការបញ្ជូនពលករនេះ កម្ពុជា និងរដ្ឋាភិបាល នៃប្រទេសអារ៉ាប់រួម ក៏នឹងមានកិច្ចព្រមព្រៀងផ្សេងៗ ដើម្បីធានា ការពារពលករពេលខ្មែរដែលទៅធ្វើការនៅទីនោះ។ លោកស្រីអះអាងថា ពេលនេះលោកស្រីបានជម្រាប់រឿងនេះ ទៅដល់ក្រសួងការងារហើយ ដើម្បីរៀបចំជួបពិភាក្សាជាមួយភាគីអារ៉ាប់រួម នៅក្នុងពេលខាងមុខ៕

# ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨

## ខេត្តសៀមរាបប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ

http://information.gov.kh/ *ថ្ងៃទី 18 ខែ ធ្នូ ឆ្នាំ 2018*

AKP សៀមរាប ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ខេត្តសៀមរាបបានប្រារព្ធទិវាជាតិលើកទី១២ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការនិមន្ត អញ្ជើញចូលរួមពីព្រះមេគុណខេត្ត ឯកឧត្តម លោកជំទាវ គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត អស់លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាពនានាជុំវិញខេត្ត បណ្តាអង្គការសង្គមស៊ីវិល មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូអ្នកគ្រូ និស្សិត ក្រុមយុវជនកាយឬទ្ធិ យុវជនកាកបាទក្រហមកម្ពុជា សិស្សានុសិស្ស និងប្រជាពលរដ្ឋប្រមាណ១ពាន់នាក់។

ទិវាជាតិនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រព្ធឡើងកាលពីថ្ងៃចន្ទ ១០កើត ខែមិគសិរ ឆ្នាំចសំរិទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ នៅក្នុងសាលមហោស្រពស្នាមញញឹមអង្គរ ក្រុងសៀមរាបនោះក៏មានដាក់បញ្ចាំងនូវកម្រងភាពយន្តឯកសារ ទាក់ទងការជួញដូរ កេងប្រវ័ញ្ច និងធ្វើអាជីវកម្មផ្លូវភេទតាមរយៈមេខ្យល់ក្រុមអ្នករកស៊ីតំពន្ធមនុស្ស និងបានប្រើប្រាស់គ្រប់កលល្បិចបោកប្រាស់ទៅតាមគ្រប់រូបភាព ហើយកុមារមួយចំនួនត្រូវបានធ្លាក់ខ្លួនទៅក្នុងអំពើ ពេស្យាចារ ដោយរងនូវអំពើហិង្សាក្នុងគ្រួសារ ល្បែងស៊ីសង ឬឪពុកម្តាយយកទៅលក់ ដើម្បីសងបំណុលគេ និងកុមារមួយចំនួនទៀតត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ដែលត្រូវបានគេយកទៅលក់ និងកត្តាមួយចំនួនក៏ធ្វើឱ្យស្ត្រី និងកុមារងាយរងគ្រោះផងដែរ។

លោកជំទាវ ជូ ប៊ុនអេង បានមានប្រសាសន៍ថា ទិវាជាតិលើកទី១២ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ក្នុងគោលបំណងបង្ហាញអំពីឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាពលរដ្ឋគ្រប់រូប ក្នុងការរួមគ្នា បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ និងការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស។ ម៉្យាងទៀតរាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ការលំបាក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ដើម្បីឱ្យប្រជាជនកម្ពុជា និង មនុស្សជាតិទទួលបានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និង ភាពសុខដុមរមនា។ លោកជំទាវ ជូ ប៊ុនអេង បានមានប្រសាសន៍ឱ្យដឹងថា ទិវាជាតិនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះដែរ ក៏បានផ្តោតសំខាន់ចំពោះបទល្មើស ការពរពោះជំនួស ដែលជាបទឧក្រិដ្ឋមួយក្នុងការជួញដូរទារក នាំចេញទៅក្រៅប្រទេស។ ម៉្យាងទៀត រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រការធ្វើទេសន្តប្រវេសន៍ការងារស្របច្បាប់ សម្រាប់ជាជម្រើសក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងសង្គម។

លោកជំទាវរដ្ឋលេខាធិការ សង្ឃឹមជឿជាក់ថា ការប្រារព្ធទិវានៅថ្ងៃនេះជាស្មារតីយល់ដឹងដ៏មានសារៈសំខាន់បំផុត ក្នុងការផ្សព្វផ្សាយជាសាធារណៈ បំផុសកិច្ចចូលរួមក្នុងការអនុវត្តច្បាប់ ស្តីអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ព្រមទាំងសូមឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ ផ្តល់ការគាំទ្រ បន្តសហការជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ដើម្បីអនុវត្តន៍ច្បាប់នេះ ឱ្យកាន់តែមានប្រសិទ្ធិភាពនិងជោគជ័យថែមទៀត ដើម្បីប្រជាជន និងប្រទេសជាតិយើង ៕ ដោយ ហង្ស សៀក

**ក្រុមគ្រួសារលោកវ៉ាត់វ័ន្តមុនីអ្នកជួយថតខ្សែភាពយន្តឯកសារ "ម្ដាយខ្ញុំលក់ខ្ញុំ"ដាក់ញត្តិឱ្យទូតរុស្ស៊ីជួយ**

http://www.rasmeinews.com/ December 18, 2018, 11:54 AM

ដោយៈមុនីវ័ន្ត/ភ្នំពេញៈក្រុមគ្រួសារលោក វ៉ាត់ វ័ន្តមុនី ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងជាអ្នកជួយថតខ្សែភាពយន្តឯកសារ "ម្ដាយខ្ញុំ លក់ខ្ញុំ" ឱ្យសារព័ត៌មាន Russia Today (RT) នៅព្រឹកថ្ងៃទី១៨ខែធ្នូឆ្នាំ២០១៨នេះ បានដាក់ញត្តិនៅស្ថានទូតរុស្ស៊ី ដើម្បីជួយអន្តរាគមន៍ឱ្យមានការដោះលែងលោក វ៉ាត់ វ័ន្តមុនី ចេញពីពន្ធនាគារ។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឃុំខ្លួនលោក វ៉ាត់ វ័ន្តមុនី ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងជាអ្នកថតខ្សែភាពយន្តឯកសារ "ម្ដាយខ្ញុំលក់ខ្ញុំ" ឱ្យសារព័ត៌មាន Russia Today (RT) ដាក់ពន្ធនាគារបណ្ដោះអាសន្ន និងចោទពីបទញុះញង់ឱ្យមានការរើសអើង តាមបញ្ញត្តិមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌ។ ការសម្រេចនេះ ធ្វើឡើងកាលពីរសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨។យោងតាមមាត្រា៤៩៦ មានខ្លឹមសារថាៈ «បទញុះញង់ឱ្យមានការរើសអើងអំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា៤៩៤ នៃក្រមនេះ ធ្វើឱ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬហិង្សា ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ។ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយ ជាកំណត់នោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ៦លានរៀល ប្រសិនបើការញុះញង់នេះ គ្មានប្រសិទ្ធភាពទេ»។

លោក វ៉ាត់ វ័ន្តមុនី ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ខណៈដែលលោកកំពុងសុំទិដ្ឋាការទៅប្រទេសហុល្លង់។ បន្ទាប់មក លោកត្រូវបានបញ្ជូនមកដល់កម្ពុជា កាលពីយប់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។ បន្ទាប់ពីបញ្ជូនមកដល់កម្ពុជា សមត្ថកិច្ចបានបញ្ជូនខ្លួនលោក វ៉ាត់ វ័ន្តមុនី ទៅកាន់សាលាដំបូងរាជធានីភ្នំពេញដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការសាកសួរអំពីដំណើររឿងនៃការថតខ្សែភាពយន្តឯកសារ "ម្ដាយខ្ញុំ លក់ខ្ញុំ"។

លោក លី សុផាណា ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យសាលាដំបូងរាជធានីភ្នំពេញ បានឱ្យដឹងថា"ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នពីបទ ញុះញង់អោយមានការរើសអើង តាមបញ្ញត្តិមាត្រា៤៩៦នៃក្រមព្រហ្មទណ្ឌ"។

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិបានថ្លែងបញ្ជាក់នៅក្នុងសន្និសីទកាសែតកាលពីថ្ងៃទី១២ ខែធ្នូថា វីដេអូនេះ ត្រូវបានថតក្នុងចេតនាទុច្ចរិត បន្ថោកកិត្តិយសប្រទេសកម្ពុជា។ ហេតុនេះ ប៉ូលិសបានស្នើសុំព្រះរាជអាជ្ញា កោះហៅលោក វ៉ាត់ វ័ន្តមុនី មកបំភ្លឺ តែលោកបានគេចខ្លួនចេញទៅក្រៅប្រទេស។ ក្រោយបំបែកសំណុំរឿងនេះ សមត្ថកិច្ចកម្ពុជា បានសុំកិច្ចសហការជាមួយសមត្ថកិច្ចថៃ ដើម្បីនាំខ្លួនលោក វ៉ាត់ វ័ន្តមុនី។ ខ្សែភាពយន្តឯកសារនេះ មានរយៈពេល ២៧នាទី ដោយបានរៀបរាប់លម្អិតអំពីគ្រួសារក្រីក្រនៅកម្ពុជាដែលលក់ព្រហ្មចារីស្រីរបស់ពួកគេក្នុងតម្លៃប្រហែល ៤០០ដុល្លារក្នុងម្នាក់ៗ។ ខ្សែភាពយន្តនេះបានបង្ហាញថានៅក្នុងក្លិបរាត្រី និងខារ៉ាអូខេ ក្មេងស្រីជំទង់បានញ៉ាំគេសជ្ជៈ និងផ្ដល់សេវាផ្លូវភេទដល់អតិថិជនបួនឬប្រាំនាក់ក្នុងមួយថ្ងៃ។

នៅក្នុងខ្សែភាពយន្តនេះ ក្មេងស្រីឈ្មោះ គៀង ស្រីម៉ិច បាននិយាយថា ម្ដាយរបស់នាង បានបង្ខំឱ្យនាងចូលពេស្យាចារ។ នៅក្នុងក្លឹបខារ៉ាអូខេភ្ញៀវបានហៅឱ្យអង្គុយជាមួយពួកគេ។ ពួកគេបានឱ្យនាងផឹកស្រាបៀរ ជាមួយពួកគេ ដោយឱ្យនាងពី ១០ ទៅ ២០ដុល្លារ ហើយប្រសិនបើទៅគេងជាមួយពួកគេ នោះនឹងទទួលបានច្រើនជាងនេះ។S/

# ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

## រដ្ឋបាលខេត្តបន្ទាយមានជ័យប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងគោលបំណងផ្សព្វផ្សាយ និងទប់ស្កាត់ការជួញដូរមនុស្ស

https://cammigrant.blogspot.com/ December 18, 2018

កាលពីព្រឹកថ្ងៃទី ១៨ ខែធ្នូ នេះ រដ្ឋបាលខេត្តបន្ទាយមានជ័យបានចូលរួមប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពឯកឧត្តម ខេង ស៊ុម សមាជិកក្រុមប្រឹក្សាខេត្ត និងឯឧត្តម អោម ចន្ថា អភិបាលខេត្តស្តីទីក្នុងគោលបំណងផ្សព្វផ្សាយ និងទប់ស្កាត់អំពើជួញដូរមនុស្ស សំដៅក្នុងការលប់បំបាត់ការជួញដូរមនុស្ស ព្រមទាំងការចំណាកស្រុកដោយខុសច្បាប់។ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនាព្រឹកមិញនេះ មានអ្នកចូលរួមសរុបចំនួនប្រមាណ 1200 នាក់ ដែលរួមមាន សិស្ស និស្សិត គរុសិស្ស តំណាងក្រុងស្រុក មន្ទីរជំវិញខេត្ត អង្គការដៃគូ ប្រជាពលរដ្ឋកងកំលាំងគ្រប់ប្រភេទ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ យោងទៅតាមរបាយការណ៍បង្រ្កាបការជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទឆ្នាំ ២០១៨ បានបង្ហាយថា មានជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះអំពីការជួញដូរមនុស្សមានចំនួន ១៨៩ នាក់ ក្នុងនោះជាយុវជនដែលមានអាយុចន្លោះពី ១៥ ដល់ ១៨ឆ្នាំ ។

## ពលករខ្មែរធ្វើការសំណង់នៅប្រទេសថៃត្រូវជីបាក់សង្កត់ស្លាប់

https://www.facebook.com/search/ ប្រភពពីទឹកចិត្ត ពលករ ឆ្លងដែន 19/12/2018

កាលពីម្សលមិញនេះ មានពលករខ្មែរធ្វើការសំណង់នៅប្រទេសថៃ ត្រូវជីបាក់សង្កត់ស្លាប់ នៅត្រង់ចំនុច ភូមិកៀតិថានី តម5 បាងណាត្រាត បាងបរ ខេត្តសមុទ្រប្រាកាណ នៅប្រទេសថៃ។ ជនរងគ្រោះមានឈ្មោះ ម៉ៃចាន់ឌី ភេទប្រុសអាយុ 23 ឆ្នាំ ស្លាប់ក្នុងករណីជីបាក់សង្កត់ស្លាប់។ ខ្ញុំសូមចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសានៃសពផង (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

## ទូតទេសស្សន៍ថៃបាននិយាយរាបរាប់រឿងរ៉ាវពីកម្មករខ្មែរធ្វើការនេសាទលើសមុទ្រថៃ ត្រូវបានចាញ់បោកមេខ្យល់ត្រូវគេលក់អោយធ្វើជាកម្មករទូក

https://www.facebook.com/ 18.12.18 *ប្រភពពី ព័ត៌មាន ពលករ ឆ្លងដែន*

ដើម្បីអោយមានការប្រុងប្រយ័ត្នដល់បងប្អូនកម្មករខ្មែរយើង ព្រោះថាទូរទេស្សន៍ថៃបាននិយាយរៀបរាប់រឿងរ៉ាវពីកម្មករខ្មែរធ្វើការនេសាទលើសមុទ្រថៃ ត្រូវបានចាញ់បោកមេខ្យល់ត្រូវគេលក់អោយធ្វើជាកម្មករទូក ដូចជានៅប្រទេសថៃ ប្រទេសឥណ្ឌូនេស៊ី ប្រទេសតៃវ៉ាន់។ល។ អគ្គបទប្រទេសថៃទូរទេស្សន៍ថៃបានចេញប្រកាសប្រាប់ដល់កម្មករខ្មែរ និងកម្មការនីខ្មែរថា បញ្ឈប់នៅការចាញ់បោកពីសំណាក់ក្រុមហ៊ុននានា ដែលដើរឃោសនាជ្រើសរើសកម្មករ កម្មការនី អោយទៅបំរើការងារនៅក្រៅប្រទេស ព្រោះគេបានសង្កេតឃើញថា ក្រុមហ៊ុនទាំងអស់នេះគឺជាក្រុមហ៊ុនជួញដូរមនុស្ស។ល។ ខ្ញុំសង្ឃឹមថា បងប្អូនឹងមានការប្រុងប្រយ័ត្ននូវការចាញ់បោកក្រុមហ៊ុននានា ដែលបានដើរឃោសនាតាមបណ្តាញសង្គមហ្វេសបុក ដែលយើងមិនបានដឹងពីសំណាក់ក្រុមហ៊ុន និងអោយបានច្បាស់លាស់។កុំសូវជឿរគេផ្តេសផ្តាសណាបងប្អូនខ្មែរយើងជាសវាងនៅការចាញ់បោកគេ។ បំណងល្អរបស់ខ្ញុំ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

# ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨
## រដ្ឋាភិបាលកម្ពុជាកំពុងរៀបចំឱ្យមានការបញ្ជូនពលករខ្មែរទៅប្រទេសអារ៉ាប៊ីសាអូឌីតដោយស្របច្បាប់

https://khmer.voanews.com/ 20 ធ្នូ 2018 *ហ៊ុល រស្មី*

វ៉ាស៊ីនតោន មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ឲ្យដឹងថា នឹងមានការពិភាក្សាជាមួយភាគីពាក់ព័ន្ធនានាអំពីការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអូឌីត (Saudi Arabia) ដែលជាផ្នែកមួយនៃសហភាពអារ៉ាប់ និងជាទីដែលមិនទាន់មានវត្តមានពលករខ្មែរច្រើននៅឡើយ។ ក៏ប៉ុន្តែអ្នកការពារសិទ្ធិពលករយល់ថា វាជាការប្រថុយប្រថានសម្រាប់កម្ពុជាក្នុងការបញ្ជូនពលកររបស់ខ្លួនឲ្យទៅបម្រើការងារនៅក្នុងតំបន់មជ្ឈឹមបូព៌ាប្រទេស ដោយសារតែកត្តាវប្បធម៌ និងមានការរំលោភសិទ្ធិការងារជាច្រើន។ អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិបង្ក្រាបការជួញដូរមនុស្ស និងផ្លូវភេទលើស្ត្រី និងកុមារ ដែលទើបតែបានបញ្ចប់ទស្សនកិច្ចនៅប្រទេសម៉ារ៉ុក (Morocco) មានប្រសាសន៍ប្រាប់ VOA កាលពីថ្ងៃសុក្រសប្តាហ៍មុនថា សហភាពអារ៉ាប់បានលើកឡើងថា កម្ពុជាពុំទាន់បានបញ្ជូនពលករចំនួនច្រើនទៅធ្វើការនៅក្នុងប្រទេសអារ៉ាប់នោះទេ។

អ្នកស្រីមានប្រសាសន៍យ៉ាងដូច្នេះ៖ «ក្នុងអាស៊ីមានអ្នកទៅហើយ ប៉ុន្តែគេថា គេចង់ផ្សារភ្ជាប់ទំនាក់ទំនងជាមួយកម្ពុជា ដោយសារថា កន្លងមកហ្នឹងមិនទាន់ឃើញមានកម្ពុជាទៅ គេហៅសហភាពអារ៉ាប់ហ្នឹងច្រើនទេ ហើយក្នុងហ្នឹង ខ្ញុំបានជម្រាបសួរដែរថា តើត្រូវការក្នុងវិស័យអី? គាត់ថា វិស័យគឺអាច មានគ្រប់កម្រិត បើសិនជាយើងអាចត្រៀមលក្ខណៈ ជាធនធានមនុស្សក្នុងកម្រិតជាអ្នកមានជំនាញខ្ពស់ ឬជំនាញមធ្យម ឬជំនាញទាបយ៉ាងណាហ្នឹង អាហ្នឹងស៊ីសង យើងធ្វើកិច្ចសហការជាមួយគ្នា មាន MOU ឬមួយក៏មានតម្រូវការ ដែលនឹងធ្វើទំនាក់ទំនងគ្នាក្រោយទៀត»។ មន្ត្រីរដ្ឋាភិបាលទទួលបន្ទុកប្រឆាំងការជួញដូរមនុស្សនេះមានប្រសាសន៍បន្ថែមថា ការពិភាក្សាកម្រិតអន្តរក្រសួងនឹងធ្វើឡើងនៅក្នុងពេលឆាប់ៗខាងមុខនេះ ពាក់ព័ន្ធនឹងការបញ្ជូនពលករខ្មែរទៅប្រទេសក្នុងតំបន់អារ៉ាប់មួយនេះ តាមអនុស្សរណៈយោគយល់មួយ ដែលភាសាអង់គ្លេសហៅថា Memorandum of Understanding ឬ MOU។ «ខ្ញុំនឹងមានកិច្ចប្រជុំមួយទៀត ព្រោះខ្ញុំទើបមកដល់ប្រទេសវិញទេ។ យើងនឹងមានកិច្ចប្រជុំដើម្បីពិភាក្សាគ្នា ដែលមិនមែនតែក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ ក្រសួងអប់រំ និងវិស័យផ្សេងៗទៀតក៏នឹងត្រូវការពិគ្រោះគ្នាដែរ ហើយក្នុងហ្នឹង យើងនឹងជជែកតែរឿង MOU ហ្នឹង។ ដំណើរការ អាចជាក្នុងដើមឆ្នាំ២០១៩ហ្នឹង ទៅតាមដែលខាងសំណើសុំរបស់គាត់ ហើយយើងក៏បានរាយការណ៍ជូនទៅខាងក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈហើយ»។

ខណៈដែលកម្ពុជាមិនទាន់មានការចុះអនុស្សរណៈយោគយល់ជាមួយប្រទេសអារ៉ាប៊ីសាអូឌីតនៅឡើយ តែប្រទេសនេះបានចុះអនុស្សរណៈយោគយល់ជាមួយប្រទេសកាតាដែលស្ថិតក្នុងប្លុកនៃប្រទេសអារ៉ាប់។ រដ្ឋសភាកម្ពុជាបានអនុម័តយល់ព្រមកាលពីឆ្នាំ២០១២ឱ្យកម្ពុជាបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសកាតាតាមអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជានិងប្រទេសកាតា។

ប្រទេសកាតាបានសម្តែងការចាប់អារម្មណ៍ក្នុងការទទួលពលករខ្មែរចំនួន៣៣០០០នាក់។ នេះបើតាមការបញ្ជាក់របស់លោកឌី ថេហូយ៉ា មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central)។ រហូតមកដល់ពេលនេះ លោកឌី ថេហូយ៉ា មិនទាន់មានព័ត៌មានផ្លូវការណាមួយបញ្ជាក់ពីការបញ្ជូនពលករ

ពីកម្ពុជាទៅធ្វើការនៅប្រទេសកាតានោះទេ។ ក៏ប៉ុន្តែ មន្ត្រីការពារសិទ្ធិពលកររូបនេះបានព្រមានពីហានិភ័យជាច្រើន ដែលអាចកើតមានដល់ពលករខ្មែរ ប្រសិនបើពួកគេស្ម័គ្រចិត្តទៅធ្វើការក្នុងប្រទេសស្ថិតក្នុងតំបន់អារ៉ាប់។

«ការបញ្ជូនទៅម្តុំអារ៉ាប់នេះជារឿងគួរឲ្យព្រួយបារម្ភ។ ព្រួយបារម្ភត្រង់ថា ទីមួយបើយើងនិយាយពីភូមិសាស្ត្រ រៀងឆ្ងាយ តំបន់ឆ្ងាយ។ ទីពីរ ទាក់ទងនឹងរឿងវប្បធម៌គឺការរស់នៅ យើងដឹងហើយ ពលរដ្ឋយើង ប្រពៃណីវប្បធម៌យើង របៀបពុទ្ធសាសនា របៀបអីផ្សេងអ៊ីចឹងទៅ ខាងអារ៉ាប់គឺជារបៀបឥស្លាម។ អ៊ីចឹង វប្បធម៌ប្រពៃណី វាខុសគ្នា។ ទីបីគឺ ទាក់ទងនឹងរឿង យន្តការការពារនៅក្នុងប្រទេសអារ៉ាប់ហ្នឹងតែម្តង។ យើងឃើញថា ជាប្រទេសសង្គមនិយម ជាប្រទេស ផ្តាច់ការអ៊ីចឹង អ៊ីចឹងអាការគោរពសិទ្ធិមនុស្សអីទាំងអស់នេះ វាជារឿងមួយដែលយើងព្រួយបារម្ភ ក្នុងលក្ខណៈដែល ប្រសិនបើពលរដ្ឋយើងត្រូវបានគេរំលោភសិទ្ធិអ៊ីចឹង ជាដើមនេះ គឺវាពិបាកក្នុងការជួយសង្គ្រោះ»។

លោកឌី ថេហូយ៉ា មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការ Central បានឲ្យដឹងពីករណីនៃស្ត្រីខ្មែរ មួយរូប ដែលត្រូវបានបញ្ជូនទៅធ្វើការនៅប្រទេសមួយស្ថិតនៅប៉ែកអារ៉ាប់នេះ ហើយបានប្រឈមនឹងភាពមិនប្រក្រតីនៃ ការធ្វើទំនាក់ទំនងជាមួយគ្រួសារ បន្ទាប់ពីប្រាំមួយខែដំបូងនៃការទៅបំពេញការងារ។ «ខាងគ្រួសារជាប្តីហ្នឹងគឺទាក់ទង មកឲ្យអង្គការ Central ជួយសង្គ្រោះប្រពន្ធគាត់ ដោយសារតែទៅរយៈពេលប្រាំមួយខែ។ បីខែដំបូងអ៊ីចឹងទៅ គេឲ្យមាន ការទំនាក់ទំនងមកផ្ទះ បន្ទាប់ពីហ្នឹងទៅ បាត់ដំណឹងឈឹង អ៊ីចឹង។ អាហ្នឹងយើងមានករណីអ៊ីចឹង! ទៅអារ៉ាប់! ហើយតែ បាត់ដំណឹងឈឹងអ៊ីចឹង។ ម្តុំហ្នឹង យើងហាក់ដូចជាមានស្ថានទូតតែនៅគុយវ៉ែតទេ។អ៊ីចឹង យើងគ្រាន់តែចង់និយាយថា សូម្បីប្រទេសមួយចំនួនដែលយើងមានស្ថានទូតនៅហ្នឹងហើយ ក៏ពិបាកជួយផង ចុះទម្រាំនៅម្តុំហ្នឹង យើងអត់មាន ស្ថានទូតទៀត? តើការជួយសង្គ្រោះទាំងអស់ហ្នឹង វារបៀបម៉េច? អ៊ីចឹងកន្លងមក យើងឃើញបាទ យើងឃើញស្រាប់ ហើយបាទ»។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មានប្រសាសន៍ថា ការសិក្សាអំពីហានិភ័យនានា តែងតែត្រូវ បានធ្វើឡើង នៅមុនការបញ្ជូនពលករខ្មែរទៅក្រៅប្រទេស។ «រឿងកាតព្វកិច្ចហ្នឹងទីមួយហើយ! ពីព្រោះរាល់ពេលដែល យើងបញ្ជូនពលករទៅក្រៅ គឺក្នុង MOU ចាំបាច់ត្រូវតែដាក់ ដោយសារយើងត្រូវមានកិច្ចការពារពលករ ហើយកម្ពុជា យើងហ្នឹងកន្លងមក ពេលដែលយើងមានកិច្ចព្រមព្រៀងបញ្ជូនពលករទៅក្រៅប្រទេស យើងមានអា MOU ហ្នឹងមួយ ហើយបន្ទាប់មកទៀត យើងមាន MOU ទាក់ទងរឿងប្រឆាំងការជួញដូរមនុស្សនេះទៀត។ ប៉ុន្តែយើងក៏អាចបង្រួមដាក់ ចូលក្នុង MOU តែមួយក៏បានដែរ»។

VOA មិនអាចទាក់ទងលោក ហេង សួ អ្នកនាំពាក្យក្រសួងការងារបានទេ នៅថ្ងៃពុធនេះ ដោយទូរស័ព្ទលោករោ ទ៍គ្មានអ្នកទទួល។ លោក សេង សក្កដា អគ្គនាយកអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ បានបដិសេធមិនផ្តល់ការ អធិប្បាយ ដោយលោកជាប់ប្រជុំ។

គ្រាដែលកម្ពុជាមិនទាន់បានសម្រេចបញ្ជូនពលករទៅប្រទេសអារ៉ាប៊ីសាអូឌីតនោះ លោកឌី ថេហូយ៉ាបានឲ្យ ដឹងពីការរកឃើញនៃគ្រោះថ្នាក់ការងារជាច្រើន ដែលបានកើតឡើងនៅប្រទេសកាតា ដែលជាប្រទេសស្ថិតក្នុងតំបន់អា រ៉ាប់ដូចគ្នានេះ។ លោកបានរៀបរាប់យ៉ាងដូច្នេះ៖ «បញ្ហាទីមួយទាក់ទងនឹងរឿងកេងប្រវ័ញ្ចការងារ កេងប្រវ័ញ្ចប្រាក់ ឈ្នួល ទីពីរលក្ខខណ្ឌរស់នៅពិបាក ដូចជា អង្គការ Amnesty International រកឃើញថា មានកន្លែងខ្លះហ្នឹងគឺរស់នៅ ៦០០នាក់អ៊ីចឹង ហើយបន្ទប់ទឹកមានតែពីរអ៊ីចឹងទេ។ ហើយរុយចង់ច្រើនជាងមនុស្ស មនុស្សនៅជាមួយរុយកខ្វក់ចឹង ណាស់! ធ្វើការទាំងយប់ ធ្វើការទាំងថ្ងៃ ហើយនៅពេលដែលមានបញ្ហា អត់ដឹងរត់ទៅណា។ គេដកលិខិតឆ្លងដែនអស់

លើញហើយ ហើយកាលណាបើគេត់ចេញ គេប្រឈមនឹងពីការជាប់គុកអ៊ីចឹងជាដើម។ ហើយក៏មានគ្រោះថ្នាក់ការងារ បើយោងតាម Department of Emergency របស់ Qatar ហ្នឹងគឺដូចរកឃើញថា មួយថ្ងៃ គ្រោះថ្នាក់ការងារ មិនក្រោមពី ១៨០០នាក់ទេ ហើយមានមនុស្សស្លាប់មិន មិនតិចជាង៧០០០នាក់ទេ រាប់តាំងពីឆ្នាំ២០១៣ រហូតដល់ឆ្នាំ២០២២។ អានេះជាការរកឃើញរបស់ Armnesty International»។

លោកថា ព័ត៌មាននេះ អាចជាទុនសម្រាប់រដ្ឋាភិបាលខ្មែរពិចារណាឲ្យមានយន្តការហ្មត់ចត់ដើម្បីការពារជីវិតពលកររបស់ខ្លួន។ «អ៊ីចឹងហើយបានយើងមានការព្រួយបារម្ភ ចំពោះការបញ្ជូនទៅប្រទេសម្ដុំហ្នឹង។ បើសិនជារដ្ឋ មានយន្តការធានាថា ពលរដ្ឋយើងទៅ យើងមានយន្តការធានាបាន បើក្នុងករណីថា គេរំលោភសិទ្ធិការងារ យើងមានដំណោះស្រាយជាក់លាក់គឺធានាបានអំពីការការពារសិទ្ធិ១០០ភាគរយ អាហ្នឹង វាមិនជាបញ្ហាអីទេ។ អ៊ីចឹងអាការណ៍ចំណាកស្រុកនេះ វាជាជម្រើស អ៊ីចឹងយើងមិនអាចហាមឃាត់មិនឲ្យគាត់ទៅទេ ក៏ប៉ុន្តែអ្វីដែលយើងត្រូវគិតគឺយន្តការការពារសិទ្ធិរបស់គាត់ ធានាបានអំពីសុវត្ថិភាព អំពីការធ្វើចំណាកស្រុក មិនមែនការចំណាកស្រុក ប្រថុយប្រថាន។ បើសំណាងល្អ ល្អ បើសំណាងមិនល្អ យកជីវិតទៅគ្រោះថ្នាក់។ ហ្នឹងជារឿងមួយដែលយើងព្រួយបារម្ភ បាទ»។

អង្គការសិទ្ធិមនុស្ស Amnesty International បានលើកឡើងពីករណីរំលោភបំពាន ដូចបានបញ្ជាក់ខាងលើនេះ នៅក្នុងរបាយការណ៍ដែលមានចំណងជើងថា«The Ugly Side of the Beautiful Game: Exploitation on a Qatar 2022 World Cup Site»ចេញផ្សាយកាលពីខែមីនាឆ្នាំ២០១៦។

តាមការបញ្ជាក់របស់លោកឌី ថេហូយ៉ា ពលករខ្មែរជាងពីរលាននាក់បានធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ក្នុងនោះមានជាងមួយលាននាក់បានទៅធ្វើការនៅប្រទេសថៃ។ ទិន្នន័យដែល លោកបានលើកឡើងនេះគឺយោងទៅលើស្ថិតិចុងក្រោយរបស់ក្រសួងការងារនៃរដ្ឋាភិបាលខ្មែរ៕

# នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស ចុះបង្ក្រាបទីតាំងម៉ាស្សាឃីហោ ៩៩ បង្កប់សេវាផ្លូវ បម្រើដោយអនីតិជន

http://nokorwatnews.com/ 20-12-2018

ភ្នំពេញ៖ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសហការ ជាមួយនគរបាលមូលដ្ឋានខណ្ឌចំការមនបានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ ៩៩ មានបង្កប់សេវាផ្លូវភេទបម្រើដោយអនីតិជនឃាត់ខ្លួនមនុស្សចំនួន៦នាក់ ក្នុងនោះម្ចាស់ទីតាំងម្នាក់ នារីរងគ្រោះចំនួន៤នាក់ និងអ្នកជាំបាយម្នាក់ ។

ករណីបង្ក្រាបទីតាំងខាងលើនេះ បានធ្វើឡើងកាលពីវេលាម៉ោង៥ និង៣០នាទីល្ងាច ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្ថិតនៅផ្ទះលេខ២៦៥ ផ្លូវ៤៣២ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ម្ចាស់ទីតាំងមានឈ្មោះ ទៀង ពុទ្ធារី ភេទស្រី អាយុ៣០ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ២៦៥ ផ្លូវ៤៣២ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សមត្ថកិច្ចបានឲ្យដឹងថា ក្នុងប្រតិបត្តិការនេះដោយមានចង្អុលបង្ហាញពី លោក ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការសម្របសម្រួល ពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមានការបញ្ជាផ្ទាល់ដោយ លោក ឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឲ្យដឹងថាទីតាំងម៉ាស្សាកោសជប់ ឃីហោ ៩៩ ចាប់

ផ្ដើមបើកបម្រើសេវាចាប់ពីម៉ោង៩ព្រឹក រហូតដល់យប់ជ្រៅរំលងអាធ្រាតដោយមាននារីក្មេងចាស់ចំនួន៤នាក់រងចាំភ្ញៀវមកម៉ាស្សា និងម៉ាស្សក្រលៀន(សាប់ និងបៀមលឹង្គ) ដោយ តម្លៃចាប់ពី ១៥ដុល្លារ ទៅ២០ដុល្លារ ក្នុងមួយដង ។

ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះផងដែរកម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនមនុស្សចំនួន ៦នាក់ក្នុងនោះនារីរងគ្រោះចំនួន ៤នាក់(អនីតិជនម្នាក់) ម្ចាស់ទីតាំងស្រីម្នាក់ បាននាំខ្លួនយកមកការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីបន្តការសាកសួរតាមនីតិវិធី ។

សូមបញ្ជាក់ផងដែរចំណែកនារីរងគ្រោះទាំង៤នាក់នោះត្រូវបាន នគរបាលប្រគល់ជូនអង្គការសង្គមកិច្ចដើម្បីធ្វើការអប់រំ ដោយឡែកស្ត្រីម្នាក់ អ្នកជាំបាយ ត្រូវកម្លាំងសមត្ថកិច្ចឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ព្រោះគ្មានការជាប់ពាក់ព័ន្ធក្នុងករណីនេះ ៕ស រស្មី

## កម្លាំងប៉ុស្តិ៍ប៉ោយប៉ែត ទទួលពលករខ្មែរ ខុសច្បាប់មកពីប្រទេសថៃ ចំនួន៥១នាក់

http://cambodiapolice.com/ 10:31 am 20 ធ្នូ 2018

បន្ទាយមានជ័យ៖ កម្លាំងប៉ុស្តិ៍ប៉ោយប៉ែតបានទទួលពលករខុសច្បាប់សរុបចំនួន៥១នាក់ ក្នុងនោះស្រី១៦នាក់ និងកុមារ០៥នាក់ មកពីបណ្តាខេត្តនិងក្រុង កាលពីថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០១៨។ យោងតាមរបាយការណ៍បានឲ្យដឹងថា ពលករដែលកម្លាំងប៉ុស្តិ៍ប៉ោយប៉ែតទទួលបានរួមមានៈ-បាត់ដំបង២០នាក់ ស្រី០៦នាក់ ក្មេង ០២នាក់។-កំពង់ធំ១៤នាក់ ស្រី០៣នាក់។សៀមរាប០៦នាក់ ស្រី០៣នាក់។បន្ទាយមានជ័យ ០៣នាក់ ស្រី០២នាក់។-ព្រៃវែង០៨នាក់ ស្រី០២នាក់ ក្មេង០៣នាក់ ៕

## រដ្ឋាភិបាលហ្វីលីពីនជួយសង្គ្រោះប្រជាជនហ្វីលីពីនជិត ៣០.០០០នាក់ ពីការជួញដូរមនុស្ស

http://information.gov.kh/ *ចេញផ្សាយ ថ្ងៃទី* 20 *ខែ ធ្នូ ឆ្នាំ* 2018

AKP ភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ រដ្ឋាភិបាលបាននិយាយពីថ្ងៃពុធថា ពួកជនរងគ្រោះពីការជួញដូរមនុស្សជិត ៣០.០០០នាក់ត្រូវបានជួយសង្គ្រោះដោយពួកអាជ្ញាធរអន្តោប្រវេសន៍ហ្វីលីពីន ចាប់តាំងពីខែមករា ដល់ខែតុលា ឆ្នាំនេះ ។ ការិយាល័យអន្តោប្រវេសន៍( BI ) ហ្វីលីពីនបាននិយាយថា ខ្លួនបានការពារជនជាតិហ្វីលីពីន សរុបទាំងអស់ ២៨.៤៦៧នាក់ ដែលរួមមាន អនីតិជន ឬស្ត្រីមិនទាន់គ្រប់អាយុ ១៥១នាក់ផងដែលធ្វើដំណើរទៅកាន់ប្រទេសអារ៉ាប៊ីសាអូឌីត មិនឱ្យចាកចេញពីប្រទេសនេះ នៅពេលដែលការិយាល័យនេះ បានបង្កើនយុទ្ធនាការរបស់ខ្លួនប្រឆាំងនឹងការជួញដូរមនុស្សនោះ ។

តាម BI ឱ្យដឹងថា ពួកអ្នកដំណើរទាំងនោះត្រូវបានគេស្ទាក់ចាប់នៅឯព្រលានយន្តហោះអន្តរជាតិ ក្រុងម៉ានីល និងព្រលានយន្តហោះដទៃទៀតក្នុងប្រទេសហ្វីលីពីនភាគកណ្តាល,នៅដាវ៉ាវប្រទេសហ្វីលីពីនភាគត្បូង និងព្រលានយន្តហោះClark នៅក្នុងកោះ Luzon យ៉ាងសំខាន់ របស់ហ្វីលីពីន ។ BI បានរឹតបន្តឹងសន្តិសុខនៅឯព្រលានយន្តហោះនៅបុណ្យគ្រីស្តស្មាស់ និងរដូវបុណ្យឈប់សម្រាកនេះ ដោយព្រួយបារម្ភថា ពួកអ្នកជួញដូរមនុស្សអាចឆ្លៀតយកឱកាសពីភាពមមាញឹក នៃពួកអ្នកធ្វើដំណើរនេះ ។

តាមការសិក្សាថ្មីៗមួយធ្វើឡើងដោយធនាគារពិភពលោកឱ្យដឹងថា ទោះបីជាទូទៅមានការអនុវត្តន៍ សេដ្ឋកិច្ចបានយ៉ាងល្អក៏ដោយ ក៏ភាពក្រីក្រនៅតែមានខ្ពស់នៅឡើយ ហើយជំហាននៃការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសហ្វីលីពីនមានភាពយឺតយ៉ាវ បើប្រៀបធៀបជាមួយបណ្តាប្រទេសនៅអាស៊ីខាងកើត ដទៃទៀត ។ ដោយសារខ្វះការងារធ្វើនៅក្នុងប្រទេសហ្វីលីពីន ប្រជាជនហ្វីលីពីន រហូតដល់១២លាននាក់ធ្វើការឬរស់នៅបរទេសដើម្បីស្វែងរកឱកាសឱ្យបាន

កាន់តែប្រសើរ ព្រមទាំងបញ្ជូនប្រាក់ទៅឱ្យគ្រួសាររបស់ពួកគេវិញ ។ ពីក្នុងចំនួននេះមានកុងត្រាថ្មី ឬបន្តទៅទៀត សម្រាប់ប្រជាជនហ្វីលីពីន ប្រមាណ ២,៣ លាននាក់ ដែលទៅធ្វើការនៅបរទេសរាល់ឆ្នាំ ។ ប្រទេសហ្វីលីពី គឺនាំចេញពលករដែលច្រើនបំផុតមួយរបស់ពិភពលោក ។ សេដ្ឋកិច្ចគឺពឹងពាក់យ៉ាងខ្លាំងទៅលើប្រាក់ដែលកម្មករហ្វីលីពីនៅបរទេស( OFWA )ផ្ញើមកប្រទេស៕ (ប្រភពស៊ីនហួ បកប្រែដោយលោក ប៊ុនមឿន )

# ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨

## សមត្ថកិច្ច បញ្ជូនស្ត្រីម្ចាស់ទីតាំងម៉ាស្សា ដែលបង្កប់សេវាផ្លូវភេទដោយអនីតិជន នៅខណ្ឌចំការមន ទៅតុលាការ ខណៈនារីរងគ្រោះត្រូវបានរំដោះ ទៅរកលំនឹងជីវិតថ្មី

http://www.freshnewsasia.com/ 2018-12-21

(ភ្នំពេញ)៖ ស្ត្រីម្ចាស់ទីតាំងម៉ាស្សាមួយកន្លែង មានបង្កប់សេវាកម្មផ្លូវភេទ បម្រើដោយអនីតិជន នៅខណ្ឌចំការមន ត្រូវបានបញ្ជូនទៅតុលាការហើយ នៅព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨នេះ ខណៈនារីរងគ្រោះចំនួន៤នាក់ ត្រូវបានរំដោះឲ្យទៅរកលំនឹងជីវិតថ្មី។

សូមជំរាបថា កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយនគរបាលមូលដ្ឋាន ខណ្ឌចំការមន ចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ ៩៩ មានបង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន ដោយឃាត់ខ្លួនមនុស្សចំនួន៦នាក់ ក្នុងនោះម្ចាស់ទីតាំងម្នាក់ នារីរងគ្រោះចំនួន៤នាក់ និងអ្នកដាំបាយម្នាក់។ ប្រតិបត្តិការនេះ ត្រូវបានធ្វើឡើងកាលពីវេលាម៉ោង ៥៖៣០នាទីល្ងាច ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្ថិតនៅផ្ទះលេខ២៦៥ ផ្លូវ៤៣២ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការនេះ មានចង្អុលបង្ហាញពីឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ និងមានការសម្របសម្រួលពីលោកគុជ គីមឡុង ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ និងមានការបញ្ជាផ្ទាល់ដោយ ឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ។

នគរបាលបានឲ្យដឹងថា ម្ចាស់ទីតាំងមានឈ្មោះ ទៀង ពុទ្ធារី ភេទស្រី អាយុ៣០ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ២៦៥ ផ្លូវ៤៣២ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។ កម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា ទីតាំងម៉ាស្សាកោសជប់ ឃីហោ ៩៩ ចាប់ផ្តើមបើកបម្រើសេវាចាប់ពីម៉ោង ៩៖០០ព្រឹក រហូតដល់យប់ជ្រៅរំលងអាធ្រាត ដោយមាននារីក្មេងចាស់ចំនួន៤នាក់ រង់ចាំភ្ញៀវ មកម៉ាស្សា និងម៉ាស្សាក្រលៀន (សម្រេចកាមដោយប្រើដៃ និងមាត់) តម្លៃចាប់ពី ១៥ដុល្លារអាមេរិក ទៅ២០ដុល្លារអាមេរិកក្នុងមួយដង។ ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនមនុស្ស ចំនួន៦នាក់ រួមមាន ម្ចាស់ទីតាំងម្នាក់, នារីរងគ្រោះចំនួន៤នាក់ (អនីតិជនម្នាក់) និងអ្នកដាំបាយម្នាក់។ នេះបើតាមការឲ្យដឹងបន្ថែម ពីសមត្ថកិច្ច។

សូមបញ្ជាក់ផងដែរថា នារីរងគ្រោះទាំង៤នាក់នោះ ត្រូវបាននគរបាលប្រគល់ជូនអង្គការសង្គមកិច្ច ដើម្បីធ្វើការអប់រំ។ ចំណែក អ្នកដាំបាយម្នាក់ ត្រូវនគរបាលឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ព្រោះគ្មានការពាក់ព័ន្ធ៕

## ដឹងអត់ថា ខ្មែរចូលទៅថៃខុសច្បាប់ត្រូវបញ្ជូនមកវិញមានខេត្តណាខ្លះ?

https://kohsantepheapdaily.com.kh/ *ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៨ ម៉ោង ០៩:៣១ ប៊ុន ធឿន*

បន្ទាយមានជ័យ ៖ មន្ត្រីនគរបាលអន្តរប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ទទួលពលករខ្មែរខុសច្បាប់ថៃចាប់បញ្ជូនមកវិញ ចំនួន៥១នាក់ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។ មន្ត្រីនគរបាលអន្តរប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានប្រាប់ថា អាជ្ញាធរមានសមត្ថកិច្ចថៃបានចាប់បញ្ជូនពលករខ្មែរខុសច្បាប់រយៈពេល១ថ្ងៃមានចំនួន៥១នាក់ ស្រី១៦នាក់ និងកុមារ០៥នាក់ ក្នុងនោះមានប្រជាពលរដ្ឋខេត្តបាត់ដំបងមានចំនួន២០នាក់ ស្រី០៦នាក់ កុមារ២នាក់ ប្រជាពលរដ្ឋខេត្តកំពង់ធំ មានចំនួន១៤នាក់ ស្រី០៣នាក់ និងប្រជាពលរដ្ឋខេត្តសៀមរាបមានចំនួន០៦នាក់ ស្រី០៣នាក់ និងប្រជាពលរដ្ឋនៅខេត្តបន្ទាយមានជ័យ មានចំនួន០៣នាក់ស្រី០២នាក់ ប្រជាពលរដ្ឋខេត្តព្រៃវែងមានចំនួន០៨នាក់ ស្រី០២នាក់ ក្មេង០៣នាក់ ។ មន្ត្រីនគរបាលបានបញ្ជាក់ថា ពលករដែលត្រូវភាគីថៃចាប់បញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានរាល់ថ្ងៃ តែជាក់ស្តែងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ បញ្ជូនច្រើនជាងសព្វមួយដងហើយជាពលករខ្មែរដែលចូលទៅរក និងធ្វើការងារនៅក្នុងប្រទេសថៃដោយខុសច្បាប់ទើបភាគីថៃចាប់បញ្ជូនមកវិញ ។

ដោយយោងតាមរបាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៨ ការងារប្រយុទ្ធប្រឆាំងការជួញដូរ និងសមាហរណកម្មដែលសហការជាមួយសមត្ថកិច្ចច្រកទ្វារអន្តរជាតិប៉ោយប៉ែតភាគីថៃចាប់បញ្ជូនពលករខ្មែរតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត រយៈពេល១ខែមានចំនួន១.៦៣១នាក់ ស្រី៥៥៥នាក់ កុមារ២០៦នាក់ កុមារី៩៨នាក់ ក្នុងនោះបានសម្ភាសន៍កុមារចំនួន៣៨នាក់ មានស្រី២៥នាក់ មានក្មេងកំព្រាចំនួន០៥នាក់ និងកុមារត្រូវបានគេជួញដូរមានចំនួន០៩នាក់ ស្រី០៤នាក់ ៕

## ពលការិនីខ្មែរធ្វើការនៅខេត្ត ត្រាត ដាច់ចិត្តចងករសម្លាប់ខ្លួនដោយមិនដឹងមូលហេតុ

https://cammigrant.blogspot.com/ posted by MT Vlog on December 20, 2018

កាលពីវេលាម៉ោង០៨យប់មិញនេះ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី២០ ខែធ្នូ ឆ្នាំ២០១៨ មានករណីពលការិនីខ្មែរម្នាក់ឈ្មោះ ធឿន សុភាន់ បានសម្រេចចិត្តចងកសម្លាប់ខ្លួនឯងនៅក្នុងផ្ទះកន្លែងដោយមិនដឹងមូលហេតុ ដែលមានទីតាំងស្ថិតនៅភូមិខៅតូម៉ោក ឃុំប្រាណីត ស្រុកខៅសាម៉ីង ខេត្តត្រាត ប្រទេសថៃ។ លក្ខណៈពេលនេះផងដែរ អាជ្ញាធរថៃក៏កំពុងទាក់ទងក្រុមគ្រួសារសព ដើម្បីធ្វើបុណ្យតាមប្រពៃណី។

គួបញ្ជាក់ផងដែរថា ឆ្នាំ២០១៨ នេះមានពលករចំណាកស្រុកសរុបចំនួន ១,៨៣៦ ៦៦៦នាក់។ ពលករចំណាកស្រុកស្របច្បាប់មានចំនួន ១,០៣៩ ៧៩៧ នាក់។ ចំពោះអ្នកដែលចេញទៅធ្វើការមិនស្របច្បាប់មានចំនួន ៧៩៦,៨៦៩នាក់។ នេះបើយោងតាមរបាយការណ៍ប្រឆាំងការជួញដូរមនុស្ស។

# ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨

## ពលករខ្មែរប្រុសស្រីប្រមាណ ១០នាក់ ក្រឡាប់រថយន្តរងរបួសធ្ងន់ និងស្រាល

https://cammigrant.blogspot.com/ posted by MT Vlog on December 23, 2018

កាលម្សិលមិញរសៀលថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៨ មានករណីគ្រោះថ្នាក់ចរាចរណ៍ ដែលបណ្តាលដោយមនុស្សយ៉ាងហោចណាស់ ១០នាក់បានរងរបួសធ្ងន់ និងស្រាលនៅក្នុងហេតុការណ៍ក្រឡាប់រថយន្តមួយគ្រឿង ដែលអ្នកធ្វើ

ដំណើរគឺជាពលករ ពលការិនីខ្មែរ ដែលកំពុងបម្រើការងារនៅក្នុងប្រទេសថៃ។ ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ខាងលើនេះ កើតឡើងក្នុងស្រុក សយដាវ ខេត្តចាន់បុរី ប្រទេសថៃ។

បច្ចុប្បន្នពលករខ្មែរដែររងគ្រោះបានកំពុងជួយសង្គ្រោះដោយអាជ្ញាធរថៃបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យប្រាក់ប៉ុកខ្លៅ ខេត្តចាន់បុរី។

## កូរ៉េ នឹងទទួលពលករបរទេស ៥៦ ពាន់នាក់នៅឆ្នាំ ២០១៩

https://www.postkhmer.com/ Publication date 21 December 2018 | 15:15 ICT

ក្រុងសេអ៊ូលៈ ប្រទេស កូរ៉េខាងត្បូង នឹងទទួលយកពលករបរទេសចំនួន ៥៦ ០០០ នាក់ស្ថិតក្រោមប្រព័ន្ធអនុញ្ញាតការងារឆ្នាំ ២០១៩ ដែលជាចំនួនដូចគ្នាទៅនឹងឆ្នាំនេះ ក្នុងគោលបំណងបន្ធូរបន្ថយកង្វះខាតកម្លាំងពលកម្មនៅក្នុងប្រទេសនេះ។

រដ្ឋាភិបាលកូរ៉េ បានសម្រេចលើកូតាការងារនេះកាលពីថ្ងៃអង្គារនៅកិច្ចប្រជុំមួយដែលដឹកនាំដោយការិយាល័យសម្របសម្រួលគោលនយោបាយរបស់រដ្ឋាភិបាល។ ស្ថិតក្រោមផែនការនេះ កូរ៉េនឹងទទួលយកពលករថ្មីចំនួន ៤៣ ០០០ នាក់ និងពលករដែលវិលត្រឡប់មកវិញចំនួន ១៣ ០០០ នាក់ ដែលតួលេខនេះបានធ្វើឲ្យចំនួនពលករថ្មីមានតិចជាងឆ្នាំ ២០១៨ ចំនួន ២ ០០០ នាក់ ខណៈដែលអ្នកវិលត្រឡប់មកវិញមានច្រើនជាងមុន ២ ០០០ នាក់ដែរ។ ស្ថិតក្រោមប្រព័ន្ធអនុញ្ញាតការងារនេះ ពលករបរទេសម្នាក់អាចធ្វើការក្នុងប្រទេស កូរ៉េ ក្នុងរយៈពេលរហូតដល់ ៤ ឆ្នាំនិង ១០ ខែដោយកាន់ទិដ្ឋាការ E-9 ប៉ុន្តែមិនអាចចាកចេញ ឬចូលប្រទេស កូរ៉េ វិញដោយកាន់ទិដ្ឋាការដូចគ្នាក្នុងអំឡុងពេលនោះទេ។ បន្ទាប់ពីរយៈពេល ៤ ឆ្នាំ និង ១០ ខែ អ្នកកាន់ទិដ្ឋាការ E-9 ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌមួយចំនួនមានសិទ្ធិចាកចេញ និងចូលប្រទេស កូរ៉េ វិញ ដើម្បីវិលត្រឡប់ទៅធ្វើការជាមួយនិយោជកចាស់របស់ពួកគេ។

ពលករបរទេសប្រហែល ២៨ ៨៨០ នាក់នឹងចូលប្រទេស កូរ៉េ នៅខែមករា មេសា កក្កដា និងតុលា ដើម្បីធ្វើការងារក្នុងវិស័យផលិតកម្ម ដោយ ៦០ ភាគរយនឹងចាប់ផ្តើមធ្វើនៅឆមាសទី ១ ឆ្នាំក្រោយ៕ ANN/KC

## ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨

## ក្រសួងចំនួន២ ប្រកាសជាផ្លូវការនូវផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជន

http://wmc.org.kh/ *ថ្ងៃចន្ទ ទី២៤ ខែធ្នូ ឆ្នាំ២០១៨ លៀ ស៊ីណា*

ភ្នំពេញ ៖ ក្រសួងយុត្តិធម៌ និង ក្រសួងសង្គមកិច្ច បានរៀបចំប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជនចាប់ពី ២០១៨ ដល់ឆ្នាំ ២០២០។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចបញ្ជាក់ថា គោលបំណងនៃផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិនេះ គឺធ្វើឲ្យជីវិតរបស់អនីតិជនទំនាស់នឹងច្បាប់បានប្រសើរឡើង ដោយផ្តោតលើគោលដៅពីរ។

ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយនឹងការគាំទ្រពីយូនីសេហ្វ បានរៀបចំរួមគ្នា ប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជនដើម្បីណែនាំពីការអនុវត្តច្បាប់នេះ ដែលបានចូលជាធរមានកាលពីដើមឆ្នាំ២០១៧ ក្រោមអធិបតីភាព សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សម្តេច ស ខេង កាលពីពេលនោះ បានលើកឡើងថា ចំណុចគន្លិះមួយនៅក្នុងផែនការនេះ គឺផ្តោតជាសំខាន់ទៅលើការឲ្យមានការយល់ដឹងពីផលប្រយោជន៍នៃការអនុវត្តនូវវិធានការបង្វែរ និងវិធានការផ្សេងក្រៅពីការឃុំខ្លួន ដែល

អាចកាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី និងកាត់បន្ថយចំនួនអនីតិជនជាប់ឃុំ ហើយក៏អាចឈានទៅកាត់ន្ថយបន្ទុកចំណាយរបស់រដ្ឋ ក្នុងការគាំទ្រទៅលើការងារឃុំឃាំងផងដែរ។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១៧ ដើម្បីធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌អនីតិជននៅកម្ពុជា។ ច្បាប់នេះផ្តោតលើការបង្វែរ ដែលជាការឆ្លើយតបដ៏ត្រឹមត្រូវចំពោះអនីតិជនទំនាស់នឹងច្បាប់ ជាជាងការដាក់ទណ្ឌកម្មដែលជាអភិក្រមកំពុងបច្ចុប្បន្ន ដោយមិនអាចឆ្លើយតបនឹងតម្រូវការរបស់អនីតិជន។

មានប្រសាសន៍ក្នុងពិធីនោះលោក វង់ សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានគូសបញ្ជាក់ថា គោលបំណងនៃផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិនេះ គឺនឹងធ្វើឲ្យជីវិតរបស់អនីតិជនទំនាស់នឹងច្បាប់បានប្រសើរឡើង ដោយផ្តោតទៅលើគោលដៅពីរ ទី ១. កសាងប្រព័ន្ធយុត្តិធម៌អនីតិជនទំនើបមួយ ប្រកបដោយចីរភាព និងមានការកែលម្អជាបន្តបន្ទាប់នាពេលអនាគត និងទី ២. ផ្តល់កិច្ចការពារ និងគាំទ្រសិទ្ធិរបស់អនីតិជនទំនាស់នឹងច្បាប់ ប្រកបដោយប្រសិទ្ធភាព។

តាមការប៉ាន់ប្រមាណ ក្នុងចំណោមកុមារ ១០០.០០០នាក់ មានកុមារប្រហែល២៣នាក់កំពុងជាប់ឃុំក្នុងពន្ធនាគារនាពេលបច្ចុប្បន្ន។ ចំនួនកុមារក្នុងពន្ធនាគារបានកើនឡើងពី ៣៣៦ ក្នុងឆ្នាំ២០១៤ ដល់ ១.៥៣៥ ក្នុងឆ្នាំ២០១៨នេះ។ នេះជាសញ្ញាមួយទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតជាបន្ទាន់ ដើម្បីឲ្យអនីតិជនទំនាស់នឹងច្បាប់ ត្រូវបានបង្វែរចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទៅកាន់យន្តការកុមារមេត្រីដូចជាកម្មវិធីបង្វែរជាដើម។

ក្នុងពេលដែលច្បាប់យុត្តិធម៌អនីតិជន គឺជាគោលដៅដ៏សំខាន់នៅក្នុងកិច្ចការកំណែទម្រង់យុត្តិធម៌អនីតិជននោះ ទស្សនៈទានស្តីពីយុត្តិធម៌អនីតិជននេះក៏ជាបញ្ហាថ្មីមួយសម្រាប់កម្ពុជា ដែលជាហេតុនាំឲ្យមានការយឺតយ៉ាវក្នុងការអនុវត្តច្បាប់។ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិនេះ ផ្តល់ជាផែនទីចង្អុលផ្លូវមួយសម្រាប់កម្ពុជាក្នុងការអនុវត្តច្បាប់នេះ និងកសាងប្រព័ន្ធយុត្តិធម៌អនីតិជនទំនើបមួយស្របតាមការអនុវត្តល្អៗរបស់អន្តរជាតិ។

ដើម្បីសម្រេចបានគោលដៅទាំងពីរដូចដែលលោក វង់ សូត បានលើកឡើង ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះបានផ្តោតលើកម្មវិធីយុទ្ធសាស្ត្រចំនួន៩ ដែលរួមមាន ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង ការអប់រំ និងការបណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ច ការបង្វែរ ការធ្វើសមាហរណកម្ម ការឃុំខ្លួន ការទប់ស្កាត់បទល្មើស ក្របខណ្ឌគោលនយោបាយនិងប្រព័ន្ធប្រតិបត្តិ និងការពិនិត្យតាមដាន និងវាយតម្លៃ៕

## ឃាត់ខ្លួនជនជាតិចិន ១០នាក់ ពាក់ព័ន្ធនឹងករណីកេងចំណេញផ្លូវភេទ ពីស្ត្រីវ័យក្មេង និងអនីតិជន

https://chsknews.com/ 2018/12/

ភ្នំពេញ៖ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង១០ និង០០នាទី ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធីផែនការងារអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដឹកនាំដោយ លោកអនុសេនីយ៍ឯក ចុល ចេក ជានាយរងការិយាល័យ បានចុះសហការជាមួយនាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងកម្លាំងសមត្ថកិច្ចមូលដ្ឋានប៉ុស្តិ៍នគរបាលរដ្ឋបាលនិរោធ ខណ្ឌច្បារអំពៅ មានការដឹកនាំដោយលោក ឧត្តមសេនីយ៍ឯក អ៊ុក ហៃសីឡា ប្រធាននាយកដ្ឋានស៊ើបអង្កេត និងអនុវត្តនីតិវិធី លោក សេង គឹមឡាក់ ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នឹងលោក ចេង សុផាន ក្រឡាបញ្ជី ចុះត្រួតពិនិត្យ និងឃាត់ខ្លួន ជនជាតិបរទេស ចំនួន២ ទីតាំង ស្ថិតនៅក្នុងផ្ទះលេខ N200 និងផ្ទះលេខ N២៣២ ផ្លូវប៉ុឡូរីស សង្កាត់និរោធ ខណ្ឌច្បារអំពៅ ជាលទ្ធផលពិនិត្យឃើញ ជនជាតិចិនសរុបចំនួន ១០នាក់ ប្រុស ពីបទបានប្រព្រឹត្តបទល្មើសកេងចំណេញផ្លូវភេទពីស្ត្រីវ័

យក្មេង និងអនីតិជន ប្រព្រឹត្តទៅនៅប្រទេសចិន ត្រូវបាន ឃាត់ខ្លួនបញ្ជូនទៅអគ្គនាយកដ្ឋាន ដើម្បីអនុវត្តនីតិវិធីបន្តនៃច្បាប់។

## កម្មករសំណង់ម្នាក់ដេកស្លាប់នៅក្រុងបាងកក

https://www.facebook.com/Matemohachun/ *សារព័ត៌មាន មតិមហាជន* December 20, 2018

បន្ទាយមានជ័យ:សពពលករខ្មែរម្នាក់ត្រូវភាគីថៃបញ្ជូនត្រឡប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតម៉ោងជា៥ល្ងាចថ្ងៃទី២០ ធ្នូ ២០១៨ បន្ទាប់ពីដេកស្លាប់នៅក្រុងបាងកកប្រទេសថៃ។ ជនរងគ្រោះជាអ្នកឃុំណាំតាវ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ វ័យ៤៦ឆ្នាំ និងជាកម្មករសំណង់ ។ ស្ត្រីជាប្រពន្ធជន រងគ្រោះប្រាប់ថា ប្តីរបស់គាត់ដេកស្លាប់យប់ថ្ងៃទី១៩ ខែធ្នូដដែល។ សពត្រូវបានសាច់ញាតិ ជួល រថយន្តដឹកបន្តទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី៕ដោយ ជីតា

## ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨

## សមត្ថកិច្ចចុះត្រួតពិនិត្យលើពលករបរទេសនៅក្រុងបាវិត

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 27/12/2018

ស្វាយរៀង ៖ លោកឧត្តមសេនីយ៍ឯក ចុង សុវណ្ណនី អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងលោកឧត្តមសេនីយ៍ឯក កែម សារិន ប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន៍ និងជាអ្នកវនិយោគឯកជន កាលពីម្សិលមិញបានចុះត្រួតពិនិត្យមើលឯកសារពាក់ព័ន្ធនានាសម្រាប់ពលករបរទេសចំនួន ២គោលដៅ ក្នុងក្រុងបាវិត ខេត្តស្វាយរៀង។

ក្រុមការងារបានត្រួតពលករបរទេស២,០០៨នាក់ រួមមាន០៥សញ្ជាតិ ដែលប្រើប្រាស់ Visa E, ប័ណ្ណការងារ, ពលករបរទេសដែល ទើបចូលមកធ្វើការនៅកម្ពុជា និងពលករបរទេស ដែលគ្មានប័ណ្ណការងារ ដើម្បីធ្វើការផាកពិន័យទៅតាមនីតិវិធីផងដែរ ៕

## កិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការ រក្សាសន្តិសុខព្រំដែន រវាងខេត្តព្រះសីហនុ កំពត កែប (កម្ពុជា) ជាមួយមន្ទីរនគរបាលខេត្តគៀនយ៉ាង(វៀតណាម)

http://cambodiapolice.com/policekh/ 9:50 am 27 ធ្នូ 2018

ខេត្តកែប៖ ថ្ងៃពុធ ០៤រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៨ លោកឧត្តមសេនីយ៍ត្រី បែន តារា ស្នងការនគរបាលខេត្តកែប បានដឹកនាំប្រតិភូស្នងការដ្ឋាននគរបាលខេត្ត ចំនួន៩រូប ដើម្បីអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការ ការការពាររក្សាសន្តិសុខព្រំដែន រវាងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ កំពត កែប (កម្ពុជា) ជាមួយមន្ទីរនគរបាលខេត្តគៀនយ៉ាង (វៀតណាម) ឆ្នាំ២០១៨ ដែលពិធីនេះប្រារព្ធធ្វើឡើងនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ។

កិច្ចប្រជុំបានស្តាប់របាយការណ៍លើកឡើងរបស់ស្នងការដ្ឋាននគរបាលនីមួយៗ ដែលមានព្រំដែនគោក និងព្រំដែនទឹកជាប់ជាមួយខេត្តគៀនយ៉ាង ប្រទេសវៀតណាម របាយការណ៍ខាងលើ បានផ្តោតសំខាន់ទៅលើ កិច្ចប្រតិបត្តិការ ការការពារសន្តិសុខព្រំដែន បង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើ សេដ្ឋកិច្ច គ្រឿងញៀន ការជួញដូរមនុស្ស

និងអាជីវកម្មផ្លូវភេទ ។ ទន្ទឹមនោះស្នងការនគរបាលខេត្តទាំងបួន ក៏ដូចជាប្រទេសទាំងពីរ បានប្តេជ្ញាបន្តរឹតចំណង មិត្តភាពអោយកាន់តែមានភាពស្អិតរមួតបន្ថែមទៀត ដើម្បីសុខសន្តិភាពប្រទេសជាតិយើងទាំងសងខាងផងដែរ ៕

## អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បញ្ជាក់ពីប្រតិបត្តិការបញ្ឈប់ការរៀបការជនជាតិបរទេស ជាមួយខ្មែរ នៅខេត្តកំពង់ចាម និងបង្ក្រាបជនជាតិចិន លួចទូរស័ព្ទ៣០០គ្រឿង ក្នុងកាស៊ីណូ នៅខេត្តឧត្តរមានជ័យ

http://www.freshnewsasia.com/ 2018-12-26

(ភ្នំពេញ)៖ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨នេះ បានបង្ហាញរបាយការណ៍ បញ្ជាក់ពីប្រតិបត្តិការបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍របស់ជនជាតិបរទេស ជាមួយជនជាតិខ្មែរ នៅខេត្តកំពង់ចាម និងប្រតិបត្តិការបង្ក្រាបជនជាតិចិន ដែលបន្លំលួចទូរស័ព្ទ៣០០គ្រឿង ក្នុងកាស៊ីណូនៅខេត្តឧត្តរមានជ័យ។

របាយការណ៍ដដែលបញ្ជាក់ថា នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ កម្លាំងនៃការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកព្រៃឈរ បានធ្វើកិច្ចសន្យាបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍ខុសច្បាប់ (ពុំមានលិខិតអនុញ្ញាតិពីក្រសួងមហាផ្ទៃ)។

លោកឧត្តមសេនីយ៍ត្រី សិត សិលា ស្នងការរងខេត្តកំពង់ចាម ទទួលផែនអន្តោប្រវេសន៍បានឲ្យដឹងថា ការបញ្ឈប់អាពាហ៍ពិពាហ៍នេះ រវាងឈ្មោះ VEN VATHANNAK ANTHONY ភេទប្រុស ជនជាតិអាមេរកាំង (ខ្មែរ-អាមេរិកាំង) និងឈ្មោះ ងួន សុខនី ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ។ ករណីនេះសមត្ថកិច្ច បានពន្យល់ណែនាំ អំពីនីតិវិធីនៃការរៀបអាពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដល់សាមីខ្លួនបានយល់។ ក្រោយពីបានពន្យល់ណែនាំចប់ សាម៉ីខ្លួន ក៏ដូចជាតំណាងអាណាព្យាបាល បានយល់ពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយជនបរទេស និងបានយល់ព្រមលុបចោលនូវរាល់ទម្រង់អាពាហ៍ពិពាហ៍ទាំងអស់។

ដោយឡែក សម្រាប់ប្រតិបត្តិការនៅខេត្តឧត្តរមានជ័យ ធ្វើឡើងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ដោយកម្លាំងនគរបាលអន្តោប្រវេសន៍ សហការជាមួយកម្លាំងនគរបាលព្រហ្មទណ្ឌ បានឃាត់ខ្លួនជនជាតិចិនចំនួន០២នាក់ ទី១៖ឈ្មោះ សៀជី សៀង អាយុ២៤ឆ្នាំ និងទី២៖ឈ្មោះ លី ជាសៀង អាយុ២៧ឆ្នាំ។ ការឃាត់ខ្លួននេះ ត្រូវបានធ្វើឡើងនៅចំណុចកាស៊ីណូអូរស្មាច់ ដោយជនជាតិចិនទាំង២នាក់ខាងលើ មកពីខេត្តព្រះសីហនុ ហើយបានបន្លំខ្លួនចូលក្នុងកាស៊ីណូ លួចទូរស័ព្ទដៃ អស់ប្រមាណ៣០០គ្រឿង។ ក្រោយពេលឃាត់ខ្លួន និងឆែកឆេរ បានរកឃើញទូរស័ព្ទដៃប្រមាណ ១០០គ្រឿង ហើយជនសង្ស័យមិនមានលិខិតឆ្លងដែននៅនឹងខ្លួនទេ។ បច្ចុប្បន្នកំពុងឃាត់ខ្លួន នៅស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ដើម្បីរៀបចំនីតិវិធីបន្តទៀត៕

## គ្រាន់តែជប៉ុនបើកទ្វារភ្លាម វៀតណាមសម្រុកបញ្ជូនពលករទៅទីនោះភ្លាម!

https://cambonomist.com/news/ 27-12-2018 ដោយ ខេមបូណូមីស

ឆ្នាំ២០១៨នេះ របាយការណ៍បង្ហាញថា ប្រទេសវៀតណាមបានបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសចំនួន ១ សែន ៤ម៉ឺននាក់ ដោយក្នុងនោះជប៉ុនគឺជាប្រទេសគោលដៅនាំមុខគេលំដាប់ទីមួយ នៃការនាំចេញពលករវៀតណាម។ នៅឆ្នាំនេះ ពលករវៀតណាមជាង ៦ម៉ឺន ៧ពាន់នាក់ បានចេញទៅធ្វើការនៅក្នុងប្រទេសជប៉ុន។ នេះបើតាមតួលេខពីនាយកដ្ឋានគ្រប់គ្រងពលករក្រៅប្រទេស នៃក្រសួងការងាររបស់វៀតណាម ដែលចុះផ្សាយយោងដោយសារព័ត៌មាន VN Express៕

កោះតៃវ៉ាន់ ឈរនៅលេខរៀងទីពីរ បន្ទាប់ពីជប៉ុន ពេលគឺមានពលករវៀតណាមចេញទៅធ្វើការនៅទីនោះ ៦ម៉ឺន ៥ពាន់នាក់។ កូរ៉េឈរនៅលេខទីបី ដោយមានចំនួនពលករវៀតណាម ៦០០០នាក់ ក្នុងឆ្នាំ២០១៨នេះ។ ទីផ្សារការងារសំខាន់ៗដទៃទៀត រួមមាន អារ៉ាប៊ី សាអូឌីត, រ៉ូមេនី, ម៉ាឡេស៊ី និង គូវ៉េត។

ការកើនឡើងនៃចំនួនពលករដែលបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ធ្វើឲ្យវៀតណាមជាប់ចំណាត់ថ្នាក់ក្នុងចំណោមប្រទេស១០ នៅលើពិភពលោក ដែលទទួលបានប្រាក់បញ្ញើពីក្រៅប្រទេសច្រើនជាងគេបំផុត កាលពីឆ្នាំទៅមិញ ដោយប្រាក់បញ្ញើពីក្រៅប្រទេសដែលវៀតណាមទទួលបាន គឺ ១៣,៨ពាន់លានដុល្លារអាមេរិក។ ការដែលវៀតណាមសម្រុកបញ្ជូនពលកររបស់ខ្លួនទៅប្រទេសជប៉ុន ត្រូវបានគេមើលឃើញថា បន្ទាប់ពីប្រទេសជប៉ុនដាក់ចេញនូវគោលនយោបាយបើកចំហទ្វារទទួលពលករពីក្រៅប្រទេស ដោយសារតែចំនួនប្រជាជនជប៉ុនកាន់តែថយចុះ និងមានមនុស្សចាស់ជរាច្រើនឡើងៗ។

យោងតាមអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) រៀងរាល់ឆ្នាំ ជនជាតិវៀតណាមប្រហែល ១សែននាក់ ចាកចេញពីប្រទេស ទៅរស់នៅក្នុងប្រទេសជឿនលឿនជុំវិញពិភពលោក។
នៅជប៉ុននិងកូរ៉េ ពលករវៀតណាមម្នាក់អាចរកបានចំណូលពី ១ពាន់ ទៅ ១ពាន់ ២រយដុល្លារអាមេរិក ក្នុងមួយខែ គឺ ៤ដងច្រើនជាងប្រាក់ខែជាមធ្យមនៅប្រទេសវៀតណាម ដែលស្មើនឹងប្រមាណ ២៩០ដុល្លារក្នុងមួយខែ៕

## ក្រុមពលករមីយ៉ាន់ម៉ាខុសច្បាប់១០០នាក់ ដែលជាប់ឃុំនៅប្រទេសថៃ ត្រូវបញ្ជូនត្រឡប់នៅប្រទេសកំណើតវិញ

http://www.freshnewsasia.com/ 2018-12-27

(រ៉ង់ហ្គូន)៖ ពលករមីយ៉ាន់ម៉ាខុសច្បាប់ ១០០នាក់ ដែលជាប់ឃុំនៅក្នុងប្រទេសថៃ ត្រូវបានបញ្ជូនត្រឡប់មកកាន់ប្រទេសកំណើតវិញហើយ ក្រោមកិច្ចសម្របសម្រួលរវាងអាជ្ញាធរប្រទេសទាំងពីរ។ នេះបើតាមការចេញផ្សាយដោយទីភ្នាក់ងារព័ត៌មានចិន ស៊ីនហួរ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៧ ខែធ្នូ ឆ្នាំ២០១៨។

ពលករមីយ៉ាន់ម៉ាទាំង ១០០នាក់មាន ១៨នាក់ជាស្ត្រីបានត្រឡប់ទៅដល់ទីក្រុង កំផ្លង (Kawthoung) រដ្ឋកាយីន (Kayin) វិញហើយតាមរយៈទូកឆ្លងកាត់ខេត្ត រ៉ាណុង (Ranong) ប្រទេសថៃកាលពីថ្ងៃពុធ។ ពលករទាំងនេះភាគច្រើនមកពីទីក្រុង តានីនថាយី (Tanintharyi), រ៉ង់ហ្គូន (Yangon), បាហ្គោ (Bago), ម៉ាក់វ៉ាយ (Magway), មន (Mon), រដ្ឋរ៉ាឃីន (Rakhine) និងរដ្ឋឈីន (Chin) ជាដើម។

គួរជម្រាបថា កាលពីថ្ងៃសៅរ៍សប្តាហ៍មុន ពលករមីយ៉ាន់ម៉ាខុសច្បាប់ ១៥នាក់ ក៏ត្រូវបានបញ្ជូនត្រឡប់មកកាន់ស្រុកកំណើតវិញផងដែរ បន្ទាប់ពីពលករ ៧៣នាក់ផ្សេងទៀត ត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់ទៅកាន់ទីក្រុង មីយ៉ាវ៉ាដឌី (Myawaddy) របស់មីយ៉ាន់ម៉ា ដែលជាប់ព្រំដែនជាមួយប្រទេសថៃ៕

## វៀតណាម បញ្ជូនពលករទៅក្រៅប្រទេសប្រមាណ ១៤ម៉ឺននាក់ ក្នុងឆ្នាំ២០១៨

http://kleykley.sabay.com.kh/ *ថ្ងៃទី ២៦ ធ្នូ ២០១៨ ម៉ោង 16:20*

វៀតណាម បានបញ្ជូនពលករសរុបប្រមាណ ១៤ម៉ឺននាក់ ទៅធ្វើការនៅក្រៅប្រទេសក្នុងឆ្នាំ២០១៨នេះ ដោយកើនឡើង ៧% បើប្រៀបធៀបនឹងឆ្នាំមុន ហើយក៏ជាឆ្នាំទី៥ ដែលវៀតណាមដែលវៀតណាម បញ្ជូនទៅពលករទៅបរទេស លើសពី ១០ម៉ឺននាក់ផងដែរ។ នេះបើតាមការចុះផ្សាយរបស់វិបសាយវៀតណាម VN EPRESS នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ដោយដកស្រង់ចេញពីរបាយការណ៍របស់ក្រសួងការងារវៀតណាម។

ជប៉ុន គឺជាទីផ្សារការងារធំបំផុតដែលពលករវៀតណាមជាង ៦៧ ០០០នាក់ ទៅធ្វើការនៅទីនោះ។ បន្ទាប់មក តៃវ៉ាន់ ជាង៦៥០០០នាក់ និងទី៣ គឺកូរ៉េខាងត្បូង ជាង ៦៣ពាន់នាក់។ ក្រៅពីនោះរួមមាន អារ៉ាប៊ីសាអ៊ូឌីត រ៉ូម៉ានី ម៉ាឡេស៊ី និងគូវ៉ែត។ ការកើនឡើងនូវចំនួនពលករចេញទៅក្រៅប្រទេសនេះ ធ្វើឱ្យវៀតណាម ស្ថិតក្នុងចំណោមប្រទេសទាំង ១០ ដែលទទួលបានប្រាក់ពីពលករវៀតណាមនៅក្រៅប្រទេស គឺ ១៣,៨ពាន់លានដុល្លារ។

បើតាមអង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ បានឱ្យដឹងថា ជនជាតិវៀតណាមប្រហែល ១០ម៉ឺននាក់ បានចាកចេញពីប្រទេសជារៀងរាល់ឆ្នាំ ដើម្បីទៅរស់នៅក្នុងប្រទេសដែលមានការអភិវឌ្ឍជាងវៀតណាម៕ ប្រភព ៖ Vietnam Express ប្រែសម្រួល៖ សំភី

## អាជ្ញាធរកោះតៃវ៉ាន់ បើកប្រតិបត្តិការតាមរកភ្ញៀវទេសចរជាជនជាតិវៀតណាមចំនួន១៥២នាក់

http://www.freshnewsasia.com/ 2018-12-26

(តៃប៉ិ)៖ អាជ្ញាធរតៃវ៉ាន់នាថ្ងៃពុធនេះបានប្រកាសឲ្យដឹងពី ការរុករកជនជាតិវៀតណាមចំនួន១៥២នាក់ ដែលបានមកដល់ដែនដីកោះនេះដោយប្រើប្រាស់ទិដ្ឋាការទេសចរណ៍ ខណៈសារព័ត៌មានក្នុងស្រុករបស់តៃវ៉ាន់បានរាយការណ៍ថា ពួកគេទាំងនោះអាចមកកាន់តៃវ៉ាន់ ដើម្បីធ្វើការងារដោយខុសច្បាប់។ នេះបើតាមការដកស្រង់ការផ្សាយចេញពីសារព័ត៌មាន Channel News Asia នៅល្ងាចថ្ងៃពុធ ទី២៦ ខែធ្នូ ឆ្នាំ២០១៨។

អ្នកទេសចរវៀតណាមខាងលើ ទទួលបានទិដ្ឋាការនៅក្រោមកម្មវិធីផ្តួចផ្តើមមួយ ដែលត្រូវបានបង្កើតឡើងកាលពីបីឆ្នាំមុន ដើម្បីទាក់ទាញអ្នកចូលចិត្តធ្វើដំណើរកម្សាន្ត ពីតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ឲ្យមកកាន់កោះតៃវ៉ាន់។ តាមការបញ្ជាក់ពីទីភ្នាក់ងារអន្តោប្រវេសន៍តៃវ៉ាន់ ជនជាតិវៀតណាមសរុប១៥៣នាក់ បានមកដល់ក្រុងកៅស៊ុង (Kaohsiung) កាលពីអំឡុងចុងសប្តាហ៍មុន ប៉ុន្តែ១៥២នាក់ក្នុងចំណោមនោះបានបាត់ខ្លួន។

គួរជម្រាបថា បើតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកតៃវ៉ាន់ ក្រុមជនជាតិវៀតណាមទាំងនោះ ប្រហែលជាមកតៃវ៉ាន់ ដើម្បីធ្វើការដោយខុសច្បាប់ ហើយពួកគេប្រឈមនឹងការត្រូវបញ្ជូនទៅកាន់ប្រទេសកំណើតវិញ រួមជាមួយបម្រាមលែងឲ្យឈានជើងចូលតៃវ៉ាន់ទៀតសម្រាប់រយៈពេលពី០៣ទៅ០៥ឆ្នាំ។ កន្លងទៅក៏ធ្លាប់មានករណីបាត់ខ្លួនភ្ញៀវទេសចរ ១៥០នាក់ នៅក្រោមកម្មវិធីខាងលើផងដែរ ប៉ុន្តែមិនច្បាស់ថាប៉ុន្មាននាក់ត្រូវបានរកឃើញនោះឡើយ៕

# ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨

## នគរបាលប៉ុស្តិ៍ចាំយាមទទួលពលករខ្មែរ៩នាក់ ពីភាគីថៃបញ្ជូនមក

http://cambodiapolice.com/policekh/ 3:08 pm 27 ធ្នូ 2018

កោះកុង ៖ នៅវេលាម៉ោង១៨ និង០០នាទី ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ នគរបាលប៉ុស្តិ៍ចាំយាម បានទទួលពលករខ្មែរ ពីភាគីថៃបញ្ជូនមកចំនួន៩នាក់ ក្នុងនោះមានស្រី០២នាក់ ។ ពួកគេត្រូវបានសមត្ថកិច្ចថៃចាប់ឃាត់ខ្លួន ខណៈឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ។ បន្ទាប់ពីធ្វើការអប់រំ ណែនាំរួចមក សមត្ថកិច្ចអនុញ្ញាតិអោយត្រឡប់ទៅផ្ទះវិញ ៕

# ឧត្តមសេនីយ៍ឯក ឌី វិជ្ជា វាយតម្លៃខ្ពស់ចំពោះវគ្គបណ្តុះបណ្តាលស្តីពីសន្តិសុខប្រព័ន្ធបច្ចេកវិទ្យា ពិតជានឹងបានចូលរួមចំណែកក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបការប្រើប្រាស់បច្ចេកវិទ្យាក្នុងការប្រព្រឹត្តបទល្មើសឆ្លងដែន

http://cambodiapolice.com/policekh/ 5:52 pm 27 ធ្នូ 2018

ភ្នំពេញ ៖ ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ បានវាយតម្លៃខ្ពស់ចំពោះវគ្គបណ្តុះបណ្តាលស្តីពីសន្តិសុខប្រព័ន្ធបច្ចេកវិទ្យា ពិតជានឹងបានចូលរួមចំណែកក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបការប្រើប្រាស់បច្ចេកវិទ្យាក្នុងការប្រព្រឹត្តបទល្មើសឆ្លងដែន ដែលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម។ ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីសន្តិសុខប្រព័ន្ធបច្ចេកវិទ្យា ក្រោមការឧបត្ថម្ភរបស់ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន នារសៀលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨នេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ បានមានប្រសាសន៍ថា ថ្វីត្បិតវគ្គបណ្តុះបណ្តាលរបស់យើងបានដំណើរការមានរយៈពេលតែពីរសប្តាហ៍ ប៉ុន្តែរយៈពេលនេះវាហាក់បីដូចជាខ្លីបន្តិច ក៏ប៉ុន្តែវាសមស្របសម្រាប់សិក្ខាកាមទាំងអស់ត្រេងត្រាប់ចាប់យកធ្វើជាមូលដ្ឋាន ដើម្បីបង្កើននូវសមត្ថភាព មុខជំនាញ និងពង្រីកប្រសិទ្ធភាពប្រតិបត្តិការរបស់ខ្លួនតាមរយៈសមត្ថភាព និងភាពប៉ិនប្រសព្វប្រកបដោយបទពិសោធន៍ខាងទ្រឹស្តី និងការពន្យល់នូវមេរៀនរបស់គ្រូឯកទេស។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា មានប្រសាសន៍ទៀតថា អំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សកលលោកទាំងមូលបានជួបនឹងបញ្ហាប្រឈមជាច្រើន ជាពិសេសបណ្តាព្រឹត្តការណ៍អវិជ្ជាមានមួយចំនួនដែលបានកើតឡើងជាបន្តបន្ទាប់ បានឆ្លុះបញ្ចាំងឲ្យឃើញអំពីភាពផុយស្រួយទាំងវិស័យសេដ្ឋកិច្ច នយោបាយ និងសន្តិសុខនៃតំបន់មួយចំនួន។ ការរីករាលដាលនៃឧក្រិដ្ឋកម្មឆ្លងដែន និងបទឧក្រិដ្ឋមានការចាត់តាំង ការបង្កចលាចលក្នុងសង្គម នៅតែជាវិញ្ញាដ៏ស្មុគស្មាញដែលពិភពលោកបាននឹងកំពុងប្រឈមយ៉ាងចាក់ស្រេះ គ្មានប្រទេសណាមួយហ៊ាននិយាយថា អាចដោះស្រាយបានដោយខ្លួនឯង ហើយទាំងអស់នេះ គឺជាកាតព្វកិច្ចរបស់កងកម្លាំងអនុវត្តច្បាប់ ដែលត្រូវប្រឹងប្រែងតស៊ូជម្នះឲ្យខានតែបាន ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម។

ស្ថានការណ៍ប្រកបដោយគ្រោះថ្នាក់ លេចធ្លោក្នុងដំណាក់កាលថ្មីនេះ គឺសកម្មភាពភេរវកម្ម បទល្មើសបច្ចេកវិទ្យា សកម្មភាពជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ការជួញដូរអាវុធជាតិផ្ទុះ និងសកម្មភាពបង្កចលាចល ដែលបាននឹងកំពុងគំរាមកំហែងដល់សុវត្ថិភាព សន្តិសុខសង្គម ក៏ដូចជាជីវភាព និងអាយុជីវិតមនុស្សនៅក្នុងប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា បញ្ជាក់ថា " ដោយសាបញ្ហាទាំងអស់នេះ ទើបទាមទារឲ្យមន្ត្រីអនុវត្តច្បាប់ត្រូវបង្កើនសមត្ថភាពរបស់ខ្លួនជាប់ជាប្រចាំ តាមរយៈការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈបន្ថែមជាបន្តបន្ទាប់ ដើម្បីធ្វើបច្ចុប្បន្នភាពសមត្ថភាព ដែលអាចឆ្លើយតបប្រកមដោយប្រសិទ្ធភាព ទៅនឹងការវិវត្តន៍ប្រែប្រួលនៃសភាពការណ៍ ក៏ដូចសកម្មភាពនៃបទឧក្រិដ្ឋ។ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គស្នងការរង មានជំនឿជឿជាក់ថា ឆ្លងតាមការបណ្តុះបណ្តាលវគ្គនេះ សិក្ខាកាមទាំងអស់ពិតជាប្រមូលបានបទពិសោធន៍ ចំណេះដឹងសម្រាប់ជាមូលដ្ឋាន ដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនបម្រើឲ្យបុព្វហេតុសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។ ហើយឆ្លៀតក្នុងឱកាសនេះ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានបញ្ជូនគ្រូឯកទេសប្រកបដោយបទពិសោធន៍ខ្ពស់មកជួយបណ្តុះបណ្តាលដល់នគរបាលជាតិកម្ពុជា ដើម្បីមានសមត្ថភាពក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស។

ក្នុងឱកាសនោះដែរ ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គស្នងការរង ក៏បានផ្ដាំផ្ញើឲ្យសិក្ខាកាមទាំងអស់យកនូវបទពិសោធន៍ និងចំណេះដឹង ដែលទទួលបានពីវគ្គបណ្ដុះបណ្ដាលនេះ យកទៅចែករំលែកជូនសហការីរបស់ខ្លួន សំដៅពង្រីកនូវសមត្ថភាពប្រតិបត្តិការក្នុងបម្រើឲ្យភាពសុខសាន្តរបស់ពលរដ្ឋ និងប្រទេសជាតិ ។

## ប្រារព្ធ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១២ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស" ខេត្តបាត់ដំបង

https://www.battambang.gov.kh/ 28-12-2018

រដ្ឋបាលខេត្តបាត់ដំបងបានប្រារព្ធ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១២ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស" នាព្រឹកថ្ងៃ ព្រ.ហ ៥រោច ខែមិគសិរ ឆ្នាំច ព.ស ២៥៦២ ត្រូវហ្នឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ នៅសាលមហោស្រពស្ទឹងសង្កែ ក្រុងបាត់ ដំបង ក្រោមអធិបតីភាពលោកជំទាវ ញ៉ឹក សាគន្ធ អភិបាលរងនៃគណៈអភិបាលខេត្ត និងជា អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត និងលោកជំទាវ ផា វ៉ាន់ សាកឿត សមាជិកក្រុមព្រឹក្សាខេត្ត ព្រមទាំងមានការចូលរួមពីបណ្ដាលមន្ទីរ អង្គភាពនានាជុំវិញខេត្ត អង្គការដៃគូរ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងប្រជាពលរដ្ឋនៅតាមសង្កាត់នានានៅក្នុង ក្រុងបាត់ ដំបងចូលរួមជាច្រើននាក់ផងដែរ។

## ទូកចំណាកស្រុក ៦គ្រឿង ត្រូវបានជួយសង្គ្រោះនៅដែនសមុទ្រអង់គ្លេស

https://www.postkhmer.com/ AFP | Publication date 27 December 2018 | 17:28 ICT

ក្រុងឡុងដ៍: ក្រុមមន្ត្រី បាននិយាយកាលពីថ្ងៃពុធថា ក្រុមអាជ្ញាធរដែនសមុទ្រអង់គ្លេស និងបារាំង បានជួយសង្គ្រោះក្រុមជនចំណាកស្រុកជាង៤០នាក់ ដែលកំពុងព្យាយាមឆ្លងកាត់ព្រំដែនទៅកាន់ប្រទេសអង់គ្លេស ដោយជិះទូកតូច ៦គ្រឿង កាលពី ២ថ្ងៃកន្លងទៅ។

មន្ត្រីការិយាល័យអន្តោប្រវេសន៍របស់អង់គ្លេស បាននិយាយថា ទូកតូច ៦គ្រឿង ដែលដឹកមនុស្ស ៤០នាក់ ចេញពីប្រទេសអ៊ីរ៉ាក់ អ៊ីរ៉ង់ និងអាហ្វហ្គានីស្ថាន ត្រូវបានឃាត់ឲ្យឈប់ នៅថ្ងៃបុណ្យណូអែល។ អ្នកនាំពាក្យការិយាល័យអន្តោប្រវេសន៍ បាននិយាយថា៖«កស្តុតាងនោះ បានបង្ហាញឲ្យឃើញថា មានការរៀបចំបង្កើតសកម្មភាពក្រុមឧក្រិដ្ឋជននៅពីក្រោយការប៉ុនប៉ងធ្វើចំណាកស្រុកដោយខុសច្បាប់ ដោយជិះទូកតូចៗជាច្រើនគ្រឿងឆ្លងសមុទ្រទៅអង់គ្លេស»។«យើងកំពុងធ្វើការយ៉ាងជិតស្និត ជាមួយប្រទេសបារាំង និងក្រុមប្រទេសជាដៃគូអនុវត្ត ច្បាប់ជាច្រើនទៀត ដោយបានយកក្រុមឧក្រិដ្ឋជន ដែលជួញដូរជនចំណាកស្រុកទាំងអស់នោះ ជាគោលដៅ ហើយធ្វើឲ្យពួកគេ ប្រឈមនឹងគ្រោះថ្នាក់ដល់ជីវិត »។ SK

# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

## ខ្វះស្ត្រីក្នុងស្រុក បុរសចិនងាកទៅទិញស្រីវៀតណាម មកធ្វើប្រពន្ធ

http://km.rfi.fr/asia/ ដោយ អៀង សុខម៉ិញ 29/12/2018

នយោបាយកូនទោលរបស់ចិន និងប្រពៃណីចង់បានតែកូនប្រុសសម្រាប់បន្តត្រកូល បាននិងកំពុងបន្តឱ្យសង្គមចិនវិសមភាព បុរសច្រើនជាងស្ត្រី។ ដោយមិនអាចរកប្រពន្ធបាននៅក្នុងប្រទេស បុរសចិនបានងាកទៅរកទិញស្ត្រីនៅ

ប្រទេសជិតខាង ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ក្រៅអំពីរបាយការណ៍ដ៏រន្ធត់ស្ដីអំពីការលក់ដូចស្ត្រីភូមាទៅឱ្យចិន វៀតណាមក៏អ្នករងគ្រោះដ៏សំខាន់មួយនៃការលក់ដូរស្ត្រីភេទនេះដែរ។

មិនខុសពីបណ្ដាប្រទេសជិតខាង ជាពិសេសឡាវនិងភូមា ស្ត្រីវៀតណាមដែលភាគច្រើនរស់នៅក្នុងតំបន់ក្រីក្រដាច់ស្រយាល ក៏កំពុងក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស តាមរយៈការលក់យ៉ាងថ្លៃទៅឱ្យបុរសចិន។ ដើម្បីបន្លំស្ត្រីរងគ្រោះ ឈ្មួញបានអួតអាងអំពីជីវិតដ៏ប្រសើរនៅចិន និងអំពីភាពទូលំទូលាយនៃទីផ្សារការងារនៅចិន ឬក៏ការរៀបចំអាពាហ៍ពិពាហ៍ជាមួយបុរសអ្នកមានចិន។ ហើយក៏មានច្រើនដែរករណីចាប់ស្ត្រីវៀតណាមយកទៅត្រង់ៗតែម្ដង ក្រោយពីបានបង្អកគ្រឿងញៀន។ ជាទូទៅ គឺក្រុមគ្រួសារ និងមនុស្សជំនិតរបស់ជនរងគ្រោះជាអ្នករៀបចំផែនការលក់ស្ត្រី នេះឡើង។

បើតាមអង្គការក្រៅរដ្ឋាភិបាល Dragon bleu នាគខៀវ មានស្ត្រីជាច្រើនពាន់នាក់ណាស់ ក្នុងមួយឆ្នាំៗ ដែលបានក្លាយជាជនរងគ្រោះនៃជំនួញទិញប្រពន្ធ។ គិតចាប់តាំងពីឆ្នាំ២០០៧មក អង្គការបានសង្គ្រោះស្ត្រីរងគ្រោះវៀតណាមមិនតិចជាង៤០០នាក់ ពីអន្លង់ទាសករផ្លូវភេទ និងដែលត្រូវគេរៀបការដោយបង្ខំ ឱ្យរត់គេចខ្លួនត្រលប់មកពីចិនវិញបាន។ ហើយជាទូទៅ គឺស្ត្រីរងគ្រោះផ្ទាល់ជាអ្នកស្វែងអន្តរាគមន៍សង្គ្រោះ។ សកម្មភាពរបស់អង្គការត្រូវបានគេទទួលស្គាល់កាន់តែច្រើន។ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយនេះ អង្គការក៏បានរកឃើញអ្នកជួញដូរមនុស្សឱ្យខុសច្បាប់៧៦នាក់ ឱ្យតុលាការកាត់ទោស។ ជាចំនួនដ៏ច្រើនបើយោងទៅលើទំហំនិងមធ្យោបាយដ៏ស្ដួចស្ដើងរបស់អង្គការ តែជាចំនួនដ៏តិចបំផុត បើប្រៀបទៅចំនួនស្ត្រីរងគ្រោះ។

ទោសជួញដូរស្ត្រី អាចនឹងត្រូវជាប់ពន្ធនាគារដល់ទៅ ២០ឆ្នាំ ប៉ុន្តែជំនួញនេះត្រូវបានរៀបចំឡើងជាបណ្ដាញនិងស៊ុះសាយខ្លាំង ព្រមទាំងផ្ដល់ផលយ៉ាងកាក់កប ក្នុងទំហំដល់ទៅរាប់សិបលានអឺរ៉ូ នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រោះតម្រូវការមកពីខាងចិន មិនចុះថយសោះ ហើយការអប់រំស្ត្រីតាមជនបទក៏នៅមានកំរិតទៀត៕